សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Économique
Royal Uniersity of Law and Economics

# សារណាបញ្ចប់ការសិក្សា

# អនីតិសង្វាសនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ឡាយ សំណាង**
លោក **វ៉ាយ ដេវីដ**

ណែនាំដោយ
លោកគ្រូ **ឃួយ កុសល**

ថ្នាក់បរិញ្ញាបត្រ**នីតិសាស្ត្រ**
ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ឡាយ សំណាង** និង **រ៉ាយ ដេវីដ** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២០-២០២៤។ ក្នុងនាមយើងខ្ញុំជាយុវជនជំនាន់ក្រោយ ដែលជាទំពាំងស្នងឫស្សី និងជាសសរទ្រូងប្រទេសជាតិ យើងខ្ញុំបានស្រាវជ្រាវ និងសរសេរជាសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទស្តីពី "**អនីតិសង្វាសនៅកម្ពុជា**"។

យើងខ្ញុំសូមធ្វើការថ្លែងអំណរគុណ និងសំដែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅចំពោះ **លោកឪពុក** និង **អ្នកម្តាយ** ជាទីគោរពស្រឡាញ់នៃកូន ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅណែនាំផ្តល់ដំបូន្មាន និងផ្តល់ក្តីស្រឡាញ់ចំពោះកូនតាំងពីតូចរហូតដល់ធំពេញវ័យ ហើយរូបលោកបានលះបង់គ្រប់បែបយ៉ាង នូវកម្លាំងកាយចិត្ត ទាំងផ្នែកបញ្ញា និងស្មារតី លើកទឹកចិត្តក្នុងការខិតខំសិក្សារៀនសូត្រ និងផ្តល់ជាថវិកា សម្ភារៈប្រើប្រាស់ក្នុងការសិក្សារៀនសូត្រផងដែរ។

ទន្ទឹមគ្នានេះដែរ យើងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីក្នុងនីតិកាលទី៧ នៃរដ្ឋសភា ដែលលោកបានដាក់ចេញនូវគោលនយោបាយល្អៗដើម្បីរក្សាសន្តិភាពជាតិ និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ក្នុងការអភិវឌ្ឍវិស័យអប់រំនៅប្រទេសកម្ពុជា។

ជាងនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណដល់ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង** និង **លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអប់រំអស់ពីសមត្ថភាពក្នុងការផ្ទេរចំណេះដឹង បទពិសោធន៍ ឯកសារសិក្សាស្រាវជ្រាវ ដល់យើងខ្ញុំក្នុងការសិក្សារៀនសូត្រ។

ជាពិសេស សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកគ្រូ **ឃួយ កុសល** ដែលជាសាស្ត្រាចារ្យណែនាំដល់យើងខ្ញុំ និងបានចំណាយពេលវេលាដ៏មានតម្លៃសម្រាប់ធ្វើការបង្ហាត់បង្ហាញណែនាំ កែតម្រូវ ផ្តល់ការប្រឹក្សា និងអនុសាសន៍ល្អៗ ដែលធ្វើឱ្យកិច្ចដំណើរការនៃការស្រាវជ្រាវ និងចងក្រងនូវឯកសារសារណានេះប្រកបដោយលទ្ធផលល្អ។

ជាចុងបញ្ចប់ យើងខ្ញុំសូមឱ្យវត្ថុស័ក្តសិទ្ធិទាំងអស់ក្នុងលោកតាមថែរក្សា ការពារ និងប្រសិទ្ធិពរជ័យសិរីសួស្តី ដល់ លោកឪពុក អ្នកម្តាយ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ ឱ្យជួប្រទះតែសេចក្តីសុខ សេចក្តីចម្រើន សុខភាពល្អ កាយសម្បទារឹងមាំ ជោគជ័យគ្រប់ភារកិច្ច និងជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

ជាបឋម ខ្ញុំបាទ **ឡាយ សំណាង** និង ខ្ញុំបាទ **វ៉ាយ ដេវីដ** សូមគោរពលោកសាស្ត្រាចារ្យព្រមទាំងស្វាគមន៍ដល់មិត្តអ្នកអានគ្រប់រូប ជាពិសេស សិស្ស និស្សិត ជាទីរាប់អាន។

ក្នុងនាម ជានិស្សិតដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងរាជធានីភ្នំពេញ បានរៀបចំនូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២៤ ក្រោមប្រធានបទស្តីពី «**អនីតិសង្វាសនៅកម្ពុជា**» នេះឡើង ដោយសារមើលឃើញថា ចំណងអនីតិសង្វាស គឺជាបញ្ហាដ៏ស្មុគស្មាញមួយបានកំពុងតែមានអត្ថិភាពនៅក្នុងសង្គមកម្ពុជាសព្វថ្ងៃនេះ។ ម្យ៉ាងទៀត ដោយសារតែក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បានចែងពីរបៀបគតិយុត្តពាក់ព័ន្ធតែសហព័ទ្ធដែលបានចុះបញ្ជីអាពាហ៍ពិពាហ៍ប៉ុណ្ណោះ ហេតុនេះ តើការដោះស្រាយទៅលើបញ្ហារបស់អនីតិសង្វាសនៅកម្ពុជាមានលក្ខណៈបែបណាទៅ? ជាការពិតណាស់ ប្រជាជនខ្មែរនាពេលបច្ចុប្បន្ននេះ បានចាប់ដៃគូគ្នារួមរស់ជាប្តីប្រពន្ធ និងមានប្តីប្រពន្ធខ្លះក៏បានចុះបញ្ជីអាពាហ៍ពិពាហ៍ហៅថា សហព័ទ្ធ និងខ្លះទៀតមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ហៅថា អនីតិសង្វាស។ ពួកគាត់មិនបានយល់ដឹងពីឥទ្ធិពលនៃការរស់នៅជាអនីតិសង្វាសទៅលើទំនាក់ទំនងទាំងផ្នែកបុគ្គល និងផ្នែកទ្រព្យសម្បត្តិឡើយ ហេតុនេះហើយ បានជាយើងទាំងពីរនាក់បាន សម្រេចចិត្តក្នុងការរៀបចំសារណា ពីប្រធានបទមួយនេះ ព្រមទាំងមានការគាំទ្រ និងលើកទឹកចិត្ត និងផ្តល់ការណែនាំយ៉ាងពេញទំហឹងពីសំណាក់ លោកគ្រូ **ឃួយ កុសល** ជាសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សារណានេះ នឹងចូលរួមជាវិភាគទានដ៏សំខាន់នៅក្នុងការយល់ដឹងអំពីបញ្ហានានាពាក់ព័ន្ធអនីតិសង្វាសនៅកម្ពុជា ដែលកន្លងមកប្រជាជនខ្មែរ យើងមិនបានចាប់អារម្មណ៍ពីការចាប់ដៃគូក្នុងការរស់នៅរបស់ខ្លួន ដែលមានឥទ្ធិពលទៅលើទំនាក់ទំនងបុគ្គល និងទ្រព្យសម្បត្តិ ខណៈពេលរស់នៅជាមួយគ្នា និងនៅពេលដែលបែកបាក់គ្នាដោយមូលហេតុណាមួយដូចជា ការលែងលះ ឬ មរណភាពឡើយ។ យើងខ្ញុំសង្ឃឹមទៀតថា សារណាមួយនេះ នឹងក្លាយជាឯកសារស្រាវជ្រាវ ដែលបាននឹងកំពុងជួបប្រទះនូវកង្វះខាតផងដែរ។ យើងខ្ញុំក៏សូមអភ័យទោសផងដែរ នូវរាល់កង្វះខាតទាំងឡាយដែលមាននៅក្នុងសារណានេះ យើងខ្ញុំ រង់ចាំទទួលការរិះគន់ដើម្បីកែលម្អពីសំណាក់មិត្តអ្នកអានទាំងអស់គ្នា។

ជាចុងក្រោយនេះ យើងខ្ញុំ សូមប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការ ចូលកើតមានដល់គណៈគ្រប់គ្រងសាលា សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត មិត្តភក្តិរួមជំនាន់ និងមិត្តអ្នកអានទាំងអស់ ជាពិសេសលោកគ្រូ **ឃួយ កុសល** ដែលបានចំណាយពេលវេលាដ៏មានតម្លៃជួយជំរុញ និងលើកទឹកចិត្តដល់ក្រុមយើងខ្ញុំ ក្នុងការចងក្រងសារណានេះឡើង ឱ្យជួបប្រទះនឹងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្ដីផ្ដើម** ........................................ ១
១. លំនាំបញ្ហានៃការស្រាវជ្រាវ ........................................ ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................ ១
៣. គោលបំណងនៃកិច្ចការស្រាវជ្រាវ ........................................ ២
៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........................................ ២
៥. សារៈសំខាន់នៃការស្រាវជ្រាវ ........................................ ២
៦. វិធីសាស្ត្រស្រាវជ្រាវ ........................................ ២
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................ ៣


## ជំពូកទី១

## ទិដ្ឋភាពទូទៅនៃអនីតិសង្វាស

**ផ្នែកទី១ សញ្ញាណទូទៅនៃអនីតិសង្វាស** ........................................ ៤
១.១. ទស្សនៈទាននៃអនីតិសង្វាសនៅកម្ពុជា ........................................ ៤
១.២. និយមន័យ ........................................ ៥
១.៣. មូលហេតុនាំឱ្យមានការរួមរស់ជាអនីតិសង្វាស ........................................ ៥
១.៣.១. ការមិនគោរពលក្ខខណ្ឌឱឡារិកនៃអាពាហ៍ពិពាហ៍ ........................................ ៦
១.៣.១.១. លក្ខខណ្ឌគ្រឹះ ........................................ ៦
១.៣.១.២. លក្ខខណ្ឌទម្រង់ ឬនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ ........................................ ៧
១.៣.២. និយ័តកម្មចំពោះអាពាហ៍ពិពាហ៍មិនបានចុះបញ្ជី ........................................ ៨
**ផ្នែកទី២ លក្ខណៈនីតិសង្វាសធៀបនិងអនីតិសង្វាស** ........................................ ១០
២.១. អត្ថន័យនីតិសង្វាស ........................................ ១០
២.២. ការធៀបនីតិសង្វាស និងអនីតិសង្វាស ........................................ ១០
២.២.១. នីតិសង្វាស ........................................ ១០
២.២.២. អនីតិសង្វាស ........................................ ១២

# ជំពូកទី២
# ការបង្កើត និងការរំលាយអនីតិសង្វាស

**ផ្នែកទី១ ការបង្កើតអនីតិសង្វាស** ........ ១៥

**កថាខណ្ឌទី១ លក្ខខណ្ឌសារធាតុនៃការបង្កើតអនីតិសង្វាស** ........ ១៥

១.១. ការរួមរស់ជាមួយគ្នា ........ ១៥

១.២. ការសង្គ្រោះរវាងគ្នា ........ ១៦

១.៣. សមគួសង្វាសតាមព្រឹត្តន័យ ........ ១៦

១.៤. លក្ខណៈស្ថិរភាព និងនិរន្តរភាព ........ ១៦

១.៥. ការរិនិច្ឆ័យអំពីភេទ ........ ១៧

១.៦. ភស្តុតាងដើម្បីគាំទ្រលក្ខខណ្ឌសារធាតុនៃអនីតិសង្វាស ........ ១៨

**កថាខណ្ឌទី២ អានុភាពក្នុងអំឡុងពេលរួមអនីតិសង្វាស** ........ ១៩

២.១. អានុភាពពាក់ព័ន្ធនឹងបុគ្គល ........ ១៩

២.១.១. អានុភាពរវាងអនីតិសង្វាសជន ........ ១៩

២.១.១.១. ការបង្កើតចំណងញាតិ ........ ១៩

២.១.១.២. ការទទួលបានអត្តាធីនភាព ........ ២០

២.១.១.៣. ការប្រើប្រាស់នាមត្រកូលប្តី ឬប្រពន្ធ ........ ២០

២.១.១.៤. កាតព្វកិច្ចដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍ ........ ២០

២.១.២. អានុភាពចំពោះកូន ........ ២២

២.១.២.១. ការកំណត់អ្នកមានអំណាចមេបា ........ ២២

២.១.២.២. អំពីបុត្តភាព ........ ២៣

២.១.២.៣. ការសន្មតបិតុភាព ........ ២៣

២.១.២.៤. អាហារកាតព្វកិច្ច ឬអាហារកិច្ច ........ ២៤

២.១.៣. អភ័យឯកសិទ្ធិគ្រួសារ ........ ២៥

២.២. អានុភាពពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ ........ ២៦

២.២.១. ទ្រព្យសម្បត្តិជាកម្មសិទ្ធិផ្ទាល់ខ្លួន ........ ២៦

២.២.២. ទ្រព្យសម្បត្តិជាកម្មសិទ្ធិរួម ........ ២៧

២.២.២.១. ប្រភពនៃទ្រព្យសម្បត្តិរួម ........ ២៧

២.២.២.២. ការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិរួម....២៧
២.២.៣. កាតព្វកិច្ចបំណុលរបស់អនីតិសង្វាស....២៨
**ផ្នែកទី២ ការរំលាយចំណងអនីតិសង្វាស....២៨**
**កថាខណ្ឌទី១ សញ្ញាណទាក់ទងការរំលាយអនីតិសង្វាស....២៩**
១.១. មូលហេតុនៃការរំលាយអនីតិសង្វាស....២៩
១.២. នីតិវិធីនៃការរំលាយអនីតិសង្វាស....៣០
១.២.១. បណ្តឹងរំលាយ....៣០
១.២.១.១. ការដាក់ពាក្យបណ្តឹង....៣១
១.២.១.២. ការពិនិត្យលើពាក្យបណ្តឹង....៣១
១.២.២. ដំណើរការនៃនីតិវិធី....៣២
១.២.៣. ការវិនិច្ឆ័យសេចក្តី....៣៣
**កថាខណ្ឌទី២ អានុភាពក្រោយការរំលាយអនីតិសង្វាស....៣៤**
២.១. អានុភាពរវាងអនីតិសង្វាសជន....៣៤
២.២. ការសម្រេចអំពីអ្នកមានអំណាចមេបាចំពោះកូន....៣៤
២.៣. សិទ្ធិ និងកាតព្វកិច្ចរបស់ឪពុកម្តាយដែលមិនរស់នៅជាមួយកូន....៣៥
២.៤.១. ទ្រព្យជាកម្មសិទ្ធិអវិភាគ....៣៦
២.៤.២. សេចក្តីចម្រើនឥតហេតុ....៣៦
២.៤.៣. ករណីមានកិច្ចសន្យាក្រុមហ៊ុន....៣៧

# ជំពូកទី៣
# ការអនុវត្តសិទ្ធិរបស់អនីតិសង្វាស

**ផ្នែកទី១ សិទ្ធិដែលអនីតិសង្វាសទទួលបាន....៣៩**
១.១. ការចុះសំបុត្រកំណើតកូនរបស់អនីតិសង្វាស....៣៩
១.២. អំពីការគ្រប់គ្រងទ្រព្យសម្បត្តិអនីតិសង្វាស....៣៩
១.៣. អំពីកម្មសិទ្ធិអវិភាគ....៤០
១.៤. អំពីសន្តតិកម្ម....៤០
១.៤.១. សិទ្ធិទទួលបានទ្រព្យសម្បត្តិដោយសន្តតិកម្មនៃអនីតិសង្វាស....៤០
១.៤.២. ការទទួលបានទ្រព្យសម្បត្តិនៃសន្តតិកម្ម....៤១

**ផ្នែកទី២ សិទ្ធិដែលអនីតិសង្វាសមិនទទួលបាន** ........................................................ ៤១

២.១. អំពីភេទ........................................................................................................ ៤១

២.២. អំពីទំនាក់ទំនងញាតិ.........................................................................................៤២

២.៣. អំពីទ្រព្យអកម្មរបស់អនីតិសង្វាស (បំណុល) ..........................................................៤២

២.៤. បណ្ដឹងផ្ដាច់អនីតិសង្វាស.....................................................................................៤៣

**សេចក្ដីសន្និដ្ឋាន** ............................................................................................ ៤៤

**អនុសាសន៍** ................................................................................................... ៤៦

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅសង្គមកម្ពុជាបច្ចុប្បន្នជាទស្សនៈរបស់ប្រជាពលរដ្ឋមួយចំនួនយល់ឃើញថា ការប្រារព្ធនូវពិធីរៀបអាពាហ៍ពិពាហ៍ ឬរៀបចំពិធីសែនព្រេនតាមប្រពៃណីទំនៀមទម្លាប់ ហើយរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធ ដោយគ្មានការចុះបញ្ជីអាពាហ៍ពិពាហ៍ គឺជាប្តីប្រពន្ធស្របតាមច្បាប់ហើយ។ ចំពោះការយល់ឃើញ ក៏ដូចជាការអនុវត្តបែបនេះ គឺមិនត្រឹមត្រូវតាមច្បាប់នោះទេ ពីព្រោះថា ប្តីប្រពន្ធដែលស្របច្បាប់ គឺបុរស និងនារី ដែលបានគោរព និងអនុវត្តនូវលក្ខខណ្ឌតាមច្បាប់ ដោយការចុះបញ្ជីអាពាហ៍ពិពាហ៍ ឬគេស្គាល់ជាទូទៅថាជាអេតាស៊ីវិល នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ ក្នុងន័យនេះ ច្បាប់ទទួលស្គាល់ប្តីប្រពន្ធស្របច្បាប់ដែលបានចុះបញ្ជីអាពាហ៍-ពិពាហ៍ប៉ុណ្ណោះ។ នៅពេលដែលអាពាហ៍ពិពាហ៍មិនបានបំពេញតាមលក្ខខណ្ឌច្បាប់ អាពាហ៍ពិពាហ៍ស្របច្បាប់មិនបានកើតឡើងទេ ក៏ប៉ុន្តែអាពាហ៍ពិពាហ៍លក្ខណៈជាក់ស្តែង ទៅតាមប្រពៃណី ទំនៀមទម្លាប់នៃសង្គមបានកើតឡើង ហៅថាអនីតិសង្វាស។ អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន។ កិច្ចសន្យាដ៏ឱឡារិកសំដៅលើ ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ(ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ពិពាហ៍) ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិល នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ ចំណែកឯការរួមរស់នៅជាមួយគ្នាដោយមិនបានបំពេញតាមលក្ខខណ្ឌនៃអាពាហ៍ពិពាហ៍ដោយការចុះបញ្ជីអាពាហ៍ពិពាហ៍ហៅថា អនីតិសង្វាស។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការរស់នៅក្នុងភាពជាអនីតិសង្វាសមានផលលំបាកជាច្រើន នៅពេលដែលមានទំនាស់កើតឡើងរវាងអនីតិសង្វាសជនដែលច្បាប់ពិបាកនឹងការពារជនរងគ្រោះ។ ដូចនេះយើងនឹងសិក្សាលម្អិតពីនីតិវិធី និងចំណុចជាបញ្ហាមួយចំនួនដូចជា ការបង្កើតនិងការរំលាយអនីតិសង្វាស ផលវិបាកក្នុងអំឡុងពេលមានចំណង អនីតិសង្វាស ការបែងចែកទ្រព្យសម្បត្តិនិងអំណាចមេបាទៅលើកូនក្រោយមានការផ្តាច់សមគ្គសង្វាស។

ដើម្បីឆ្លើយតបទៅនឹងដំណោះស្រាយនៃបញ្ហាខាងលើនេះឱ្យបានក្បោះក្បាយនោះ យើងខ្ញុំបានបង្កើតជាចំណោទបញ្ហាចំនួន៤គឺ៖

- តើអនីតិសង្វាសមានអត្ថន័យដូចម្តេច ហើយមូលហេតុអ្វីដែលនាំឱ្យមានអត្ថិភាពនៃអនីតិសង្វាស?
- តើការបង្កើត និងរំលាយចំណងអនីតិសង្វាសត្រូវអនុវត្តយ៉ាងដូចម្តេច?
- តើអនីតិសង្វាសបង្កើតទំនាក់ទំនងញាតិដែរឬទេ?
- ក្រោយការរំលាយអនីតិសង្វាស តើទ្រព្យសម្បត្តិអនីតិសង្វាសត្រូវអនុវត្តយ៉ាងដូចម្តេច?

## ៣. គោលបំណងនៃកិច្ចការស្រាវជ្រាវ

ការសិក្សាលើប្រធានបទ អនីតិសង្វាសនៅកម្ពុជា មានគោលបំណងក្នុងការស្វែងយល់ពីការអនុវត្តរបប អនីតិសង្វាសក្នុងសង្គមជាក់ស្តែង ដើម្បីធានាឱ្យបាននូវសន្តិសុខគតិយុត្តល្អមួយនៅក្នុងសង្គមគ្រួសារខ្មែរ ពោល គឺចៀសវាងការកើតមានវិវាទរវាងអនីតិសង្វាសជន។

ម៉្យាងទៀត ការសិក្សាស្រាវជ្រាវនេះគឺផ្តោតសំខាន់ទៅលើរបបអនីតិសង្វាសនៅកម្ពុជា និងមានគោល បំណងជាក់លាក់ដូចជា៖

- ស្វែងយល់ពីទិដ្ឋភាពទូទៅនៃអនីតិសង្វាស
- មូលហេតុនាំឱ្យមានអត្ថិភាពនៃអនីតសង្វាស
- ការបង្កើត និងការរំលាយអនីតិសង្វាស
- ទំនាក់ទំនងញាតិ និងទ្រព្យសម្បត្តិរវាងអនីតិសង្វាស
- នីតិវិធីនៃការដោះស្រាយជម្លោះក្នុងប្រព័ន្ធតុលាការក្នុងរឿងការរំលាយអនីតិសង្វាស។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺសិក្សាតែលើរបបអនីតិសង្វាសនៅក្នុងសង្គមកម្ពុជា។ ចំណែកឯដែនកំណត់នៃ ការស្រាវជ្រាវវិញ គឺផ្តោតសំខាន់ទៅលើអនីតិសង្វាសរវាងបុរសនារី និងភេទដូចគ្នា ព្រមទាំងធ្វើការបកស្រាយ អំពីអានុភាពក្នុងអំឡុងពេលរួមអនីតិសង្វាស និងក្រោយការរំលាយអនីតិសង្វាសប៉ុណ្ណោះ។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

យើងខ្ញុំសង្ឃឹមថាសារណាស្តីពី អនីតិសង្វាសនៅកម្ពុជា នេះ នឹងចូលរួមចំណែកផ្តល់នូវពុទ្ធិពិតប្រាកដ មួយអំពីលទ្ធិក្នុងសង្គមគ្រួសារខ្មែរ និងបញ្ហាកង្វះការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋ និងការផ្សព្វផ្សាយ ឱ្យទូលាយទាក់ទងនិងផលវិបាកនៃអនីតិសង្វាសនេះ និងវិវាទផ្លូវច្បាប់នានានៅពេលមានបណ្តឹងសុំរំលាយ អនីតិសង្វាសទៅតុលាការជាដើម ហើយជាពិសេសនឹងក្លាយជាឯកសារបន្ថែមសម្រាប់កិច្ចការស្រាវជ្រាវ ក្រោយៗ ពាក់ព័ន្ធនឹងប្រធានបទអនីតិសង្វាសនេះ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ប្រធានបទខាងលើនេះ យើងខ្ញុំបានខិតខំស្រាវជ្រាវ ដើម្បីប្រមូលនូវឯកសារមួយចំនួន ដូចជា បទបញ្ញត្តិ ច្បាប់ លិខិតបទដ្ឋានគិតិយុត្ត របាយការណ៍ អត្ថបទសិក្សា សៀវភៅសិក្សា ការបកស្រាយរបស់វាគ្មិនតាមបណ្តាញ អ៊ីនធឺណេតផ្សេងៗ និងការសង្កេតជាក់ស្តែងក្នុងសង្គមកម្ពុជា។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងសារណានេះ យើងខ្ញុំបានធ្វើការបែងចែកជា ០៣ ជំពូកគឺ ទិដ្ឋភាពទូទៅនៃអនីតិសង្វាស (ជំពូកទី១) ការបង្កើត និងការរំលាយអនីតិសង្វាស (ជំពូកទី២) និង ការអនុវត្តសិទ្ធិរបស់អនីតិសង្វាស (ជំពូកទី៣)។ ក្រៅពីនេះ ក្នុងសារណាក៏បានរំលេចនូវ សេចក្តីផ្តើមនៅទំព័រដំបូង ហើយនូវទំព័រចុងក្រោយនៃសារណា គឺ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ព្រមទាំងបានភ្ជាប់នូវឯកសារយោង និងឧបសម្ព័ន្ធផងដែរ។

# ជំពូកទី១

# ទិដ្ឋភាពទូទៅនៃអនីតិសង្វាស

# ជំពូកទី១
# ទិដ្ឋភាពទូទៅនៃអនីតិសង្វាស

## ផ្នែកទី១ សញ្ញាណទូទៅនៃអនីតិសង្វាស

### ១.១. ទស្សនៈទាននៃអនីតិសង្វាសនៅកម្ពុជា

យើងបានដឹងហើយថា ប្រទេសកម្ពុជាយើងត្រូវបានបង្កើតឡើង និងមានអរិយធម៌របស់ខ្លួនជាយូរលង់មកហើយ។ ប្រជាជនកម្ពុជាបានអនុវត្តតាម ប្រពៃណី ទំនៀមទម្លាប់ របស់ខ្លួនតាំងពីបុរាណកាលមកម្លេះ។ ក្នុងនោះយើងឃើញថា ការរៀបអាពាហ៍ពិពាហ៍រវាងបុរសនារី ក៏ត្រូវបានអនុវត្តតាមប្រពៃណី ទំនៀមទម្លាប់ផងដែរ។ ក្រោយមក នៅក្នុងឆ្នាំ១៨៦៣ ប្រទេសកម្ពុជាបានធ្លាក់ក្នុងអាណានិគមនិយមបារាំង ហើយក្នុងអាណានិគមនេះបារាំងបាននាំមកដល់កម្ពុជានូវច្បាប់ទំនើបបែបបច្ចិមប្រទេស ដូចជាក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ជាដើម។ ក្រោយពីទទួលបានឯករាជនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ កម្ពុជាបានប្រកាន់យកក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ មកអនុវត្តសម្រាប់គ្រប់គ្រងទំនាក់ទំនងផ្នែកឯកជន រហូតដល់ឆ្នាំ១៩៧៥ របបកម្ពុជាប្រជាធិបតេយ្យបានលេចឡើងមកជាពេលដែលវិស័យច្បាប់នៅកម្ពុជាលែងមានអត្ថិភាព។ ខ្មែរក្រហមបានកាប់សម្លាប់ប្រជាជន និងបង្ខំឱ្យធ្វើការឥតត្រាប្រណី ជាងនេះទៅទៀត របបនេះបានចាប់បង្ខំឱ្យប្រជាជនរៀបការ បើទោះបីជាមានការស្ម័គ្រចិត្ត ឬគ្មានក៏ដោយ។ បន្ទាប់ពីរបបកម្ពុជាប្រជាធិតេយ្យបានដួលរំលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាបានត្រឹមប្រកាន់ខ្ជាប់នូវប្រពៃណីទំនៀមទម្លាប់ទាក់ទង់នឹងអាពាហ៍ពិពាហ៍បានល្អ ប៉ុន្តែការយល់ដឹងរបស់ប្រជាពលរដ្ឋពាក់ព័ន្ធទៅនឹងអាពាហ៍ពិពាហ៍ក្នុងទិដ្ឋភាពច្បាប់នៅមានកម្រិត បើទោះបីជាច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៨៩ ដែលកំណត់ពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ក៏ដោយ។ ម្យ៉ាងទៀតច្បាប់នេះក៏មិនអាចអនុវត្តបាន ដោយសារអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានទើបតែបង្កើតឡើងនៅឆ្នាំ២០០០។[1] មកដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ទើបយើងមានវិធានគតិយុត្តថ្មីដែលជាច្បាប់សារជាតុគ្រប់គ្រងទ្រព្យសម្បត្តិ និង ទំនាក់ទំនងញាតិ តាមរយៈច្បាប់ស្តីពីការដាក់ឱ្យអនុវត្តក្រមរដ្ឋប្បវេណី។ ទន្ទឹមនឹងនេះដែរបញ្ហាគតិយុត្តមួយចំនួននៅតែចោទជាបញ្ហាធ្ងន់ធ្ងរនៅក្នុងការអនុវត្ត។ បើទោះជាមាន វិធានស្តីពីការគ្របគ្រងអាពាហ៍ពិពាហ៍ក្តី អត្ថិភាពនៃអនីតិសង្វាសនៅតែបងន្តកើតមានជាហូហែនៅក្នុងសង្គមកម្ពុជា។ បញ្ហាធំ គឺការមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ហើយការមិនចុះសំបុត្រអាពាហ៍ពិពាហ៍នេះឯងហៅថា អនីតិសង្វាស។ ម្យ៉ាងទៀត ប្រជាជនកម្ពុជាមួយចំនួននៅតែបន្តជ្រើសរើសយកការរស់នៅបែបអនីតិសង្វាសដោយបដិសេធវត្តមាននៃវិធានគតិយុត្ត។

តើអនីតិសង្វាស មានអត្ថន័យបែបណាទៅ? យើងនឹធ្វើការបកស្រាយនៅក្នុង ចំណុច១.២ (និយមន័យ) ខាងក្រោម។

---

[1] ចក សម្បត្តិ, «អនីតិសង្វាស» (ភ្នំពេញ,២០១៤), ទំព័រទី ១-២។

### ១.២. និយមន័យ

អនីតិសង្វាស គឺជាទំនាក់ទំនងរវាងបុរសនារី ដែលរួមរស់ជាមួយគ្នាដូចជាប្ដីប្រពន្ធ ប៉ុន្តែពុំបានអនុវត្តតាម បញ្ញត្តិមាត្រា ៩៥៥ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជាទេ ពោលគឺពុំមានការចុះបញ្ជី អាពាហ៍ពិពាហ៍តាមទម្រង់ច្បាប់ទេ។[2] យោងតាមបញ្ញត្តិមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណីកម្ពុជា បានចែងថា អាពាហ៍ពិពាហ៍នឹងមានអានុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

ចំណែកឯអនីតិសង្វាស ពុំត្រូវបានកំណត់និយមន័យដោយច្បាប់ឡើយ ប៉ុន្តែ ត្រូវបានគេព្យាយាមឱ្យ និយមន័យផ្សេងគ្នាដូចខាងក្រោម៖

- អនីតិសង្វាស គឺជាស្ថានភាពរបស់បុរស និងនារីដែលរួមរស់នៅជាមួយគ្នាដូចជាប្ដីប្រពន្ធមានខាន់ស្លា ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ។[3]
- អនីតិសង្វាស គឺជាទំនាក់ទំនង ដែលមិនត្រូវបានទទួលស្គាល់ជាសហព័ទ្ធ ឬ ប្ដីប្រពន្ធស្របច្បាប់ ប៉ុន្តែ បុគ្គលនោះបានរស់នៅជាមួយគ្នា មានជីវភាពរួមគ្នាដូចប្ដីប្រពន្ធ និងមានឆន្ទៈរៀបអាពាហ៍ពិពាហ៍។[4]

យោងតាមវចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត បានឱ្យនិយមន័យ អនីតិសង្វាស ថា ជាការរស់ នៅជាមួយគ្នាដូចប្ដីប្រពន្ធ តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍។

### ១.៣. មូលហេតុនាំឱ្យមានការរួមរស់ជាអនីតិសង្វាស

ជាការពិតណាស់ ចំណងអនីតិសង្វាសមានអត្ថិភាពនៅក្នុងសង្គមកម្ពុជាជាយូរមកហើយ។ ចំណែកឯ មូលហេតុដែលនាំឱ្យបុរស និងនារីរួមរស់ជាមួយគ្នាតាមបែបអនីតិសង្វាសនៅក្នុងសង្គមកម្ពុជាមានដូជា៖

- ដោយសារតែភាគីម្ខាងនៅមានជាប់ចំណងអាពាហ៍ពិពាហ៍ពីមុន មិនទាន់រំលាយ ឬមិនទាន់ត្រូវ បានលែងលះនៅឡើយ។
- ពេលខ្លះ អាចមកពីស្ថានភាពផ្លូវចិត្តរបស់ភាគីបុរស ឬនារីនោះតែម្ដង ដូចជាការមិនចង់មានចំណង អាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ មិនចង់ប្ដូរត្រកូល ឬចង់មានសេរីភាព ដោយមិនចាំបាច់ប្ដឹងប្ដល់គ្នាដល់ តុលាការ នៅពេលដែលចង់លែងលះ។

---

[2] ខៀវ សុខា, រៀបរៀង « អនីតិសង្វាស និងទិដ្ឋភាពផ្លូវច្បាប់», ទំព័រទី ៣។

[3] សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, *«សទ្ទានុក្រមបារាំង-ខ្មែរនៃពាក្យច្បាប់»*, (ភ្នំពេញ៖ហ្វូណន ឆ្នាំ២០០២), ទំព័រទី ៧៩។

[4] ផៀង សំអាង, រៀបរៀង, «អំពីអនីតិសង្វាស», (ដកស្រង់ទាំងស្រុងចេញពី មេរៀនភាគ២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី សមិទ្ធផលរបស់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ បោះពុម្ពលើកទី១ នៅរាជធានីភ្នំពេញ ខែវិច្ឆិកា ឆ្នាំ២០១៦)៖ ២០២០

- អាចបណ្តាលមកពីកត្តាជីវភាពទ័លក្រ ដែលមិនអាចធ្វើឱ្យពួកគាត់មានលទ្ធភាពចំណាយក្នុងការរៀបចំពិធីអាពាហ៍ពិពាហ៍តាមច្បាប់។
- ពេលខ្លះ អាចមកពីនីតិវិធីក្នុងការចុះសំបុត្រអាពាហ៍ពិពាហ៍ ប្រើពេលយូរ ឬស្មុគស្មាញ ឬភាគីខ្លួនឯងផ្ទាល់ មានការយឺតយ៉ាវក្នុងការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍។
- ពេលខ្លះ អាចមកពីសាមីភាគីមិនយល់អំពីលក្ខខណ្ឌតម្រូវតាមផ្លូវច្បាប់ ដើម្បីឱ្យអាពាហ៍ពិពាហ៍មួយមានសុពលភាព និង អានុភាពតាមច្បាប់ និងសារៈសំខាន់នៃអាពាហ៍ ពិពាហ៍ស្របច្បាប់។
- ពេលខ្លះទៀត ក៏អាចមកពីកត្តាប្រពៃណីទំនៀមទម្លាប់ជាយូរមកហើយរបស់សាមីភាគី ដែលនាំឱ្យពួកគាត់ផ្តល់តម្លៃទៅលើការរៀបចំពិធីសែនព្រេន ឬពិធីរៀបអាពាហ៍ពិពាហ៍ថា មានសារៈសំខាន់ ជាងការចុះសំបុត្រអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ទៅទៀត។[5]

### ១.៣.១. ការមិនគោរពលក្ខខណ្ឌឱឡារិកនៃអាពាហ៍ពិពាហ៍

យោងតាមមាត្រា៣ កថាខណ្ឌទី១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ចែងថា អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្រីម្នាក់ដែលប្តេជ្ញាថា ខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញតាមទំនើងចិត្តរបស់ខ្លួន។ ចំណែកឯ ច្បាប់ស្តីពីឯកពន្ធភាព មាត្រា៣ ចែងថា ចំណងអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្តេជ្ញាចិត្តថារួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន។

ដូច្នេះដើម្បីឱ្យអាពាហ៍ពិពាហ៍ស្របច្បាប់ បុរសនារីត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

#### ១.៣.១.១. លក្ខខណ្ឌគ្រឹះ

- ការព្រមព្រៀង៖ អាពាហ៍ពិពាហ៍ គឺការព្រមព្រៀងដែលកើតចេញពីឆន្ទៈពិតប្រាកដរបស់បុរសស្ត្រី ដើម្បីរួមរស់ជាមួយគ្នា ហើយគ្មានភាគីណាមួយអាចរំលាយអាពាហ៍ពិពាហ៍នេះទៅតាមទំនើងចិត្តបានឡើយ។
- ភេទ៖ ការរៀបអាពាហ៍ពិពាហ៍ ភាគីចាំបាច់ត្រូវតែមានភេទផ្ទុយគ្នា។ ច្បាប់មិនអនុញ្ញាតឱ្យភាគីមានភេទដូចគ្នារៀបអាពាហ៍ពិពាហ៍ឡើយ។[6]
- អាយុ៖ បុរសនារីដែលដល់នីតិភាព ពោលគឺចាប់ពីអាយុ ១៨ឆ្នាំឡើងទៅ អាចរៀបអាពាហ៍ពិពាហ៍បាន។ ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាងបានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនដែល

[5] ខៀវ សុខា, រៀបរៀង « អនីតិសង្វាស និងទិដ្ឋភាពផ្លូវច្បាប់», ទំព័រទី ១។
[6] ច្បាប់ស្តីពីអាពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា ៤។

មានអាយុមិនតិចជាង ១៦ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បានដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ។[7]

- នៅលីវ៖ ច្បាប់បានទទួលស្គាល់តាមគោលការណ៍ស្មុគ្រចិត្តប្តីមួយប្រពន្ធមួយ ហេតុនេះ បុរសនារីដែលមានបំណងរៀបអាពាហ៍ពិពាហហ៍ត្រូវតែនៅលីវ។[8] ប្រសិនបើភាគីណាមួយកំពុងមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ត្រូវតែបញ្ចប់ចំណងអាពាហពិពាហ៍នោះជាមុនសិន តាមរយៈសេចក្តីសម្រេចរបស់តុលាការ។

**១.៣.១.២. លក្ខខណ្ឌទម្រង់ ឬនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍**

- ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍៖ បុរសនារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាន នៃឃុំសង្កាត់លំនៅដ្ឋានសាមីខ្លួនខាងនារី។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវពិនិត្យឱ្យបានហ្មត់ចត់នូវពាក្យសុំនោះ ដោយផ្អែកទៅលើលក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់។
- ការប្រកាសអាពាហ៍ពិពាហ៍៖ ក្រោយពីបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវហើយ មន្ត្រីអត្រានុកូលដ្ឋាននៃឃុំសង្កាត់ ត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ដើម្បីយកទៅបិទផ្សាយជាសាធារណៈនៅលំនៅដ្ឋាន និងនៅសាលាឃុំសង្កាត់នៃសាមីខ្លួននារី និងនៅមុខលំនៅដ្ឋាន និងសាលាឃុំសង្កាត់សាមីខ្លួនបុរស។ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ត្រូវបិទផ្សាយក្នុងរយៈពេល ១០ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍ ដើម្បីឱ្យជនដែលមានប្រយោជន៍ក្នុងរឿងនេះ អាចប្តឹងជំទាស់នឹងអាពាហ៍-ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ស្របនឹងអាពាហ៍ពិពាហ៍នោះ។
- ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ៈ បន្ទាប់ពីបានបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍បានចំនួន១០ថ្ងៃ ដោយមិនមានការប្តឹងជំទាស់ទេ និងរៀបចំពិធីអាពាហ៍ពិពាហ៍ចប់សព្វគ្រប់ សាមីខ្លួនទាំងពីរត្រូវទៅសាលាឃុំសង្កាត់ ដើម្បីចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអាត្រានុកូលដ្ឋានខាងលំនៅដ្ឋាននារី។ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ត្រូវមានសាក្សីពីរនាក់គ្រប់អាយុការទៅជាមួយដើម្បីបញ្ជាក់ពីការដឹងឮ ឬធ្វើជាសាក្សី។
- ការចុះបញ្ជីអាពាហ៍ពិពាហ៍៖ បន្ទាប់ពីបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍រួច មន្ត្រីអត្រានុកូលដ្ឋានត្រូវស្រង់ទិន្នន័យភាគីទាំងសងខាង និងចុះសៀវភៅអាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់ឱ្យសាមីខ្លួនប្តីប្រពន្ធនូវសំបុត្រអាពាហ៍ពិពាហ៍ (អេតាស៊ីវិល) ច្បាប់ដើម និងចេញសេចក្តីចម្លងតាមការស្នើ

---

[7] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៤៨។

[8] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៣ កញ្ញា ១៩៩៣, មាត្រា ៤៥ កថាខណ្ឌទី៤។

សុំរបស់សាមីខ្លួនដើម្បីទុកប្រើប្រាស់។[9]

ផ្ទុយទៅវិញ នៅពេលដែលអាពាហ៍ពិពាហ៍មិនបានគោរពទៅតាមការកំណត់របស់ច្បាប់ ឬបានគោរពទៅតាមលក្ខខណ្ឌសារធាតុនៃអាពាហ៍ពិពាហ៍ មិនបានចុះបញ្ជីអាពាហ៍ពិពាហ៍នោះ អាពាហ៍ពិពាហ៍ស្របច្បាប់មិនបានកើតឡើងនោះទេ ករណីនេះត្រូវបានស្គាល់ថាជា អនីតិសង្វាស (សមគ្គសង្វាសតាមព្រឹត្តន័យ)។ ក្នុងករណីផ្សេងទៀត អនីតិសង្វាសក៏អាចត្រូវបានកើតឡើងតាមរយៈ ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីដោយគ្មានការចុះបញ្ជីអាពាហ៍ពិពាហ៍ផងដែរ។

បើពិនិត្យទៅលើ កថាខណ្ឌទី២ មាត្រា៩៥៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មូលហេតុមួយចំនួនដែលនាំឱ្យអាពាហ៍ពិពាហ៍ត្រូវបានចាត់ទុកជាមោឃៈបាន រួមមាន ការមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការមិនបានជូនដំណឹងជាសាធារណៈអំពីអាពាហ៍ពិពាហ៍របស់ខ្លួន ការមិនចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិលនេះឯង។ ក៏ប៉ុន្តែ ទោះបីមិនបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីឬគ្មានក៏ដោយ នៅពេលដែលបុរសនិងនារី បានចុះសំបុត្រអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិលនោះ អនីតិសង្វាសនឹងត្រូវបានបញ្ចប់ ដោយពួកគេនឹងក្លាយជាប្តីប្រពន្ធស្របច្បាប់។

ដូច្នេះហើយ អនីតិសង្វាសក្នុងន័យនេះ កើតឡើងដោយសារការមិនបានគោរពលក្ខខណ្ឌឱឡារិកនៃអាពាហ៍ពិពាហ៍ ឬអវត្តមាននៃការចុះសំបុត្រអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិលនេះឯង។

### ១.៣.២. និយ័តកម្មចំពោះអាពាហ៍ពិពាហ៍មិនបានចុះបញ្ជី

ក្រោយការដួលរលំនៃរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩ មិនទាន់មានវិធានគតិយុត្តសម្រាប់គ្រប់គ្រងពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍នៅឡើយទេ រហូតដល់ឆ្នាំ១៩៨៩ ទើបមានវិធានស្តីពីអាពាហ៍ពិពាណ៍និងគ្រួសារ ត្រូវបានបង្កើតឡើង។ ហើយក្រោយមក ការបង្កើតវិធានគតិយុត្តស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារនេះ ក៏បានបង្កជាបញ្ហាគតិយុត្តមួយចំនួនផងដែរ។ ដោយហេតុថា ការងារនៃការចុះបញ្ជីអត្រានុកូលដ្ឋានមិនទាន់ត្រូវបានបង្កើតឡើង ដែលវាតម្រូវទាមទារឱ្យមានការធ្វើនិយ័តកម្មនៃអាពាហ៍ពិពាហ៍ដែលមិនបានចុះបញ្ជី។

ដើម្បីដោះស្រាយបញ្ហាខាងលើនេះ រាជរដ្ឋាភិបាលបានចេញនូវអនុក្រឹត្យចំនួន ៥ ចាប់តាំងពីឆ្នាំ២០០០ មក ក្នុងគោលដៅចម្បងកំណត់បែបបទ និងនីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាន។ សំបុត្រអត្រានុកូលដ្ឋានរួមមាន សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព។ ការចុះសំបុត្រអត្រានុកូលដ្ឋាន គឺជារឿងសំខាន់ ដោយសារវាជាបង្កើតចំណងរួមភ្ជាប់សញ្ជាតិរបស់បុគ្គលទៅនឹងរដ្ឋ ព្រមទាំងបង្កើតជាសិទ្ធិ និង

[9] ប្រធានបទស្តីពី «អាពាហ៍ពិពាហ៍ស្របច្បាប់»រៀបរៀងដោយៈ លោកមេធាវី ម៉េង វណ្ណី និងលោក ប៊ុន វិទូ ជំនួយការមេធាវី និងជាសមាជិកក្រុមការងាររៀបចំ និងផ្សព្វផ្សាយអត្ថបទច្បាប់ នៃក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ

ករណីយកិច្ចដល់បុគ្គលក្នុងគ្រួសារ និងសង្គម។[10] ម្យ៉ាងទៀត ការសុំចុះបញ្ជីអត្រានុកូលដ្ឋានជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូបផងដែរ។[11] ពលរដ្ឋខ្មែរដែលបានគ្នាជាប្តីប្រពន្ធពិតប្រាកដនៅមុនពេលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានចូលជាធរមាន ប្រសិនបើ ប្តីប្រពន្ធគ្មានសំបុត្រអាពាហ៍ពិពាហ៍ ប្តីប្រពន្ធនោះ អាចមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បាននៅតាមសាលាឃុំសង្កាត់ ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីពីររូបជានីតិជន ឬអ្នកដែលគួរឱ្យទុកចិត្តបានដែលបានដឹងឮផ្ទាល់ពីសាមីខ្លួនផ្ទាល់ថាជាប្តីប្រពន្ធ និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬសង្កាត់ជាមួយគ្នា នាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។[12] ហើយការសុំចុះបញ្ជីនេះអនុវត្តតែក្នុងរយៈពេល ៣ឆ្នាំ ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមានប៉ុណ្ណោះ។[13] ពោលគឺចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥។ សម្រាប់ឆ្នាំ២០០២ សៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទត្រូវអនុញ្ញាតឱ្យបើកប្រើប្រាស់ចាប់ពីថ្ងៃទី០១ ខែសីហា ហើយត្រូវបញ្ឈប់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០២។[14] ប៉ុន្តែក្រោយមក មានការពន្យាពេលនៃការចុះបញ្ជីអត្រានុកូលដ្ឋាន ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៦ វិញ។[15]

អនុក្រឹត្យដែលបានរៀបរាប់ខាងលើនេះ ទទួលស្គាល់អាពាហ៍ពិពាហ៍ដែលមិនបានចុះបញ្ជី ដែលវាហាក់បំពានទៅលើមាត្រា ៣ និង មាត្រា ១៤ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារឆ្នាំ១៩៨៩ ដែលកំណត់ពីគោលការណ៍ឱឡារិកភាពនៃអាពាហ៍ពិពាហ៍ដែលមានការចុះបញ្ជី ឬមិនបានគោរពឋានានុក្រមនៃនីតិ។[16]

លើសពីនេះទៅទៀត ក្នុងគោលដៅដើម្បីធ្វើឱ្យអនីតិសង្វាសក្លាយទៅជាអាពាហ៍ពិពាហ៍ស្របច្បាប់នោះក្រសួងមហាផ្ទៃក៏បានចេញ សេចក្តីណែនាំលេខ ០០៨ សណន នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការចុះសៀវភៅអត្រានុកូលដ្ឋាន ឱ្យមាននិរន្តរភាពក្រោយបញ្ចប់យុទ្ធនាការចុះបញ្ជីអត្រានុកូលដ្ឋានកន្លងមក។ សេចក្តីណែនាំនេះអនុញ្ញាតឱ្យអ្នកដែលរស់នៅជាមួយគ្នា ដូចជាប្តីប្រពន្ធ ឬបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី តែមិនទាន់មានសំបុត្រអាពាហ៍ពិពាហ៍ ត្រូវប្តឹងសុំចុះបញ្ជីអាពាហ៍ពិពាហ៍នៅឃុំសង្កាត់របស់ខ្លួន។ ដើម្បីទទួលបាននូវសំបុត្រអាពាហ៍ពិពាហ៍ ប្តីប្រពន្ធអនីតិសង្វាសទាំងពីរត្រូវមានលិខិតស្នាមផ្សេងៗ ដូចជា ពាក្យសុំរៀបអាពាហ៍-ពិពាហ៍ លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ពោះម៉ាយ សេចក្តីចម្លងសំបុត្រកំណើត (បើមាន) ឬសៀវភៅគ្រួសារ

---

[10] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ១០៣ អនក្រ.បក, ២៩ ធ្នូ ២០០០, មាត្រា ២។

[11] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ១០៣ អនក្រ.បក, ២៩ ធ្នូ ២០០០, មាត្រា ៣។

[12] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ១០៣ អនក្រ.បក, ២៩ ធ្នូ ២០០០, មាត្រា ៤៥។

[13] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ១០៣ អនក្រ.បក, ២៩ ធ្នូ ២០០០, មាត្រា ៥៩។

[14] អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា៨ និងមាត្រា៥៩ នៃអនុក្រឹត្យលេខ១០៣, លេខ៦០ អនក្រ.បក, ២៤ មិថុនា ២០០០, មាត្រា ៥៩។

[15] អនុក្រឹត្យស្តីពីការកែសម្រួលចំណុច ក និងចំណុច ខ នៃមាត្រា៥៩ថ្មីស្ទួន នៃអនុក្រឹត្យលេខ១៧, លេខ១០៦ អនក្រ.បក, ២៣ សីហា ២០០៥, មាត្រា ៥៩ថ្មីស្ទួន។

[16] ចក សម្បត្តិ, អនីតិសង្វាស (ភ្នំពេញ,២០១៤), ទំព័រទី ៨-១២

(បើមាន) ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (បើមាន)។ និយាយឱ្យខ្លី ត្រូវបំពេញសំណុំបែបបទ និងដំណើរការទៅដូចជានីតិវិធីដែលប្តីប្រពន្ធរៀបអាពាហ៍ពិពាហ៍ថ្មីថ្មោងដូច្នេះដែរ។[17]

## ផ្នែកទី២ លក្ខណៈនីតិសង្វាសធៀបនិងអនីតិសង្វាស

### ២.១. អត្ថន័យនីតិសង្វាស

នីតិសង្វាស គឺជាការរួមរស់នៅជាមួយគ្នាជាប្តី ប្រពន្ធដោយបានបំពេញទៅតាមលក្ខខណ្ឌច្បាប់កំណត់។ នីតិសង្វាស ឬអាពាហ៍ពិពាហ៍ស្រប់ច្បាប់ ត្រូវបានកំណត់ក្នុង មាត្រា ៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហហ៍និងគ្រួសារឆ្នាំ១៩៨៩ និងមាត្រា ៣ នៃច្បាប់ស្តីពីឯកពន្ធភាពឆ្នាំ២០០៦ បានបញ្ញត្តិថា អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន។

### ២.២. ការធៀបនីតិសង្វាស និងអនីតិសង្វាស

#### ២.២.១. នីតិសង្វាស

- បង្កើតអានុភាពនៃអាពាហ៍ពិពាហ៍ស្របច្បាប់៖ ការចុះសំបុត្រអាពាហ៍ពិពាហ៍បង្កើតអានុភាពអាពាហ៍ពិពាហ៍ស្របច្បាប់ដែលនាំឱ្យកើតឡើងនូវសិទ្ធិ និងករណីយកិច្ចរវាងប្តីប្រពន្ធ ដូចជា ប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា សហការគ្នា និងសង្គ្រោះគ្នាទៅវិញទៅមក សិទ្ធិក្នុងការប្រើប្រាស់នាមត្រកូល ឬសោហ៊ុយអាពាហ៍ពិពាហ៍ (សោហ៊ុយចំណាយផ្សេងៗសម្រាប់ជីវភាពគ្រួសារដូចជាការហូបចុក ការស្នាក់នៅ ស្លៀកពាក់ សុខភាព) ជាដើម។[18]
- បង្កើតនូវទំនាក់ទំនងញាតិ និងទំនាក់ទំនងឪពុកម្តាយនិងកូន៖ ប្តីប្រពន្ធ ត្រូវក្លាយជាញាតិនឹងគ្នា (ញាតិតាមចំណងអាពាហ៍ពិពាហ៍) ហើយវាក៏ពង្រីកវិសាលភាពដល់ញាតិរបស់ប្រពន្ធ និងញាតិរបស់ប្តីតាមទំហំដែលច្បាប់បានកំណត់ (ញាតិពន្ធក្នុង ៣ថ្នាក់) ហៅថា ញាតិពន្ធ ឬសាច់ថ្លៃ។ អាពាហ៍ពិពាហ៍ស្របច្បាប់មានអានុភាពឱ្យអាចសន្មតភាពជាឪពុករបស់កូន «ទារកនៅក្នុងគភ៌ប្រពន្ធដែលមាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ត្រូវសន្មតថាជាកូនរបស់ប្តី»។[19] អានុភាពនៃអាពាហ៍ពិពាហ៍ក៏បង្កើតឱ្យមានការប្រើប្រាស់អំណាចមេបារួមចំពោះកូនជាអនីតិជន ប៉ុន្តែប្រសិនបើបុរសនិងនារីមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ អ្នកដែលមានអំណាចមេបាចំពោះកូនគឺ ម្តាយ (អំណាចមេបាទោល)។

---

[17] ចក សម្បត្តិ, «អនីតិសង្វាស» (ភ្នំពេញ,២០១៤), ទំព័រទី ១៤-១៦។

[18] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៦៥, ៩៦៦ និង ៩៧១។

[19] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨៨ កថាខណ្ឌទី១។

- ទំនាក់ទំនងទ្រព្យសម្បត្តិ៖ អាពាហ៍ពិពាហ៍ស្របច្បាប់នាំឱ្យកើតឡើងនូវប្រព័ន្ធទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិដែលប្តី ឬប្រពន្ធតែម្ខាង ឬទាំងសងខាងទទួលបានក្នុងពេលមានចំណងអាពាហ៍-ពិពាហ៍។[20] ប្រព័ន្ធនេះបានកំណត់អំពីតុល្យភាពនៃសិទ្ធិ និងករណីយកិច្ចទាំងនៅក្នុងពេលដែលប្តីប្រពន្ធត្រូវរ៉ូវគ្នានិងពេលលែងលះ មានន័យថា ប្តីប្រពន្ធមានសិទ្ធិស្មើគ្នាក្នុងការទទួលផលប្រយោជន៍ពីការប្រើប្រាស់ និងគ្រប់គ្រងទ្រព្យសម្បត្តិរួម។ ការចាត់ចែងទ្រព្យសម្បត្តិរួមត្រូវការ ការឯកភាពគ្នាពីប្តីនិងប្រពន្ធ ហើយនៅពេលដែលពួកគេរស់នៅមិនចុះសម្រុងគ្នាឈានដល់ការលែងលះ ទ្រព្យសម្បត្តិរួម ត្រូវធ្វើការបែងចែកដោយយុត្តិធម៌រវាងប្តីប្រពន្ធ។
- ការទាមទារសំណង៖ ប្តីប្រពន្ធស្របច្បាប់(សហព័ទ្ធ) មានសិទ្ធិទាមទារសំណងនៃការខូចខាតសតិអារម្មណ៍ ផ្អែកលើអំពើអនីត្យានុកូលពីជនបង្ក ក្នុងករណីដែលសហព័ទ្ធបានទទួលមរណភាព (ការស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ជាដើម) ពោលគឺជាការទាមទារនូវការខូចខាតដែលខ្លួនបានទទួលដោយសារការស្លាប់របស់ប្តី ឬប្រពន្ធណាម្ខាង បន្ថែមពីលើសំណងការខូចខាតដែលកើតឡើងចំពោះជនរងគ្រោះដោយផ្ទាល់។ មួយវិញទៀត នៅក្នុងករណីប្តី ឬប្រពន្ធ បានប្រព្រឹត្តអំពើអនីត្យានុកូលចំពោះប្តីឬប្រពន្ធម្ខាង ប្តីឬប្រពន្ធម្ខាងទៀត អាចទាមទារសំណងនៃការខូចខាតទាំងផ្នែកសម្ភារៈ និងផ្លូវចិត្ត។
- ឋានៈក្នុងការទទួលមត៌ក៖ អាពាហ៍ពិពាហ៍ស្របច្បាប់ នាំឱ្យប្តីប្រពន្ធក្លាយជាញាតិនឹងគ្នា ហើយក្នុងករណីដែលប្តី ឬប្រពន្ធណាម្ខាងបានទទួលមរណភាព ប្តី ឬប្រពន្ធដែលនៅរស់នឹងក្លាយជាអ្នកទទួលមត៌កក្នុងនាមជាសន្តតិជនជានិច្ច។[21]
- ការទទួលបានអត្តាធីនភាព៖ ករណីដែលអនីតិជនមិនទាន់ដល់នីតិភាពរៀបអាពាហ៍ពិពាហ៍បានរៀបអាពាហ៍ពិពាហ៍ជាមួយនីតិជនម្ខាងទៀតតាមបញ្ញត្តិមាត្រា ៩៤៨ វាក្យខណ្ឌ២ អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលបានអត្តាធីនភាពដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ។[22]
- ការទទួលបានការការពារផ្សេងទៀត៖ ប្តីប្រពន្ធដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ នឹងទទួលបានការការពារតាមផ្លូវច្បាប់ជាច្រើន ពោលគឺមានច្បាប់ដែលគ្រប់គ្រងទំនាក់ទំនងពួកគេ ដូចជាក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីឯកពន្ធភាព និងច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ជាអាទិ៍។ ឧបមាថា

[20] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៣។

[21] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦១ កថាខណ្ឌទី១។

[22] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ២១ កថាខណ្ឌទី២។

ប្រសិនបើ ប្តីប្រពន្ធចុះសំបុត្រអាពាហ៍ពិពាហ៍ ហើយប្តីទៅមានដៃគូនៅខាងក្រៅ (លួចមានស្រី) ប្រពន្ធអាចទាមទារលែងលះដោយមូលហេតុ ផិត (តាមក្រមរដ្ឋប្បវេណី) ឬអាចប្តឹងប្តីពីបទផិត ឬទ្វេពន្ធភាពបាន (តាមច្បាប់ស្តីពីឯកពន្ធភាព)។ ប៉ុន្តែប្រសិនបើយើងក្រឡេកមកមើល ទំនាក់ទំនងប្តីប្រពន្ធដែលមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ឬទំនាក់ទំនងអនីតិសង្វាសវិញ ច្បាប់មិនបានការពារនូវទំនាក់ទំនងពួកគេនោះទេ លើកលែងតែករណីមួយចំនួនដូចជា ករណីដែលប៉ះពាល់ផលប្រយោជន៍ដល់កុមារដែលកើតចេញពីឪពុកម្តាយ ដែលគ្មានចំណងអាពាហ៍ពិពាហ៍។ ដូចករណីខាងលើនេះ ប្រសិនបើប្តីប្រពន្ធមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍វិញ ប្រពន្ធមិនអាចប្តឹងប្តីពីបទផិត ឬបទទ្វេពន្ធភាពបានទេ។

**២.២.២. អនីតិសង្វាស**

- ទំនាក់ទំនងរវាងប្តីប្រពន្ធ៖ ទំនាក់ទំនងរវាងប្តីនិងប្រពន្ធ ប្រឈមទៅនឹងការបាត់បង់ ឬត្រូវបានរំលាយគ្រប់ពេលវេលា ដោយមិនឆ្លងកាត់តាមផ្លូវតុលាការ។ នេះហៅថា ទំនាក់ទំនងបង្កើតឡើងដោយសេរី ហើយអាចរំលាយទៅវិញដោយសេរី។
- ចំណូលគ្រួសារ៖ ចំណូលដែលប្តីប្រពន្ធទទួលបានក្នុងអំឡុងពេលរួមរស់ជាមួយគ្នា គឺមិនមែនជាទ្រព្យសម្បត្តិរួមឡើយ តែជាទ្រព្យសម្បត្តិដោយឡែករៀងៗខ្លួន មានន័យថា អ្នកណារកបានអ្នកនោះជាម្ចាស់នៃផលប្រយោជន៍នោះ។
- លក្ខណៈសម្បត្តិជាសន្តតិជន៖ ប្តីប្រពន្ធដែលពុំមានអាពាហ៍ពិពាហ៍ស្របច្បាប់ មិនអាចក្លាយជាទាយាទក្នុងការស្នងមត៌ក នៅពេលដែលភាគីម្ខាងទៀតទទួលមរណភាពឡើយ។ ដើម្បីបញ្ចៀសអំពីបញ្ហានេះ ប្តីឬប្រពន្ធអាចតាក់តែងបណ្តាំមត៌ក ដោយកំណត់អំពីការបែងចែកទ្រព្យសម្បត្តិឱ្យភាគីម្ខាងទៀតបាន មុននឹងខ្លួនទទួលមរណភាព ហើយមត៌កនឹងធ្លាក់ទៅលើប្តីឬប្រពន្ធរបស់ខ្លួននៅពេលដែលខ្លួនទទួលមរណភាព។[23]
- កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ៖ ប្តីប្រពន្ធជាអនីតិសង្វាសជនមិនអាចតាក់តែង និងចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលច្បាប់ទទួលស្គាល់ ដែលមានខ្លឹមសារកំណត់អំពីទ្រព្យសម្បត្តិរួម និងដោយឡែក ឱ្យមានភាពច្បាស់លាស់ស្របទៅតាមឆន្ទៈរបស់ប្តីប្រពន្ធបានឡើយ។ ក៏ប៉ុន្តែប្តីប្រពន្ធអាចធ្វើជាកិច្ចសន្យាឯកជន ដោយកំណត់អំពីការគ្រប់គ្រងទ្រព្យសម្បត្តិបាន។
- ករណីយកិច្ចរួមរស់នៅជាមួយគ្នា៖ ប្តីប្រពន្ធ មិនមានករណីយកិច្ចរួមរស់ជីវភាពជាមួយគ្នាឡើយ។ មានន័យថា ប្តីនិងប្រពន្ធមិនមានចំណងតាមផ្លូវច្បាប់ ដែលតម្រូវឱ្យរួមរស់នៅតែជាមួយគ្នារហូត

[23] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧០-១១៧៥។

នោះទេ។ ក្នុងករណីដែលប្តីឬប្រពន្ធបានរួមសេវនកិច្ចជាមួយអ្នកដទៃក្រៅពីប្តី ឬប្រពន្ធរបស់ខ្លួន (ទំនាក់ទំនងផ្លូវភេទ) ប្តីឬប្រពន្ធនោះមិនត្រូវបានចាត់ទុកថាបានប្រព្រឹត្តបទផិត ដែលឈានទៅដល់ការផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌឡើយ។

- ករណីយកិច្ចសហការៈ ប្តីប្រពន្ធ មិនត្រូវបានតម្រូវឱ្យគ្រប់គ្រងទ្រព្យសម្បត្តិដោយសហការគ្នា ដូចទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធស្របច្បាប់ឡើយ។ មួយវិញទៀត នៅពេលដែលប្តីប្រពន្ធមានកូន សិទ្ធិក្នុងការគ្រប់គ្រងកូន (អំណាចមេបា) ជាគោលការណ៍ត្រូវធ្លាក់លើម្តាយ (អំណាចមេបាទោល) ប៉ុន្តែឪពុកម្តាយអាចពិភាក្សាគ្នាដោយកំណត់ថា ឪពុកមានសិទ្ធិគ្រប់គ្រងកូន។ ចំពោះឪពុកឬម្តាយ ដែលគ្មានសិទ្ធិគ្រប់គ្រងកូន មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងត្រូវផ្គត់ផ្គង់សោហ៊ុយដើម្បីចិញ្ចឹមកូនផងដែរ។ ក្នុងករណីដែលមិនអាចពិភាក្សាគ្នាបាននូវចំណុចដូចបានរៀបរាប់ខាងលើទេ ប្តីឬប្រពន្ធអាចដាក់ពាក្យសុំឱ្យតុលាការសម្រេចបាន។
- ករណីយកិច្ចសង្គ្រោះគ្នាទៅវិញទៅមកៈ ប្រសិនបើប្តី ឬប្រពន្ធមានជីវភាពខ្វះខាត ឬធ្លាក់ក្នុងស្ថានភាពលំបាកខាងផ្នែកហិរញ្ញវត្ថុ នោះប្តីឬប្រពន្ធម្ខាងទៀតមិនត្រូវបានតម្រូវដោយច្បាប់ក្នុងការផ្គត់ផ្គង់ ឬផ្តល់ជាសោហ៊ុយប្រាក់កាសជាដើម ទៅភាគីដែលធ្លាក់ក្នុងស្ថានភាពលំបាកនោះឡើយ (តាមផ្លូវច្បាប់ហៅថា អាហារកាតព្វកិច្ច)។
- សិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ស្របច្បាប់៖ ប្តី ឬប្រពន្ធ អាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយអ្នកដទៃផ្សេងទៀតបានដោយសេរី ដោយពុំមានបទល្មើសព្រហ្មទណ្ឌឡើយ។
- សំណងការខូចខាត(អាហារកិច្ច)៖ នៅពេលបញ្ចប់ទំនាក់ទំនងជាមួយគ្នា ប្តីឬប្រពន្ធដែលគ្មានកំហុស ហើយមានជីវភាពខ្វះខាត មិនទទួលបានសំណងការខូចខាតឡើយ។
- ការទទួលស្គាល់កូន(ការសន្មតបិតុភាព)៖ នៅពេលដែលប្តីប្រពន្ធមានកូន ចំពោះប្តី ដើម្បីក្លាយជាឪពុករបស់កូន ឪពុកត្រូវបង្ហាញឆន្ទៈទទួលស្គាល់កូននោះ។ ក៏ប៉ុន្តែ ប្រសិនបើកូននោះមានឪពុកតាមផ្លូវច្បាប់រួចហើយ ពុំអាចទទួលស្គាល់បានឡើយ[24] (ឪពុកតាមផ្លូវច្បាប់ សំដៅដល់ឪពុកដែលកំពុងស្ថិតនៅក្នុងចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ណាមួយជាអាទិ៍)។ បើកូនមិនទាន់ដល់អាយុ ១៨ឆ្នាំ (អនីតិជន) នោះពុំចាំបាច់ទទួលការយល់ព្រមពីកូន និងម្តាយទេ ប៉ុន្តែ បើកូនចម្រើនវ័យដល់អាយុ ១៨ឆ្នាំ ហើយ (នីតិជន) ចាំបាច់ត្រូវទទួលការយល់ព្រមពីកូននោះ។[25]

[24] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៩៣។

[25] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៩៥ និង ៩៩៦ កថាខណ្ឌទី១។

- ការបែងចែកទ្រព្យសម្បត្តិ៖ ប្តី ឬប្រពន្ធអាចមានបញ្ហាបែងចែកទ្រព្យសម្បត្តិនៅពេលបញ្ចប់ទំនាក់ទំនងជាមួយគ្នា ជាពិសេសចំពោះទ្រព្យសម្បត្តិណាដែលពុំមានឈ្មោះប្តីឬប្រពន្ធជាម្ចាស់ទ្រព្យ។
- បំណុល៖ ប្រសិនបើ ប្តីឬប្រពន្ធខ្ចីបំណុលអ្នកដទៃ ដើម្បីយកមកប្រើប្រាស់ក្នុងជីវភាពគ្រួសារ ដូចជាការព្យាបាលការថែទាំកូន ឬការគ្រប់គ្រងទ្រព្យសម្បត្តិ ប្តីឬប្រពន្ធនោះគឺជាអ្នកទទួលបន្ទុកតែម្នាក់ឯង លើកលែងតែការខ្ចីបំណុលនោះដាក់ឈ្មោះប្តី និងប្រពន្ធជាអ្នកខ្ចី ឬប្តី ឬប្រពន្ធម្ខាងទៀតបានទទួលស្គាល់បំណុលដែរ។
- ការលួចទ្រព្យសម្បត្តិ៖ ប្រសិនបើ ប្តីឬប្រពន្ធបានលួចទ្រព្យសម្បត្តិប្តីឬប្រពន្ធម្ខាងទៀត ប្តីឬប្រពន្ធនោះត្រូវជាប់ទោសពី បទលួច ដោយពុំទទួលបាននូវអភ័យឯកសិទ្ធិគ្រួសារឡើយ។ អភ័យឯកសិទ្ធិគ្រួសារ សំដៅដល់ការរួចផុតពីការជាប់ទោស ប្រសិនបើលួចទ្រព្យសម្បត្តិរបស់ញាតិ ឬរបស់ប្តីប្រពន្ធស្របច្បាប់។
- ទំនាក់ទំនងញាតិ៖ ទំនាក់ទំនងញាតិតាមផ្លូវច្បាប់ ពុំត្រូវបង្កើតឡើងឡើយចំពោះប្តីប្រពន្ធដែលរួមរស់នៅជាមួយគ្នាហើយមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍។
- ការចាត់ទុកថាបានចម្រើនវ័យ១៨ឆ្នាំ(អត្តាធីនភាព)៖ ប្តី ឬប្រពន្ធដែលមានអាយុ ១៦ឆ្នាំ ហើយដែលបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ឬបានរួមរស់នៅជាមួយគ្នាដូចជាប្តីប្រពន្ធ ប៉ុន្តែមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិល មិនត្រូវបានចាត់ទុកបានចម្រើនវ័យ ១៨ឆ្នាំ ឡើយ។

# ជំពូកទី២

# ការបង្កើត និងរំលាយអនីតិសង្វាស

# ជំពូកទី២
# ការបង្កើត និងការរំលាយអនីតិសង្វាស

## ផ្នែកទី១ ការបង្កើតអនីតិសង្វាស

### កថាខណ្ឌទី១ លក្ខខណ្ឌសារធាតុនៃការបង្កើតអនីតិសង្វាស

នៅកម្ពុជា អនីតិសង្វាសពុំត្រូវបានកំណត់ពីរបបគតិយុត្តច្បាស់លាស់នោះទេ ក៏ប៉ុន្តែពាក្យ អនីតិសង្វាស ត្រូវបានប្រើក្នុងមាត្រា ២២២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។[26] ក្នុងមាត្រាដដែលនេះ បានចែងពីការដាក់ទណ្ឌកម្មចំពោះការប្រើអំពើហឹង្សាទៅលើអនីតិសង្វាសប៉ុណ្ណោះ ព្រោះថាស្មារតីនៃក្រមនេះ មានគោលដៅដើម្បីដាក់ទណ្ឌចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តិល្មើសព្រហ្មទណ្ឌ។ ការណ៍ដែលមិនបានកំណត់ពីរបបគតិយុត្តនេះ នាំឱ្យមានផលលំបាកក្នុងការកំណត់ពីសញ្ញាណនៃអនីតិសង្វាស។ អនីតិសង្វាស ផ្ទុយពីនីតិសង្វាសដែលបានកំណត់ក្នុងវិធានគតិយុត្តច្បាស់លាស់។ ហេតុនេះហើយ ទើបនាំឱ្យមាននត្ថិភាពលក្ខខណ្ឌនៃការបង្កើតអនីតិសង្វាសនៅកម្ពុជា។

ការមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ មិនមែនជាកត្តាសំខាន់តែមួយដែលកំណត់ពីអត្ថិភាពនៃអនីតិសង្វាសនោះទេ តែវាក៏ត្រូវបានកំណត់យ៉ាងសំខាន់ដោយលក្ខខណ្ឌសារធាតុនៃអនីតិសង្វាសផងដែរ។ ដោយសារច្បាប់កម្ពុជាមិនមានការចែងឱ្យច្បាស់លាស់អំពីលក្ខខណ្ឌនៃ អនីតិសង្វាស ឬមិនមានវិធានគតិយុត្តណាមួយកំណត់ពីទំនាក់ទំនងអនីតិសង្វាស យើងនឹងពិនិត្យទៅលើនិយមន័យដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីបារាំង អនីតិសង្វាស ជាសមគ្គសង្វាសតាមព្រឹត្តិន័យ ដែលមានលក្ខណៈជាការរស់នៅរួមគ្នាភ្ជាប់ជាមួយនូវលក្ខខណ្ឌស្ថេរភាព និងនិរន្តរភាព រវាងបុគ្គលពីរនាក់ដែលមានភេទខុសគ្នា ឬដូចគ្នា ហើយរស់នៅជាមួយគ្នាដូចប្តីប្រពន្ធ។ និយមន័យខាងលើនេះ បានកំណត់ពីអត្តសញ្ញាណដែលបង្កើតជាចំណងអនីតិសង្វាស ហើយដោយយោងតាមនិយមន័យនេះ លក្ខខណ្ឌសារធាតុនៃអនីតិសង្វាសអាចត្រូវបានកំណត់ដូចខាងក្រោម។[27]

#### ១.១. ការរួមរស់ជាមួយគ្នា

អនីតិសង្វាសក៏ដូចជាអាពាហ៍ពិពាហ៍ស្របច្បាប់ ដែលមានការរួមរស់ជាមួយគ្នាដូចប្តីប្រពន្ធ ពោលគឺលក្ខណៈនៃការរស់នៅជាមួយគ្នាគ្របដណ្តប់ទៅលើការរស់នៅក្រោមដំបូលផ្ទះតែមួយ និងដំណើរជីវិតរួមគ្នា។ ការរស់នៅជាមួយគ្នាមិនមែនជាលក្ខខណ្ឌជាសារវន្ត ក្នុងការកំណត់អំពីអត្ថិភាពនៃអនីតិសង្វាសនោះទេ ប៉ុន្តែការរស់នៅជាលក្ខណៈប្តីប្រពន្ធទៅវិញទេ ដែលជាលក្ខខណ្ឌសារវន្តសម្រាប់វិនិច្ឆ័យអំពីអនីតិសង្វាស ហើយវាត្រូវបានកំណត់ដោយលក្ខណៈស្ថិរភាព និងនិរន្តរភាព។

---

[26] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២២២។

[27] ចក សម្បត្តិ, «អនីតិសង្វាស» (ភ្នំពេញ,២០១៤), ទំព័រទី ១៧។

### ១.២. ការសង្គ្រោះទៅវិញទៅមក

ប្រសិនបើភាគីនៃអនីតិសង្វាសបានចំណាយ ដើម្បីជីវភាពរស់នៅរួម ការអប់រំ ការថែទាំ ការព្យាបាលកូន ឬសោហ៊ុយដើម្បីគ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិ ឬកាតព្វកិច្ចផ្សេងៗ ដែលភាគីនៃអនីតិសង្វាសបានព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរ ជាមួយនឹងម្ចាស់បំណុល ឬភាគីតែម្ខាងទៀតបានយល់ព្រមតាមលិខិតជាលាយ-លក្ខណ៍អក្សរនៅក្នុងអំឡុងពេលអនីតិសង្វាស ត្រូវចាត់ទុកជាកាតព្វកិច្ចសាមគ្គីរបស់ភាគីនៃអនីតិសង្វាស។ ផ្ទុយទៅវិញ ក្នុងករណីដែលមិនមានការព្រមព្រៀង ឬធ្វើជាលាយលក្ខណ៍អក្សរជាមួយភាគីនៃអនីតិសង្វាស ភាគីដែលបានចំណាយសោហ៊ុយដើម្បីគ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិ ឬកាតព្វកិច្ចផ្សេងៗសម្រាប់គ្រួសារ ត្រូវមានកាតព្វកិច្ចសងចំពោះម្ចាស់បំណុល។

### ១.៣. សមគ្គសង្វាសតាមព្រឹត្តន័យ

អនីតិសង្វាស គឺជាការរួមសមគ្គសង្វាសតាមព្រឹត្តន័យ ដែលបានផ្តល់នូវភាពវិជ្ជមាន និងអវិជ្ជមាន។ សមគ្គសង្វាសតាមព្រឹត្តន័យ សំដៅលើការរួមរស់ជាមួយគ្នាដោយមិនផ្លូវការ ឬមិនបានបំពេញលក្ខខណ្ឌអាពាហ៍ពិពាហ៍ស្របច្បាប់។ [28] ម្យ៉ាងវិញទៀត អនីតិសង្វាសត្រូវបានបែងចែកដាច់ពីអាពាហ៍ពិពាហ៍ស្របច្បាប់ ហើយអនីតិសង្វាសគឺជាសមគ្គសង្វាសសេរីរបស់គូភាគី និងរលាយទៅវិញដោយសេរីផងដែរ។ បើយោងតាមច្បាប់ស្តីពីឯកពន្ធភាព មាត្រា ៣ កថាខណ្ឌទី១ និងច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារឆ្នាំ១៩៨៩ ត្រង់មាត្រា ៣ បញ្ញត្តិថា «អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាឱឡារិកមួយធ្វើឡើងដោយបុរស និងនារីម្នាក់ដែលប្តេជ្ញាចិត្តថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយមិនអាចរំលាយទៅវិញតាមទំនើងចិត្តរបស់ខ្លួនឡើយ»។ តាមការបកស្រាយបែបបដិលោមវិធី ភាពខុសគ្នារវាងអនីតិសង្វាស និងអាពាហ៍ពិពាហ៍អាចត្រូវបានរំលាយដោយតម្រូវឱ្យឆ្លងកាត់នីតិវិធីច្បាប់ដែលមានមូលហេតុ ឬការលែងលះនៅតុលាការ ពោលគឺមិនមែនរំលាយតាមទំនើងចិត្តរបស់ប្តីប្រពន្ធនោះទេ។[29]

### ១.៤. លក្ខណៈស្ថិរភាព និងនិរន្តរភាព

លក្ខណៈស្ថិរភាព និងនិរន្តរភាព ក៏ជាលក្ខខណ្ឌមួយកំណត់ពីអត្ថិភាពនៃអនីតិសង្វាសដែរ។ ជាការពិតណាស់ ទំនាក់ទំនងក្រៅអាពាហ៍ពិពាហ៍ដូចជាអនីតិសង្វាសជាដើម តែងលេចឡើងនូវភាពចម្រុះច្រើនបែប ដែលខ្លះ ស្ថិតជានិរន្តរ៍ ខ្លះរយៈពេលខ្លី ខ្លះលាក់កំបាំង ខ្លះបើកចំហជាសាធារណៈ ហើយខ្លះទៀតត្រូវបានសង្គមទទួលស្គាល់ ឬមិនទទួលស្គាល់ជាដើម។

ដូចនេះបញ្ហាមួយបានលេចឡើងថា តើទំនាក់ទំនងម្តងម្កាលបង្កើតអត្ថិភាពអនីតិសង្វាសឬទេ?

---

[28] សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, *«សទ្ទានុក្រមបារាំង-ខ្មែរនៃពាក្យច្បាប់»*, (ភ្នំពេញ៖ហ្វូណាន ឆ្នាំ២០០២), ទំព័រទី ៧៩។

[29] ចក សម្បត្តិ, «អនីតិសង្វាស» (ភ្នំពេញ,២០១៤), ទំព័រទី ១៨។

ការទាក់ទងគ្នាម្តងម្កាលមិនបង្កើតជាអនីតិសង្វាសនោះទេ ពីព្រោះថា អនីតិសង្វាសត្រូវការអំឡុងពេលវេលាសមស្របមួយ ពោលអនីតិសង្វាសគឺជាស្ថានភាពនៃព្រឹត្តការណ៍ដែលមានរយៈពេលយូរអង្វែង ឬជានិរន្តរ៍។ បើយោងតាមលោក Jean Carbonnier[30] អនីតិសង្វាសខុសពីអាពាហ៍ពិពាហ៍ ហើយទម្រង់នៃសមគ្គសង្វាសក្រៅអាពាហ៍ពិពាហ៍ប្រភេទនេះ គឺមានលក្ខណៈជានិរន្តរ៍។ ហើយអនីតិសង្វាស រួមផ្សំដោយការរស់នៅជាមួយគ្នា ការងារផ្ទះរួមគ្នា។ អនីតិសង្វាស ដែលជាសមគ្គសង្វាសដោយសេរីមួយត្រូវបានគេទទួលស្គាល់ថា វាពុំបានបង្កើតអានុភាពគតិយុត្ត ទោះបីក្នុងករណីដែលស្ថានភាពនៃអនីតិសង្វាសមានស្ថិរភាពមួយច្បាស់លាស់ ដូចគ្នាទៅនឹងអាពាហ៍ពិពាហ៍ស្របច្បាប់ក៏ដោយ។[31]

### ១.៥. ការវិនិច្ឆ័យអំពីភេទ

នៅប្រទេសកម្ពុជាបច្ចុប្បន្នយើងសង្កេតឃើញមានការកើតឡើងនៃការរស់នៅជាមួយគ្នា និងការយកគ្នាជាប្តីប្រពន្ធរវាងភេទដូចគ្នា (រវាងបុរសនិងបុរស និង រវាងនារីនិងនារី) ដោយសារសង្គមកម្ពុជាកាន់តែស្គាល់នូវទំនើបភាវូនីយកម្ម និងសិទ្ធសេរីភាពរបស់បុគ្គលម្នាក់ៗ។ ដោយមានការបើកចំហដល់សិទ្ធិសេរីភាព និងស្របទៅនឹងការរីកចម្រើនរបស់សង្គមកម្ពុជានោះ បុគ្គលដែលស្រឡាញ់ភេទដូចគ្នាកាន់តែមានភាពក្លាហានក្នុងការបង្ហាញពីសមគ្គសង្វាសរបស់ពួកគេជាសាធារណៈ។ បើមើលពីរូបភាពខាងក្រៅនៃទំនាក់ទំនង វាពុំមានលក្ខណៈខុសគ្នាពីការរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធស្របច្បាប់នោះទេ គ្រាន់តែការរួមរស់នៅជាមួយគ្នានោះមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិល។ ហេតុនេះ ភេទដូចគ្នា នឹងត្រូវពិចារណាថាតើជាអនីតិសង្វាស ឬស្ថិតក្នុងស្ថានភាពផ្សេងទៀត?

ដូចដែលយើងបានបញ្ជាក់ខាងលើមកហើយថា អនីតិសង្វាសមិនមែនកើតឡើងដោយសារតែការមិនបានបំពេញនូវលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍នោះទេ អ្វីដែលសំខាន់នោះគឺលក្ខខណ្ឌសារធាតុនៃអនីតិសង្វាសទៅវិញទេ។ ការទទួលស្គាល់នូវអនីតិសង្វាសរវាងបុគ្គលដែលមានភេទដូចគ្នា គឺជាការអនុវត្តយ៉ាងទន់ភ្លន់នូវច្បាប់ តែវារក្សាបាននូវស្ថិរភាពគតិយុត្តមួយដល់សង្គម ជាពិសេសស្ថាប័នអនុវត្តច្បាប់តែម្តង។ ក៏ប៉ុន្តែ ការទទួលស្គាល់បែបនេះវាផ្ទុយនឹងទំនៀមទម្លាប់ដ៏ល្អរបស់សង្គមខ្មែរ។

គួរបញ្ជាក់ផងដែរថា នៅប្រទេសបារាំង ដោយមានការទទួលស្គាល់អាពាហ៍ពិពាហ៍ភេទដូចគ្នា អនីតិ-សង្វាស អាចត្រូវបានបង្កើតឡើងដោយគូភាគីដែលមានភេទដូចគ្នាផងដែរ ដូចមានកំណត់ក្នុងនិយមន័យនៃពាក្យ អនីតិសង្វាសក្នុងក្រមរដ្ឋប្បវេណីបារាំង។[32] រីឯនៅប្រទេសជប៉ុនវិញ មិនមានការទទួលស្គាល់ភេទដូចគ្នា

[30] Jean Cabonnier (1908–2003) was one of the most important French jurists of the 20th century. He was a civil law specialist and a private law professor.

[31] ចក សម្បត្តិ, «អនីតិសង្វាស» (ភ្នំពេញ,២០១៤), ទំព័រទី ១៩។

[32] ចក សម្បត្តិ, «អនីតិសង្វាស» (ភ្នំពេញ,២០១៤), ទំព័រទី ១៧។

ជាអនីតិសង្វាសនោះទេ ដោយមូលហេតុវាផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ទំនៀមទម្លាប់ និងប្រពៃណីល្អរបស់សង្គមជប៉ុន។ ដូចគ្នានេះដែរ នៅប្រទេសកម្ពុជា ដោយសារច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ បានកំណត់យ៉ាងច្បាស់ និងទទួលស្គាល់តែបុរសនារីដែលមានភេទផ្ទុយគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ជាប្តីប្រពន្ធស្របច្បាប់ប៉ុណ្ណោះ។ មួយវិញទៀត នៅពេលដែលមានបណ្តឹងសុំរំលាយអនីតិសង្វាស ក្នុងការអនុវត្តជាក់ស្តែងក្នុងតុលាការកម្ពុជា ភាគច្រើននៃបណ្តឹងទាំងនោះ ត្រូវបានធ្វើឡើងដោយភាគីដែលមានភេទផ្ទុយគ្នាប៉ុណ្ណោះ ដូចនេះអត្ថិភាពនៃអនីតិសង្វាសរវាងបុគ្គលដែលមានភេទដូចគ្នា មិនទាន់លេចឡើងជាយុត្តិសាស្ត្រនៅតុលាការនោះទេ។[33]

ចំពោះបណ្តឹពាក់ព័ន្ធនឹងការរំលាយអនីតិសង្វាស យើងនឹងធ្វើការបកស្រាយក្នុងចំណុច ១.២.១ បណ្តឹងរំលាយ នៃផ្នែកទី២ ការរំលាយចំណងអនីតិសង្វាស។

### ១.៦. ភស្តុតាងដើម្បីគាំទ្រលក្ខខណ្ឌសារធាតុនៃអនីតិសង្វាស

នត្ថិភាពនៃសំបុត្រអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិល គឺជាមូលហេតុកំណត់ពីអត្ថិភាពនៃអនីតិសង្វាស បើទោះបីជាពួកគេបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាមប្រពៃណីក៏ដោយ។ ផ្ទុយទៅវិញ ប្តីប្រពន្ធស្របច្បាប់ សំបុត្រអាពាហ៍ពិពាហ៍ គឺជាភស្តុតាងគតិយុត្តបញ្ជាក់ពី ភាពស្របច្បាប់នៃសមគ្គសង្វាសរបស់ពួកគេ ឬបញ្ជាក់ពីអត្ថិភាពនៃអាពាហ៍ពិពាហ៍របស់ពួកគេ។

ទោះបីអនីតិសង្វាស មិនត្រូវបានចាត់ទុកជាប្តីប្រពន្ធស្របច្បាប់ក៏ដោយ ប៉ុន្តែ គូស្វាមីអនីតិសង្វាសនៅតែអាចទទួលបានការធ្វើលិខិត ឬផ្តល់ឱ្យនូវលិខិតស្នាមនិងឯកសារផ្សេងៗជាច្រើន រួមមានសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារជាដើម។ ដោយហេតុនេះ លិខិតស្នាមផ្សេងៗដែលត្រូវបានបង្កើតឡើងដោយចំណងមួយនេះ តាមរយៈសកម្មភាពដែលកើតចេញពីជីវភាពរស់នៅបែប អនីតិសង្វាសរបស់ពួកគេ អាចប្រើប្រាស់ជាភស្តុតាងបញ្ជាក់ពីអត្ថិភាពនៃអនីតិសង្វាសបាន។ ក៏ប៉ុន្តែ សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារជាដើម មិនអាចយកមកបញ្ជាក់ពីអត្ថិភាពនៃអាពាហ៍ពិពាហ៍ស្របច្បាប់បាននោះទេ ពីព្រោះថា លិខិតទាំងនេះមិនមែនជាលិខិតអត្រានុកូលដ្ឋានដែលធ្វើឡើងដោយមន្ត្រីអត្រានុកូលដ្ឋាននោះទេ។

យ៉ាងណាមិញក្នុងភាពជាក់ស្តែងនៅតុលាការ ពេលមានបណ្តឹងផ្តាច់អនីតិសង្វាស ភស្តុតាងត្រូវបានដាក់ដោយសេរីដោយគូភាគី ព្រោះនៅតុលាការគ្មានការតម្រូវឱ្យគូភាគីដាក់លិខិតទាំងនោះជូនតុលាការនោះទេ។[34] ក្រៅពីលិខិតស្នាមខាងលើ ដោយសារវាជាសមគ្គសង្វាសសេរី អត្ថិភាពនៃអនីតិសង្វាសអាចត្រូវបានបង្ហាញឡើងតាមរយៈមធ្យោបាយផ្សេងៗជាច្រើនទៀតដូចជា ការដាក់អាសយដ្ឋានរួមគ្នាក្នុងបណ្ណ័សម្គាល់ម្ចាស់អចលនវត្ថុ ការចុះឈ្មោះរួមគ្នាក្នុងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុដូចជា ប្លង់កាន់កាប់ដីធ្លី ផ្ទះ លិខិត

[33] ចក សម្បត្តិ, «អនីតិសង្វាស» (ភ្នំពេញ,២០១៤), ទំព័រទី ២២-២៣។

[34] ចក សម្បត្តិ, «អនីតិសង្វាស» (ភ្នំពេញ,២០១៤), ទំព័រទី ២៦-២៧។

ប្រកាសអាពាហ៍ពិពាហ៍ រូបថតរៀបអាពាហ៍ពិពាហ៍ ឬកំដាប់ពាក្យ លិខិតអញ្ជើញចូលរួមអាពាហ៍ពិពាហ៍ ការបញ្ជាក់សមគ្គសង្វាស ឬភាពរួមរស់ក្នុងលក្ខណៈជាប្តីប្រពន្ធពីអាជ្ញាធរមូលដ្ឋាន (មេឃុំ ឬចៅសង្កាត់) ការដឹងឮពីការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីរបស់ពួកគេជាដើម។ ដោយសារតែគ្មានបទបញ្ញត្តិច្បាប់ដែលកំណត់អនីតិសង្វាសគ្មានលក្ខខណ្ឌទម្រង់ជាលាយលក្ខណ៍អក្សរនេះទេ ហើយអត្ថិភាពនៃអនីតិសង្វាសអាចត្រូវបានបញ្ជាក់ដោយសេរី និងប្រើប្រាស់ភស្តុតាង ឬមធ្យោបាយផ្សេងពីៗគ្នាបានដោយហេតុថា អនីតិសង្វាសជាសមគ្គសង្វាសតាមព្រឹត្តិន័យកើតឡើងដោយឆន្ទៈរបស់បុរសនារី។[35]

ទោះបីជាយ៉ាងណាក៏ដោយ ភស្តុតាងដែលបង្ហាញឬដាក់ដោយសេរីរបស់ភាគី អាចត្រូវបានបដិសេធចោលដោយតុលាការក្នុងការអនុវត្តជាក់ស្តែង ដោយសារចៅក្រមមានឆន្ទានុសិទ្ធិសម្រេច និងពិនិត្យទៅលើលក្ខខណ្ឌសារធាតុផ្សេងៗ ដើម្បីវិនិច្ឆ័យទទួលស្គាល់អត្ថិភាពនៃអនីតិសង្វាសរបស់គូភាគី។[36]

**កថាខណ្ឌទី២ អានុភាពក្នុងអំឡុងពេលរួមអនីតិសង្វាស**

បើទោះបីជាគ្មានលិខិតបទដ្ឋានគតិយុត្តកំណត់ច្បាស់លាស់ សម្រាប់គ្រប់គ្រងចំណងអនីតិសង្វាសក៏ដោយ នៅពេលដែលមានអត្ថិភាពនៃអនីតិសង្វាស វាក៏បង្កើតឱ្យមានព្រឹត្តិការណ៍គតិយុត្តរវាងបុគ្គលទាំងពីរពោលវាបង្កើតឱ្យមានអានុភាពគតិយុត្តពាក់ព័ន្ធនឹងបុគ្គល (ក្រៅបេតិកភណ្ឌ) និងអានុភាពពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ (ផ្នែកបេតិកភណ្ឌ) ផងដែរ។

**២.១. អានុភាពពាក់ព័ន្ធនឹងបុគ្គល**

អាពាហ៍ពិពាហ៍ស្របច្បាប់ បង្កើតឱ្យមានទំនាក់ទំនងសហព័ទ្ធតាមផ្លូវច្បាប់ ចុះអនីតិសង្វាសជាសមគ្គសង្វាសព្រឹត្តន័យបង្កើតទំនាក់ទំនងបែបណាទៅ?

ដូចនេះយើង នឹងធ្វើការបកស្រាយក្នុងចំណុច ២.១.១ អានុភាពរវាងអនីតិសង្វាសជន ខាងក្រោម៖

**២.១.១. អានុភាពរវាងអនីតិសង្វាសជន**

**២.១.១.១. ការបង្កើតចំណងញាតិ**

តើអនីតិសង្វាសបង្កើតទំនាក់ទំនងញាតិដែរឬទេ?

ត្រូវចាត់ទុកថាមានទំនាក់ទំនងជាញាតិគឺ ទីមួយរវាងញាតិលោហិតក្នុង ៦ថ្នាក់ ទីពីរសហព័ទ្ធ និងទី៣ញាតិពន្ធក្នុង ៣ថ្នាក់។[37] ជាគោលការណ៍តាមផ្លូវច្បាប់ ប្តីប្រពន្ធត្រូវចាត់ទុកថាមានទំនាក់ទំនងញាតិនឹងគ្នាលុះត្រាតែ ប្តីប្រពន្ធនោះបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ ហើយញាតិត្រូវបានគណនាតាមថ្នាក់ញាតិមួយ

[35] ចក សម្បត្តិ, «អនីតិសង្វាស» (ភ្នំពេញ,២០១៤), ទំព័រទី ២៧។
[36] ចក សម្បត្តិ, «អនីតិសង្វាស» (ភ្នំពេញ,២០១៤), ទំព័រទី ៣០។
[37] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៣៨។

ច្បាស់លាស់។[38] តាមការបកស្រាយបែបបដិលោមវិធី អនីតិសង្វាសមិនបង្កើតទំនាក់ទំនងជាញាតិនោះទេ។ ដូច្នេះហើយ រវាងអនីតិសង្វាសជនទាំងពីរ មិនមានការកើតឡើងនូវសិទ្ធិ និងកាតព្វកិច្ចដូចដែលញាតិមាននឹងគ្នានោះទេ ជាពិសេសគឺទំនាក់ទំនងជាប្តីប្រពន្ធតាមផ្លូវច្បាប់។ ដោយហេតុថា អនីតិសង្វាសជាសមគ្គសង្វាសដោយសេរី វាមិនបង្កើត កាតព្វកិច្ចរួមរស់នៅជាមួយគ្នា កាតព្វកិច្ចស្មោះត្រង់ និងកាតព្វកិច្ចជួយសង្គ្រោះគ្នាទៅវិញទៅមករវាងអនីតិសង្វាសជនទាំងពីរនោះទេ។[39]

### ២.១.១.២. ការទទួលបានអត្តាធីនភាព

ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ ១៦ឆ្នាំ អាចទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់អ្នកនោះបាន តាមពាក្យសុំរបស់អនីតិជននោះ ប្រសិនបើតុលាការយល់ឃើញថា អត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជននោះ។ អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយត្រូវទទួលអត្តាធីនភាព ដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ។[40] អនីតិជនដែលទទួលអត្តាធីនភាពត្រូវចាត់ទុកថាបានដល់ នីតិភាព។[41] ម្យ៉ាងទៀត អាពាហ៍ពិពាហ៍របស់អនីតិជន អាចកើតឡើងបាន លុះត្រាតែមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបាទាំងសងខាង ឬតែម្ខាង ឬអាណាព្យាបាលសម្រាប់អនីតិជននោះ។[42] ហើយនៅពេលដែលអនីតិជន បានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ហើយ អនីតិជននោះត្រូវចាត់ទុកថាបានដល់នីតិភាពដោយអាពាហ៍ពិពាហ៍នោះ។[43]

ក៏ប៉ុន្តែ បញ្ញត្តិដែលបានរៀបរាប់ខាងលើនេះ ពុំត្រូវបានយកមកអនុវត្តចំពោះអនីតិសង្វាសទេ គឺមិនទទួលបានអត្តាធីនភាពឡើយ ដោយហេតុថាគ្មានអត្ថិភាពនៃការចុះសំបុត្រអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិល។

### ២.១.១.៣. ការប្រើប្រាស់នាមត្រកូលប្តី ឬប្រពន្ធ

អនុលោមតាមបញ្ញត្តិមាត្រា ៩៦៥ នៃក្រមរដ្ឋប្បវេណីកម្ពុជា នៅពេលរៀបអាពាហ៍ពិពាហ៍ ប្តីប្រពន្ធ អាចប្រើនាមត្រកូលរបស់ប្តី ឬប្រពន្ធ ឬអាចប្រើនាមត្រកូលដើមរៀងៗខ្លួន ដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍បាន។ នៅប្រទេសកម្ពុជា ការប្រើប្រាស់នាមត្រកូលគឺជាជម្រើសមិនមានលក្ខណៈដាច់ខាតនោះទេ ហើយជាទម្លាប់ និងការអនុវត្តជាក់ស្តែង គឺប្តីប្រពន្ធប្រើនាមត្រកូលដើមក្រោយរៀបអាពាហ៍ពិពាហ៍ស្របច្បាប់។

---

[38] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៣៩។

[39] ចក សម្បត្តិ, «អនីតិសង្វាស» (ភ្នំពេញ,២០១៤), ទំព័រទី ៣១។

[40] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ២១។

[41] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ២២។

[42] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៥៣ កថាខណ្ឌទី១-២។

[43] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៦៨។

ផ្ទុយទៅវិញ បទបញ្ញត្តិនេះមិនត្រូវបានយកមកអនុវត្តចំពោះអនីតិសង្វាសនោះទេ ដោយហេតុថាគ្មានអត្ថិភាពនៃការចុះសំបុត្រអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិល។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តជាក់ស្តែង យើងឃើញថា ពួកគេអាចទទួលបាននូវឯកសារបញ្ជាក់មួយចំនួនតាមរយៈអាជ្ញាធរមូលដ្ឋាន ដូចជា សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ជាដើម។

**២.១.១.៤. ភាតព្វកិច្ចដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍**

អាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ បង្កើតអានុភាពជាកាតព្វកិច្ចទៅដល់សហព័ទ្ធទាំងសងខាងដែលមាន ដូចជា កាតព្វកិច្ចរួមរស់នៅជាមួយគ្នា កាតព្វកិច្ចសហការ និងកាតព្វកិច្ចសង្គ្រោះគ្នាទៅវិញទៅមក។[44] តាមពិតទៅកាតព្វកិច្ចស្មោះត្រង់ ជាកាតព្វកិច្ចសំខាន់មួយផងដែរនៅក្នុងទំនាក់ទំនងនៃអាពាហ៍ពិពាហ៍ ព្រោះថា ការអនុវត្តកិច្ចសន្យាអាពាហ៍ពិពាហ៍តម្រូវឱ្យគូភាគីអនុវត្តកាតព្វកិច្ចរៀងៗខ្លួនដោយស្មោះត្រង់ និងសុចរិត។[45]

ករណីយកិច្ចរួមរស់នៅជាមួយគ្នា សំដៅទៅដល់ករណីយកិច្ចនៃសហព័ទ្ធក្នុងការមានទំនាក់ទំនងផ្លូវភេទជាមួយគ្នា និងដោយសារការភ្ជាប់ជាមួយនូវគោលការណ៍ នៃភាពផ្តាច់មុខក្នុងទំនាក់ទំនងរបស់ពួកគេ បង្កើតបានជាសច្ចធារណ៍នៃបិតុភាព។[46]

ករណីយកិច្ចសហការ សំដៅទៅដល់ការបំពេញបេសកកម្មរបស់ប្តីនិងប្រពន្ធ ដែលមានតួនាទីរៀងៗខ្លួន និងបំពេញឱ្យគ្នាទៅវិញទៅមក ហើយដែលត្រូវអនុវត្តរួមគ្នានិងស្មើភាពគ្នា ក្នុងការដឹកនាំគ្រួសារនិងការអប់រំកូន។ ជាក់ស្តែង គឺការអនុវត្តអំណាចមេបារបស់ឪពុក ឬម្តាយទៅលើកូនរបស់ខ្លួន។

ករណីយកិច្ចសង្គ្រោះគ្នាទៅវិញទៅមក សំដៅទៅដល់ករណីយកិច្ចជួយគ្នារវាងប្តីប្រពន្ធ ក្នុងផ្លូវសម្ភារៈ និងផ្លូវចិត្ត នៅក្នុងការរស់នៅប្រចាំថ្ងៃ (គេហកិច្ច ការថែទាំគ្នាពេលមានជម្ងឺ -ល-)។ អាហារកាតួកិច្ចគឺជាឧទាហរណ៍ស្រាប់នៃករណីកិច្ចនេះ។

រីឯករណីយកិច្ចស្មោះត្រង់ ឈរលើគោលគំនិតថាអាពាហ៍ពិពាហ៍គឺមិនមែន ជាការសន្យាក្នុងការស្រឡាញ់នោះទេ តែជាការសន្យាក្នុងការថែរក្សានូវជំនឿទុកចិត្តរវាងប្តីប្រពន្ធ។ អ្វីដែលមានអាទិភាពជាងគេនៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍ គឺការស្មោះត្រង់ផ្លូវភេទ ដែលហាមឃាត់មិនឱ្យមានការផិតឡើយ។ ការមិនគោរពកាតព្វកិច្ចស្មោះត្រង់ អាចនឹងនាំឱ្យមានការដាក់ទណ្ឌកម្មផ្នែករដ្ឋប្បវេណី និងព្រហ្មទណ្ឌ។ នៅក្នុងទណ្ឌកម្មផ្នែករដ្ឋប្បវេណី អំពើផិត ត្រូវបានចាត់ទុកជាមូលហេតុ នៃការលែងលះដោយសារកំហុស[47] ដោយសារថាវាផ្ទុយនឹងគោលការណ៍ប្តីមួយប្រពន្ធមួយ (ឯកពន្ធភាព)។ ត្រូវចាត់ទុកជាថា ផិត គឺការរួមសេវនកិច្ចរវាង

[44] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៦៦។

[45] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៥។

[46] Raymond Guillien et Jean Vincent, LEXIQUE DES TERMES JURIDIQUES, (Dalloz 16 édition 2007), page 127

[47] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៨ កថាខណ្ឌទី១ ចំណុច ក។

បុរសដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្ដីរបស់ខ្លួន។

អនីតិសង្វាសមិនបានបង្កើតឱ្យមានកាតព្វកិច្ចខាងលើទាំងនេះទ ព្រោះថា កាតព្វកិច្ចខាងលើជាកាតព្វកិច្ចស៊ីវិល ដែលអាចត្រូវបានបង្កើតដោយច្បាប់ប៉ុណ្ណោះ ហើយនេះក៏ជាព្រំដែនមួយច្បាស់លាស់រវាងអាពាហ៍ពិពាហ៍ និងអនីតិសង្វាសផងដែរ។ ដោយឡែក ស្ថានភាពដែលតុលាការទទួលស្គាល់នូវអត្ថិភាពនៃករណីយកិច្ចទាំងនេះនៅក្នុងអនីតិសង្វាស គឺហាក់ដូចជាកំពុងតែទទួលស្គាល់នូវករណីយកិច្ចផ្នែករដ្ឋប្បវេណីដែលកើតចេញពីអាពាហ៍ពិពាហ៍ចំពោះអនីតិសង្វាស។[48]

**២.១.២. អានុភាពចំពោះកូន**

ជាគោលការណ៍ឪពុកម្ដាយ គឺជាអ្នកដែលមានសិទ្ធិអំណាចមេបាលើកូន ហើយឪពុកម្ដាយត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នា។ ផ្ទុយទៅវិញ ប្រសិនបើចំណងអាពាហ៍ពិពាហ៍របស់ឪពុកម្ដាយត្រូវបានរំលាយ (លែងលះ) នោះនឹងនាំឱ្យមានការកំណត់អ្នកដែលមានអំណាចមេបាលើកូន ដោយកំណត់យក ឪពុក ឬម្ដាយណាម្ខាងជាអ្នកមានអំណាចមេបាលើកូន។ ការកំណត់អំពីអ្នកមានអំណាចមេបាអាចកើតមានឡើងក្នុងករណីដែលឪពុកម្ដាយមានចំណងអាពាហ៍ពិពាហ៍ ឬករណីឪពុកម្ដាយគ្មានចំណងអាពាហ៍ពិពាហ៍។[49]

ចុះចំណែកឯ អនីតិសង្វាសវិញ ត្រូវកំណត់ពីអ្នកដែលមានអំណាចមេបាចំពោះកូនយ៉ាងដូចម្ដេច?

**២.១.២.១. ការកំណត់អ្នកមានអំណាចមេបា**

ឪពុកម្ដាយដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នា។[50] ផ្ទុយទៅវិញ ចំពោះទំនាក់ទំនងអនីតិសង្វាស គឺមានតែម្ដាយប៉ុណ្ណោះដែលមានអំណាចមេបាចំពោះកូន (អំណាចមេបាលទោល) ដោយហេតុផលថា ស្ត្រីដែលបានសម្រាលកូន គឺជាម្ដាយរបស់កូន។[51] ចំណែកឯ ឪពុក គឺគ្មានមូលហេតុបិតុភាពតាមច្បាប់នោះទេ លើកលែងតែឪពុកបានទទួលស្គាល់កូននោះដោយស្ម័គ្រចិត្ត និងបានចុះសំបុត្រកំណើតកូន ដោយដាក់ឈ្មោះខ្លួនថាជាឪពុករបស់កូននោះ វាជាហេតុនាំឱ្យមានទំនាក់ទំនងជាឪពុក និងកូនកើតឡើង។[52] ហេតុនេះ អនីតិសង្វាសមិនបង្កើតឱ្យមានអំណាចមេបាសហការ ឬអំណាចមេបារួមដូចអាពាហ៍ពិពាហ៍ស្របច្បាប់ឡើយ។ អំណាចមេបាសហការ ជាអានុភាពគតិយុត្តនៃអាពាហ៍ពិពាហ៍ មិនមែន

[48] ចក សម្បត្តិ, «អនីតិសង្វាស» (ភ្នំពេញ,២០១៤), ទំព័រទី ៣២-៣៦។

[49] អត្ថបទស្ដីពី «អ្នកមានអំណាចមេបា» រៀបរៀងដោយៈ នូ ច័ន្ទសុគន្ធា (សិស្សចៅក្រមជំនាន់ទី៦ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ)

[50] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៣៦។

[51] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨៧។

[52] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៩៣-៩៩៩។

ជាអានុភាពរបស់អនីតិសង្វាស់នោះទេ ដូច្នេះ ក្នុងអំឡុងពេលអត្ថិភាពរបស់ខ្លួន អនីតិសង្វាសបង្កើតឱ្យមានអ្នកមានអំណាចមេបា និងអ្នកគ្មានអំណាចមេបា។

ជារួមមក អំណាចមេបាសហការ ឬអំណាចមេបារួម គឺជាអានុភាពគតិយុត្តរបស់អាពាហ៍ពិពាហ៍ស្របច្បាប់ប៉ុណ្ណោះ ចំណែកឯអនីតិសង្វាសមិនបង្កើតបានជាអានុភាពដូចអាពាហ៍ពិពាហ៍ស្របច្បាប់ទេ ហើយអំណាចមេបារបស់អនីតិសង្វាសទៅលើកូនគឺជាអំណាចមេបាទោល។ ម៉្យាងទៀត នៅក្នុងជីវភាពជាក់ស្តែងប្តីប្រពន្ធអនីតិសង្វាសបានអនុវត្តអំណាចមេបា ដោយសហការគ្នាក្នុងការបីបាច់ថែរក្សា ផ្គត់ផ្គង់ និងគ្រប់គ្រងកូនរបស់ខ្លួនដែលជាអនីតិជន ដូចគ្នានឹងសហព័ទ្ធដែលមានអាពាហ៍ពិពាហ៍ស្របច្បាប់ផងដែរ ទោះបីគ្មានច្បាប់កំណត់ក៏ដោយ។

### ២.១.២.២. អំពីបុត្តភាព

បុត្តភាព សំដៅលើទំនាក់ទំនងញាតិលោហិតខ្សែផ្ទាល់របស់ឪពុកម្តាយ ដែលយើងតែងហៅថា ជាកូនបង្កើត។ បុត្តភាព គឺសំដៅដល់បុត្តភាពតាមផ្លូវច្បាប់ ពោលគឺមានការចុះអត្រានុកូលដ្ឋាន មានសេចក្តីសម្រេចរបស់តុលាការ (សាលក្រម សាលដីកា ឬសេចក្តីសម្រេច)។ វាជាចំណងស៊ីវិលចងភ្ជាប់ឪពុកម្តាយទៅនឹងកូន។

ចំពោះបុត្តភាពនៅក្នុងករណីអនីតិសង្វាសវិញ កើតឡើងតាមរយៈបើករណីគឺ ទី១ មាតុភាព និងបណ្តឹងទាមទារឱ្យបញ្ជាក់អត្ថិភាពនៃមាតុភាព (ពីកូន ឬពីម្តាយ) ទី២ ការសន្មតបិតុភាព និងទី៣ ការទទួលស្គាល់ (តាមរយៈមន្ត្រីអត្រានុកូលដ្ឋាន ឬតាមមតកសាសន៍) និងបណ្តឹងទាមទារឱ្យទទួលស្គាល់។[53]

### ២.១.២.៣. ការសន្មតបិតុភាព

ជាទូទៅស្ត្រីដែលបានសម្រាលកូន ច្បាប់បានកំណត់ថា កូននោះជាកូនបង្កើតរបស់ម្តាយ[54] និងជាកូនបង្កើតរបស់ឪពុក ដែលស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ ឬស្ថិតក្នុងអំឡុងពេលមួយដែលច្បាប់បានកំណត់ថាជាឪពុករបស់កូន។ ក៏ប៉ុន្តែ ប្រសិនបើមិនអាចសន្មតជនដែលត្រូវជាឪពុករបស់កូនបានទេ នោះកូន ឬអ្នកតំណាងរបស់កូន ត្រូវធ្វើការបញ្ជាក់ពីបិតុភាពរបស់កូនបានតាមផ្លូវច្បាប់។

ការបញ្ជាក់ពីបិតុភាពរបស់កូន មាន ៣ របៀប ដូចខាងក្រោម[55]៖

- របៀបទី១: គឺត្រូវបានសន្មតថា ទារកដែលនៅក្នុងគភ៌ប្រពន្ធដែលស្ថិតក្នុងចំណងនៃអាពាហ៍ពិពាហ៍ជាកូនរបស់ប្តី។

[53] ចក សម្បត្តិ, «អនីតិសង្វាស» (ភ្នំពេញ,២០១៤), ទំព័រទី ៤៧។

[54] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨៧។

[55] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨៨។

- របៀបទី២: កូនដែលកើតក្រោយអំឡុងពេល ១៨០ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍បានបង្កើត ឬ អំឡុងពេល ៣០០ថ្ងៃ គិតចាប់ពីថ្ងៃបានរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍ ត្រូវបានសន្មតថាមានគភ៌ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។
- របៀបទី៣: ប្រសិនបើ ស្ត្រីបានរៀបអាពាហ៍ពិពាហ៍ថ្មីក្នុងអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍-ពិពាហ៍ថ្មីនោះ ប្រសិនបើមិនអាចកំណត់ឳពុករបស់កូនបាន ត្រូវសន្មតថាជាកូនរបស់ប្តីដែលបានរៀបអាពាហ៍ពិពាហ៍ថ្មី។

ចំពោះឳពុកដែលមានបំណងទទួលស្គាល់កូនដោយស្ម័គ្រចិត្ត ច្បាប់បានអនុញ្ញាត ក៏ប៉ុន្តែ ត្រូវមានការយល់ព្រមពីម្តាយរបស់កូនជាមុនប្រសិនបើកូនជាអនីតិជន តែបើកូនជានីតិជនត្រូវមានការយល់ព្រមពីកូនដោយផ្ទាល់ ហើយបែបបទនៃទម្រង់ការទទួលស្គាល់នេះ ត្រូវធ្វើការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន ឬតាមរយៈមតកសាសន៍ (ការយល់ព្រមរបស់ម្តាយត្រូវមាន ការចុះហត្ថលេខាលើលិខិតទទួលស្គាល់)។[56] តែផ្ទុយទៅវិញ ក្នុងករណីដែល ឳពុក ឬកូនបានដឹងថាមិនមែនជាឳពុកកូនបង្កើត ជនដែលត្រូវបានសន្មតថា ជាឳពុក ឬជាកូនអាចមានសិទ្ធិបដិសេធចំពោះបិតុភាពបាន។[57]

ចំពោះករណីអនីតិសង្វាសវិញ ការទទួលស្គាល់មាតុភាព មិនមែនជាបញ្ហាចោទនោះទេ ព្រោះថា ស្ត្រីដែលជាអ្នកពរពោះកូន ឬស្ត្រីដែលសម្រាលកូន គឺជាម្តាយរបស់កូននោះ ក៏ប៉ុន្តែ ការសន្មតបិតុភាពវិញ លុះត្រាតែមានការទទួលស្គាល់ពីឳពុកចំពោះកូននោះ (កូនជាអនីតិជន) និងកូនចំពោះឳពុក ក្នុងករណីកូនជានីតិជន។

#### **២.១.២.៤. អាហារកាតព្វកិច្ច ឬអាហារកិច្ច**

អាហារកាតព្វកិច្ច គឺជាជំនួយផ្នែកហិរញ្ញវត្ថុដល់បុគ្គលដែលមិនអាចទ្រទ្រង់ជីវភាពដោយសមត្ថភាពផ្ទាល់ខ្លួនបាន។ បុគ្គលដែលត្រូវការអាហារកាតព្វកិច្ច ហៅថា ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច រីឯជនដែលផ្តល់អាហារកាតព្វកិច្ច ហៅថា ជនដែលមានករណីកិច្ចផ្តល់អាហារកាតព្វកិច្ច។ អាហារកាតព្វកិច្ចរវាងឳពុកម្តាយនិងកូនជាអនីតិជន ត្រូវបានកើតឡើងតាមរយៈអានុភាពនៃអំណាចមេបា ក្នុងនោះអ្នកដែលមានអំណាចមេបា មានសិទ្ធ និងករណីកិច្ចត្រូវបីបាច់ថែរក្សារូបកាយរបស់កូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យរបស់កូននោះ។

យោងតាមស្មារតីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៤៧ កថាខណ្ឌទី១ បានបញ្ញត្តិថា មាតាបិតាមានកាតព្វកិច្ចថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ។ ពោលគឺឳពុកម្តាយមានករណីកិច្ចត្រូវ ស្រឡាញ់កូន

[56] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៩៥-៩៩៧។
[57] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨៩។

ចិញ្ចឹមបីបាច់រក្សាកូន និងយកចិត្តទុកដាក់អប់រំកូន គឺបណ្តុះបណ្តាលកូនឱ្យស្រឡាញ់ការរៀនសូត្រ ស្នេហាមាតុភូមិ មានស្មារតីសាមគ្គីជាតិ ស្រឡាញ់ពលកម្ម គោរពទ្រព្យសម្បត្តិរដ្ឋ និងទ្រព្យសម្បត្តិរបស់អ្នកដទៃ។

នៅពេលមានពាក្យសុំរំលាយ ឬបញ្ឈប់ការរួមរស់ជាអនីតិសង្វាស អនីតិសង្វាសជនតែងតែទាមទារអាហារកាតព្វកិច្ចពីភាគីម្ខាងទៀតក្នុងផលប្រយោជន៍ផ្ទាល់ខ្លួន ឬសម្រាប់ទ្រទ្រង់ចិញ្ចឹមកូន។[58] អាហារកាតព្វកិច្ចកើតឡើងចំពោះតែសហព័ទ្ធដែលបានចុះបញ្ជីអាពាហ៍ពិពាហ៍តាមច្បាប់ប៉ុណ្ណោះ ហើយមិនត្រូវបានអនុវត្តឡើយចំពោះអនីតិសង្វាសនៅពេលមានពាក្យសុំរំលាយអនីតិសង្វាស ទោះបីភាគីម្ខាងមានកំហុសក៏ដោយ។

### ២.១.៣. អភ័យឯកសិទ្ធិគ្រួសារ

អភ័យឯកសិទ្ធិគ្រួសារ សំដៅទៅលើភាពមិនអាចផ្តន្ទាទោសព្រហ្មទណ្ឌបាន ចំពោះជនដែលបានប្រព្រឹត្តបទល្មើសលួច (អំពើលួចទ្រព្យសម្បត្តិ) បើជននោះលួចទ្រព្យសម្បត្តិរបស់បុព្វញាតិ ឬបច្ឆាញាតិ និងទ្រព្យសម្បត្តិរបស់សហព័ទ្ធខ្លួន។[59]

នៅក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយតឹងរ៉ឹង ដើម្បីឱ្យចៅក្រមមិនអាចពង្រីកវិសាលភាព អនុវត្តន៍ដូច្នេះយើងអាចបកស្រាយបានថា ពាក្យ "សហព័ទ្ធ" ដែលចែងក្នុងមាត្រា ៣៥៥ ស្តីពីអភ័យឯកសិទ្ធិគ្រួសារ ក្នុងអំពើលួចនេះត្រូវបកស្រាយតឹងរ៉ឹង ពោលគឺជាសហព័ទ្ធដែលកើតចេញពីអាពាហ៍ពិពាហ៍ស្របច្បាប់។

ហើយពាក្យថា "ទ្រព្យសម្បត្តិ" នៅទីនេះ អាចជាទ្រព្យសម្បត្តិរួម ឬទ្រព្យសម្បត្តិដោយឡែក ហើយអាចជាទ្រព្យសកម្ម ឬទ្រព្យអកម្ម។ ជាវិបាក អំពើលួចទ្រព្យសម្បត្តិរបស់អនីតិសង្វាសជនណាម្នាក់ ដោយអនីតិសង្វាសជនណាម្នាក់ទៀត ត្រូវចាត់ទុកជាអំពើលួច ហើយដែលមិនអាចទទួលបាននូវអភ័យឯកសិទ្ធិគ្រួសារដូចមានចែងក្នុងកថាខណ្ឌទី២ នៃមាត្រា ៣៥៥ នៃក្រមព្រហ្មទណ្ឌនោះទេ។

ម្យ៉ាងទៀត ទ្រព្យសម្បត្តិក្នុងចំណងអនីតិសង្វាសមិនមែនជាទ្រព្យសម្បត្តិដែលស្ថិតនៅក្នុងប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធនោះទេ ពោលគឺវាជាទ្រព្យសម្បត្តិនៅក្រោមរបបគតិយុត្តនៃកម្មសិទ្ធិអវិភាគ។ បើភាគីនៃអនីតិសង្វាសជនណាម្នាក់លួចទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់អនីតិសង្វាសជនណាម្នាក់ទៀត ឬទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិអវិភាគនៃពួកគេទាំងពីរ ពោលគឺត្រូវទទួលខុសត្រូវទាំងផ្នែកព្រហ្មទណ្ឌ និងផ្នែករដ្ឋប្បវេណីបើសិនជាមានការទាមទារពីជនរងគ្រោះ ពីព្រោះថា អនីតិសង្វាសមិនបានបង្កើតជាអភ័យឯកសិទ្ធិគ្រួសារក្នុងរឿងព្រហ្មទណ្ឌនោះទេ។[60]

[58] ចក សម្បត្តិ, «អនីតិសង្វាស» (ភ្នំពេញ,២០១៤), ទំព័រទី ៥៤។

[59] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣៥៥។

[60] ចក សម្បត្តិ, «អនីតិសង្វាស» (ភ្នំពេញ,២០១៤), ទំព័រទី ៣៧។

## ២.២. អានុភាពពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ

ចំពោះការរស់នៅបែបអនីតិសង្វាស ថ្វីត្បិតមានសកម្មភាពដូចគ្នានឹងសហព័ទ្ធមែន ប៉ុន្តែមិនអាចកើតឡើងនូវប្រព័ន្ធទ្រព្យសម្បត្តិណាមួយដែលកំណត់ដោយច្បាប់ឡើយ ដោយសារនត្ថិភាពនៃសំបុត្រអាពាហ៍ពិពាហ៍។ ទោះជាយ៉ាងណាក្តី ការរស់នៅបែបអនីតិសង្វាសនៅក្នុងសង្គមខ្មែរយើង ទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិឃើញថា មានការអនុវត្តដោយមានការទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក មានន័យថា បើទោះបីគ្មានសំបុត្រអាពាហ៍ពិពាហ៍ ក៏អនីតិសង្វាសបានគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនដោយសាមគ្គីភាព សហការគ្នាដូចសហព័ទ្ធដែរ។ ការគ្រប់គ្រងប្រកបដោយភាពរលូនគ្មានបញ្ហាអ្វីឡើយ ប្រសិនបើភាគីទាំងពីរព្រមព្រៀងគ្នាក្នុងការចាត់ចែង ឬក៏គ្រប់គ្រងនោះ។ ប៉ុន្តែបញ្ហាចម្បងនោះ ប្រសិនបើមិនអាចពិភាក្សាគ្នាបានទេ តើពួកគេគួរធ្វើដូចម្តេច? ដើម្បីឆ្លើយនឹងសំណួរនេះ ជាដំបូង ត្រូវកំណត់ឱ្យបានច្បាស់ថា ទ្រព្យសម្បត្តិណាខ្លះជាកម្មសិទ្ធិផ្តាច់មុខរបស់អនីតិសង្វាសជន និងទ្រព្យសម្បត្តិណាខ្លះដែលជាទ្រព្យសម្បត្តិនៃកម្មសិទ្ធិរួមនៃអ្នកទាំងពីរ ទើបអាចដោះស្រាយបញ្ហានៃការប្រើប្រាស់សិទ្ធិទៅលើទ្រព្យទាំងនោះ។

តទៅនេះ យើងនឹងសិក្សាអំពីទ្រព្យសម្បត្តិដែលកើតឡើងក្នុងអំឡុងពេលនៃការរួមរស់របស់អនីតិសង្វាស ដូចជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន(២.២.១) ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរួម(២.២.២) និងកាតព្វកិច្ចបំណុលរបស់អនីតិសង្វាស(២.២.៣)។

### ២.២.១. ទ្រព្យសម្បត្តិជាកម្មសិទ្ធិផ្ទាល់ខ្លួន

ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់អនីតិសង្វាសជន គឺមានភាពដូចគ្នា និងខុសគ្នាមួយចំនួន ហើយការកំណត់អំពីទ្រព្យសម្បត្តិនេះ គឺយើងអាចកំណត់បានថាទ្រព្យសម្បត្តិផ្ទាល់ខ្លួននៃអនីតិសង្វាស គឺកើតចេញសកម្មភាពគ្រប់បែបយ៉ាងនៃការកើតឡើងនៃទ្រព្យសម្បត្តិតាមរយៈ ការប្រកបរបររកស៊ី អាជីវកម្ម ប្រាក់ខែ ដែលបានមកពីការធ្វើការងារជាដើម។ លើសពីនេះ ទ្រព្យដែលបានមកពី ការប្រទានកម្ម អច្ច័យទាន សន្តតិកម្ម ក៏ចាត់ជាទ្រព្យសម្បត្តិផ្ទាល់ខ្លួននៃអនីតិសង្វាសជនផងដែរ និងប្រាក់ដែលរកបានក្នុងអំឡុងពេលរស់នៅជាអនីតិសង្វាសក៏ចាត់ជាទ្រព្យសម្បត្តិផ្ទាល់ខ្លួនដូចគ្នាដែរ។ ប្រសិនបើ គេមិនអាចធ្វើការបែងចែកបានថាទ្រព្យណាមួយជារបស់អ្នកណាទេនោះ ទ្រព្យទាំងនោះគួរតែត្រូវសន្មតថាជា ទ្រព្យសម្បត្តិអវិភាគ។

ចំពោះការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់អនីតិសង្វាស គឺដូចគ្នាទៅនឹងការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធផងដែរ។ ក៏ប៉ុន្តែ ការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ដែលបានបញ្ញត្តិក្នុងមាត្រា ៩៧៧ នៃក្រមរដ្ឋប្បវេណី មិនអាចយកមកអនុវត្តចំពោះករណីអនីតិសង្វាសបានឡើយ។

### ២.២.២. ទ្រព្យសម្បត្តិជាកម្មសិទ្ធិរួម

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយណា ដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក្នុងលក្ខណៈជាប្រាក់បៀវត្សរ៍ ឬប្រាក់ឈ្នួល ឬប្រាក់កម្រៃ ឬប្រយោជន៍នានាផ្សេងពីទ្រព្យសម្បត្តិដែលមានចែងក្នុងមាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណី។[61]

ចំណែកឯ ក្នុងទំនាក់ទំនងអនីតិសង្វាសវិញ គឺពុំមានប្រព័ន្ធទ្រព្យសម្បត្តិរួម និងប្រព័ន្ធទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យាអនីតិសង្វាសនោះទេ។ ប៉ុន្តែអនីតិសង្វាសជន អាចធ្វើកិច្ចសន្យាកំណត់អំពីទ្រព្យសម្បត្តិ ដែលមានលក្ខណៈជាកិច្ចសន្យាឯកជនបាន។

#### ២.២.២.១. ប្រភពនៃទ្រព្យសម្បត្តិរួម

ករណីប្តីប្រពន្ធស្របច្បាប់ ប្រភពនៃទ្រព្យសម្បត្តិរួមរបស់ពួកគេរួមមាន ទ្រព្យសម្បត្តិដែលទទួលបានអំឡុងអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិរួមកើតឡើងតាមការព្រមព្រៀង។ ទ្រព្យសម្បត្តិដែលទទួលបានអំឡុងអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិទាំងឡាយណា ដែលសហព័ទ្ធទទួលបាននៅក្នុងអំឡុងពេលដែលបានរៀបអាពាហ៍ពិពាហ៍ ទោះបីជាប្តីរកបានអំពីការងារដែលខ្លួនធ្វើ ឬប្រពន្ធបានមកពីការប្រកបកិច្ចការងាររបស់ខ្លួនក៏ដោយក៏ទ្រព្យសម្បត្តិទាំងនោះចាត់ទុកថាជាទ្រព្យសម្បត្តិរួមដែរ។ រីឯ ទ្រព្យសម្បត្តិរួមដែលកើតឡើងតាមការព្រមព្រៀងសំដៅទៅលើទ្រព្យសម្បត្តិទាំងឡាយណា ដែលមានការព្រមព្រៀមពីសហព័ទ្ធណាម្ខាង ស្ម័គ្រចិត្តដាក់ទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន ទៅជាទ្រព្យសម្បត្តិរួម ដែលធ្វើឡើងតាមរយៈជាកិច្ចសន្យាលាយល័ក្ខអក្សរជាដើម។

ផ្ទុយទៅវិញ ចំពោះទំនាក់ទំនងអនីតិសង្វាសពុំមានប្រព័ន្ធទ្រព្យសម្បត្តិរួម ដូចបានរៀបរាប់ក្នុងចំណុច ២.២.២.ខាងលើឡើយ តែទំនាក់ទំនងនេះ ក៏អាចមានអត្ថិភាពនៃប្រភពទ្រព្យសម្បត្តិរួមផងដែរ ដូចជា ទ្រព្យសម្បត្តិជាកម្មសិទ្ធិរួមរបស់អនីតិសង្វាសដែលកើតចេញមកពីការដាក់ទុនបើកមុខរបរជាមួយគ្នា ឬទិញវត្ថុណាមួយគ្នាជាដើម។

#### ២.២.២.២. ការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិរួម

ជាគោលការណ៍ សហព័ទ្ធមានសិទ្ធិគ្រប់គ្រាន់ក្នុងការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនទៅតាមតម្រូវការប្រចាំថ្ងៃ។ ចំពោះទ្រព្យសម្បត្តិរួម ប្តីប្រពន្ធត្រូវមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រង ដោយមិនបែងចែកថា អ្នកណាធ្វើការបានប្រាក់ខែច្រើនជាងអ្នកណាទេ។ ក៏ប៉ុន្តែ ការប្រើប្រាស់ទ្រព្យសម្បត្តិរួមនេះ ត្រូវតែធ្វើឡើងនៅក្នុងទំហំចាំបាច់ ដោយផ្អែកទៅលើភាពចាំបាច់នៅក្នុងជីវភាពរស់នៅ មិនមែនចេះតែចាយវាយតម្រូវទៅតាមចិត្តចង់ខ្លួនឯងទេ។ ហើយកិច្ចសំខាន់ៗដែលទាក់ទងនឹងការចាត់ចែងទ្រព្យរួម ដូចជា ការលក់ដូរ ឬការយកទៅធ្វើជាអំណោយជាដើម ត្រូវតែមានការព្រមព្រៀងពីប្តីប្រពន្ធទាំងសងខាង។

[61] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៣។

ផ្ទុយពីអាពាហ៍ពិពាហ៍ស្របច្បាប់ ដោយសារតែអនីតិសង្វាសពុំមានប្រព័ន្ធទ្រព្យរួម និងប្រព័ន្ធទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យា ការណ៍នេះនាំឱ្យមានភាពស្មុគស្មាញខ្លាំងក្នុងការកំណត់ទ្រព្យសម្បត្តិរបស់អនីតិសង្វាសជន។ ក្នុងករណីដែលមានវិវាទអំពីការប្រើប្រាស់ទ្រព្យសម្បត្តិកើតឡើង យើងត្រូវធ្វើចំណាត់ថ្នាក់ទ្រព្យសម្បត្តិទាំងនោះជាមុនសិន មានន័យថា កំណត់ទ្រព្យណាជាកម្មសិទ្ធិរួម និងទ្រព្យណាជាកម្មសិទ្ធិផ្ទាល់ខ្លួន។ ការធ្វើចំណាត់ថ្នាក់សំខាន់បំផុត គឺការបង្ហាញភស្តុតាងបញ្ជាក់ឱ្យច្បាស់ថាទ្រព្យណាជារបស់ផ្ទាល់ខ្លួន និងទ្រព្យណាដែលជាកម្មសិទ្ធិរួម។

មួយវិញទៀត ប្រសិនបើមិនច្បាស់ពីចំណែកនៃទ្រព្យសម្បត្តិ យើងអាចកំណត់បានថា ទ្រព្យទាំងនោះជាកម្មសិទ្ធិអវិភាគ ហើយប្រសិនបើមានវិវាទពីការប្រើប្រាស់ទ្រព្យ និងមិនអាចព្រមព្រៀងគ្នាទៅលើការគ្រប់គ្រង និងថែរក្សាទ្រព្យនោះទេ ជាគោលការណ៍ បញ្ញត្តិនៃកម្មសិទ្ធិអវិភាគ ត្រូវយកមកអនុវត្ត។

តាមទិដ្ឋភាពច្បាប់ ការចាត់ចែងទ្រព្យសម្បត្តិរួម ត្រូវតែមានការយល់ព្រមពីប្តីប្រពន្ធទាំងសងខាង លើកលែងតែមានស្ថានភាពពិសេសសម្រាប់ជីវភាពរស់នៅរួម។ ប្តីប្រពន្ធណាម្ខាងអាចចាត់ចែងទ្រព្យសម្បត្តិរួមនោះបានដោយការទទួលបានការអនុញ្ញាតពីតុលាការ ហើយប្រសិនបើបានចាត់ចែងដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ឬគ្មានការអនុញ្ញាតពីតុលាការទេនោះ សហព័ទ្ធដែលមិនបានយល់ព្រម អាចទាមទារឱ្យលុបចោលនូវការចាត់ចែងនោះបាន ដោយការដាក់ពាក្យប្តឹងទៅតុលាការនៅក្នុងអំឡុងពេល ២ឆ្នាំ គិតចាប់ពីពេលដែលបានដឹង។ ក្នុងករណីនេះ ប្រសិនបើទ្រព្យដែលបានចាត់ចែងនោះជាអចលនវត្ថុ និងអំឡុងពេល ១ឆ្នាំប្រសិនបើទ្រព្យនោះមិនមែនជាអចលនវត្ថុ។[62] ករណីនេះមិនយកមកអនុវត្តចំពោះអនីតិសង្វាសឡើយ។

### ២.២.៣. ភាតព្វកិច្ចបំណុលរបស់អនីតិសង្វាស

ក្នុងទំនាក់ទំនងអនីតិសង្វាស ពុំមានសកម្មភាពនៃការទទួលខុសត្រូវដោយសាមគ្គីភាពដូចសហព័ទ្ធទេ។ ក្នុងករណីប្រសិនបើ ភាគីណាមួយនៃអនីតិសង្វាសបានជំពាក់បំណុល អ្នកដែលបានជំពាក់នោះត្រូវទទួលខុសត្រូវដោយខ្លួនឯង មិនពាក់ព័ន្ធជាមួយអនីតិសង្វាសជនម្ខាងទៀតឡើយ។ តែប្រសិនបើ មានការព្រមព្រៀងរវាងអនីតិសង្វាសជនទាំងពីរ ដោយផ្ទាល់មាត់ក្តី ឬដោយលាយលក្ខណ៍អក្សរក្តី ភាគីនៃអនីតិសង្វាសទាំងពីរត្រូវទទួលខុសត្រូវរួមគ្នា។

## ផ្នែកទី២ ការរំលាយចំណងអនីតិសង្វាស

ចំពោះរបៀបនៃការបញ្ចប់អនីតិសង្វាស ក៏មិនខុសពីការរំលាយអាពាហ៍ពិពាហ៍ស្របច្បាប់ប៉ុន្មានឡើយ បើទោះបីជាអនីតិសង្វាសជាចំណងក្រៅគតិយុត្តក៏ដោយ។ ក៏ព្រោះតែអនីតិសង្វាសជាចំណងក្រៅគតិយុត្ត

[62] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៦។

ដូច្នេះ ក្រោយពីមានការបង្កើតចំណងអនីតិសង្វាសហើយ នឹងឈានដល់ការបញ្ចប់អនីតិសង្វាសវិញនោះ បានបង្កឱ្យមានបញ្ហាជាច្រើនដល់អនីតិសង្វាសជនទាំងសងខាង ជាពិសេសពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិជាដើម។

ដូចនេះ យើងនឹងធ្វើការបកស្រាយបន្តទៅទៀតអំពី សញ្ញាណទាក់ទងការរំលាយអនីតិសង្វាស (កថាខណ្ឌទី១) និង អានុភាពក្រោយការរំលាយអនីតិសង្វាស (កថាខណ្ឌទី២) ដែលជាចំណុចមិនអាចខ្វះបាន។

## កថាខណ្ឌទី១ សញ្ញាណទាក់ទងការរំលាយអនីតិសង្វាស

### ១.១. មូលហេតុនៃការរំលាយអនីតិសង្វាស

អនីតិសង្វាស ជាចំណងក្រៅគតិយុត្ត ដូចនេះ ភាគីអាចរួមរស់ជាមួយគ្នាដោយសេរី ហើយការរលាយទៅវិញក៏ដោយសេរីផងដែរ ផ្ទុយពីអាពាហ៍ពិពាហ៍ដែលត្រូវរលាយទៅវិញដោយឆ្លងកាត់នីតិវិធីមួយច្បាស់លាស់ និងតឹងរ៉ឹង។ ក្នុងប្រភេទជាចំណងដែលកើតឡើងតាមព្រឹត្តិន័យ អនីតិសង្វាសក៏ត្រូវរលាយវិញទៅតាមព្រឹត្តិន័យវិញដែរ ពីព្រោះថាវាកើតឡើងដោយឆន្ទៈសេរីរបស់គូភាគី (គោលការណ៍ស្វ័យភាពនៃឆន្ទៈ ឬស្វ័យភាពនៃបុគ្គលឯកជន) ហើយក៏វារលាយទៅវិញដោយតាមឆន្ទៈសេរីរបស់គូភាគីវិញដែរ។

ចំពោះអាពាហ៍ពិពាហ៍ដែលបានបង្កើតឡើងដោយចំណងគតិយុត្ត មិនអាចត្រូវបានរំលាយដោយសេរីដោយគ្រាន់តែមានការបង្ហាញឆន្ទៈរបស់ភាគីនោះទ គឺត្រូវមានការអនុញ្ញាត ឬសេចក្តីសម្រេចរបស់តុលាការ។

ដូចនេះ សហព័ទ្ធអាចធ្វើការលែងលះបាន លុះត្រាតែមានមូលហេតុណាមួយក្នុងចំណោមមូលហេតុនានាដែលច្បាប់កំណត់ខាងក្រោម៖

- បានប្រព្រឹត្តអំពើជិតទៅលើសហព័ទ្ធ។
- បានបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ។
- មិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬរស់ អស់រយៈពេលជាង ១ឆ្នាំ។
- បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង ១ឆ្នាំ ផ្ទុយនឹងងគោលបំណងនៃអាពាហ៍ពិពាហ៍។
- ករណីបែកបាក់គ្នា និងគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន។[63]

ចំណែកឯ ការរំលាយអនីតិសង្វាសវិញ ដោយសារតែពុំមានច្បាប់ចែង ដូចនេះនាំឱ្យមានផលលំបាកក្នុងការអនុវត្តថា តើគួរកំណត់ការរំលាយចំណងអនីតិសង្វាស ប្រដូចទៅនឹងនីតិសង្វាស ឬយ៉ាងណា? ទោះជាបែបនោះក្តី ក្នុងបរិបទប្រទេសកម្ពុជា ចំណងអនីតិសង្វាសក៏ពុំសូវមានលក្ខណៈខុសគ្នាទៅនឹងនីតិសង្វាសដែរ រីឯមូលហេតុនៃការរំលាយក៏មិនមានលក្ខណៈខុសគ្នាប៉ុន្មានដែរ។

[63] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២៧០/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៨ កថាខណ្ឌទី១ ចំណុច ក - ង។

ករណីអាពាហ៍ពិពាហ៍បង្កើតឡើងដោយស្របច្បាប់ តុលាការដែលបានទទួលពាក្យបណ្ដឹងលែងលះគ្នា ក្នុងករណីចាំបាច់ តុលាការអាចចេញដីការសម្រេចចាត់ចែងរក្សាការពារដូចខាងក្រោម៖

- ការបំបែកលំនៅ
- ការគ្រប់គ្រងថែរក្សាកូន
- ការគ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិ
- អាហារកាតព្វកិច្ចរបស់សហព័ទ្ធ
- បន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍
- សោហ៊ុយចិញ្ចឹមបីបាច់កូនជាអាទិ៍។[64]

តុលាការដែលទទួលពាក្យបណ្ដឹងលែងលះគ្នា អាចចេញដីកាសម្រេចបង្គាប់ឱ្យធ្វើការចាត់ចែងរក្សាការពារ តាមការដាក់ពាក្យសុំរបស់ភាគីទៅតុលាការ ឬតាមឆន្ទានុសិទ្ធិរបស់តុលាការ។ ចំណែកឯ ករណីអនីតិសង្វាស មិនទាន់បានកំណត់នៅឡើយថា តើគួរយកមកអនុវត្តប្រដូច និងនីតិសង្វាស ឬយ៉ាងណានោះទេ?

ទោះជាបែបនោះក្ដី អនីតិសង្វាសអាចត្រូវបានបញ្ចប់ក្នុងករណីដូចជា ការចុះបញ្ជីអាពាហ៍ពិពាហ៍ ការប្រកាស ការបាត់ខ្លួន មរណភាព និងការឈប់រស់នៅជាមួយគ្នាជាដើម។

### **១.២. នីតិវិធីនៃការរំលាយអនីតិសង្វាស**

#### **១.២.១. បណ្ដឹងរំលាយ**

បណ្ដឹងនៅក្នុងរឿងក្ដីអនីតិសង្វាស ជាញឹកញាប់គឺដើមចោទតែងតែសុំផ្ដាច់សមគ្គសង្វាសពីចុងចម្លើយ ឬផ្ដាច់អនីតិសង្វាស ឬបំបែកលំនៅជាអនីតិសង្វាស។ ក៏ប៉ុន្តែ ចាប់ពីឆ្នាំ២០១៣ មកមានការផ្លាស់ប្ដូរកម្មវត្ថុនៃបណ្ដឹងពី បណ្ដឹងទាមទារសុំផ្ដាច់សមគ្គសង្វាស ទៅជា បណ្ដឹងសុំបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍។[65] ជាក់ស្ដែង យោងទៅតាមសាលក្រមសាលាដំបូងរាជធានីភ្នំពេញ គឺដើមចោទប្ដឹងទាមទារឈប់រស់នៅជាអនីតិសង្វាស សុំសិទ្ធិអំណាចមេបាលើកូន និងសុំទាមទារគ្រប់គ្រងកាន់កាប់ទ្រព្យសម្បត្តិជាអចលនវត្ថុជាដើម។[66]

តើការផ្លាស់ប្ដូរបណ្ដឹងផ្ដាច់អនីតិសង្វាស ទៅជាបណ្ដឹងសុំបញ្ជាក់ពីនត្ថិភាពនៃអាពាហ៍ពិពាហ៍ ជាបណ្ដឹងត្រឹមត្រូវដែរឬទេ?

ការផ្ដាច់អនីតិសង្វាស ពុំមានផលប្រយោជន៍ ឬភាពចាំបាច់តាមផ្លូវច្បាប់ ក្នុងការធ្វើបណ្ដឹងបញ្ជាក់អំពីនត្ថិភាពនៃអាពាហ៍ពិពាហ៍ឡើយ ព្រោះថា គោលដៅរបស់វាគឺបញ្ហាផ្លូវចិត្ត និងផ្លូវសីលធម៌ក្នុងសង្គមកម្ពុជាតែ

---

[64] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨៣។

[65] ចក សម្បត្តិ, «អនីតិសង្វាស» (ភ្នំពេញ,២០១៤), ទំព័រទី ៦៣។

[66] សំណុំរឿងរដ្ឋប្បវេណីលេខ ២៦៩២ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨, ពាក្យបណ្ដឹង ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៩ នៃសាលាដំបូងរាជធានីភ្នំពេញ ។

ប៉ុណ្ណោះ។ ការទទួលស្គាល់អំពីនត្ថិភាពនៃអាពាហ៍ពិពាហ៍ ក៏មិនមានន័យថា មានអត្ថិភាពនៃអនីតិសង្វាស ដោយស្វ័យប្រវត្តិដែរ។ ម្យ៉ាងទៀត ការទាមទារសុំបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍នេះ អាចត្រូវបានទទួលស្គាល់ដោយតុលាការបានតែក្នុងករណីដែលមានមូលហេតុរបស់វាត្រឹមត្រូវ។ ដូចនេះ សំណួរចោទឡើងថា តើអ្វីទៅជាមូលដ្ឋានរបស់តុលាការក្នុងការសម្រេចអំពីការបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍? ជាទូទៅ ទំនងជាមានសច្ចធារណ៍តាមផ្លូវតុលាការដែលថា បើគ្មានសំបុត្រអាពាហ៍ពិពាហ៍នោះវាមាននត្ថិភាពនៃអាពាហ៍ពិពាហ៍។[67]

**១.២.១.១. ការដាក់ពាក្យបណ្ដឹង**

ជាទូទៅ ការដាក់ពាក្យបណ្ដឹងលែងលះ ត្រូវធ្វើឡើងនូវចំពោះមុខសាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីដែលពាក់ព័ន្ធនឹងបណ្ដឹងលែងលះនោះ។ ភាគីក៏អាចដាក់ពាក្យសុំលែងលះ ទៅក្រុមប្រឹក្សាឃុំសង្កាត់ ហើយក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវធ្វើការបញ្ចុះបញ្ចូលឱ្យសះជាគ្នាបានក្នុងអំឡុងពេល ១៥ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំនោះ។ បើមិនអាចបញ្ចុះបញ្ចូលឱ្យសះជាបានទេ ត្រូវចាត់ទុកថាមានបណ្ដឹងលែងលះគ្នា ហើយក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបញ្ជូនពាក្យបណ្ដឹងនោះទៅតុលាការជាបន្ទាន់។[68]

របៀបដាក់ពាក្យបណ្ដឹង និងចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹងត្រូវអនុលោមតាមការកំណត់របស់ច្បាប់ដូចខាងក្រោម៖

- ការប្ដឹង ត្រូវធ្វើដោយដាក់ពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរ
- ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹងរួមមានៈ
  - ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់។
  - ខ្លឹមសារនៃសាលក្រម ដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ។
  - គប្បីសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់ នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុសំខាន់ៗ ដែលត្រូវបញ្ជាក់ដោយភស្តុតាង។[69]
- ដើមចោទត្រូវបង់ពន្ធដាក់ពាក្យសុំ ប៉ុន្តែលើកលែងតែករណីការផ្ដល់ជំនួយសង្គ្រោះលើបណ្ដឹង។[70]

**១.២.១.២. ការពិនិត្យលើពាក្យបណ្ដឹង**

កាលបើមានការដាក់ពាក្យបណ្ដឹងមកតុលាការ តុលាការត្រូវធ្វើការពិនិត្យពាក្យបណ្ដឹង[71] នោះ ដោយយោងលើមាត្រាដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដូចជា៖

[67] ចក សម្បត្តិ, «អនីតិសង្វាស» (ភ្នំពេញ,២០១៤), ទំព័រទី ៦៣-៦៤។
[68] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨២។
[69] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៧៥។
[70] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៦៥។

- ករណីដែលពាក្យបណ្តឹងមានចំណុចខ្វះខាត (របៀបដាក់ពាក្យបណ្តឹង និងចំណុចដែលត្រូវសរសេរក្នុងបណ្តឹង) តុលាការកំណត់អំឡុងពេលសមរម្យ និងបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតទាំងនោះ។
- ប្រសិនបើដើមចោទមិនបានកែតម្រូវចំណុចខ្វះខាតទេ តុលាការត្រូវលើកពាក្យបណ្តឹងចោលដោយដីកាសម្រេច។
- តុលាការត្រូវពិនិត្យទៅលើពន្ធដាក់ពាក្យសុំ កាលបើចាំបាច់។

ម្យ៉ាងទៀត ក្នុងករណីដែលបណ្តឹងមានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតនោះមិនអាចកែតម្រូវបានទេ តុលាការអាចលើកបណ្តឹងនោះចោល ដោយសាលក្រមបាន។[72]

ការពិនិត្យពាក្យបណ្តឹង ឬពាក្យសុំ តាមបញ្ញត្តិមាត្រា ៧៨ នៃក្រមរដ្ឋប្បវេណីកម្ពុជា កំណត់អំពីលក្ខខណ្ឌនៃបណ្តឹង ដោយចាត់ទុកពន្ធសម្រាប់ដាក់ពាក្យសុំ ក៏ជាលក្ខខណ្ឌសុពលភាពនៃបណ្តឹងដែរ។ តួយ៉ាង នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់អំពីការគណនាពន្ធដាក់ពាក្យសុំ ទៅតាមតម្លៃនៃកម្មវត្ថុនៃបណ្តឹង ចំពោះចំណងអាពាហ៍ពិពាហ៍ស្របច្បាប់។[73] ប៉ុន្តែ ពន្ធលើពាក្យសុំចំពោះរឿងអនីតិសង្វាសវិញ តុលាការត្រូវតែកំណត់តម្លៃដោយឆន្ទានុសិទ្ធិសមហេតុផល។

### ១.២.២. ដំណើរការនៃនីតិវិធី

នៅក្នុងដំណើរការនៃនីតិវិធី ច្បាប់នីតិវិធីត្រូវយកមកអនុវត្ត។ ក្រោយពីទទួលបានពាក្យសុំ ឬពាក្យបណ្តឹងស្តីពីអនីតិសង្វាស ឬផ្តាច់សមគ្គសង្វាសពីចុងចម្លើយរួចមក សាលាជម្រះក្តីនឹងដំណើរការនីតិវិធីរឿងក្តីនេះដោយឈរលើច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឬនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង ដោយធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល រួចចេញដីកាសម្រេច ក្នុងករណីមានការផ្សះផ្សារគ្នារវាងគូភាគី ឬដោយឈរលើក្រមនីតិវិធីរដ្ឋប្បវេណីដែលជាបញ្ញត្តិទូទៅ៖ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលដោយផ្ទាល់មាត់ ឬក៏លើកពាក្យបណ្តឹងចោល។ នៅដំណាក់កាលនីតិវិធីត្រៀម ជាទូទៅគូភាគីដែលជាដើមបណ្តឹង តែងតែធ្វើសេចក្តីថ្លែងការណ៍អំពីមូលហេតុដែលទាមទារនាំឱ្យមានការបញ្ជាក់ពីនត្ថិភាព នៃអាពាហ៍ពិពាហ៍ពីចុងចម្លើយ។

តើការចាត់ចែងរក្សាការពារ ដែលចែងក្នុងមាត្រា ៩៨៣ នៃក្រមរដ្ឋប្បវេណី អាចយកមកអនុវត្តនៅក្នុងរឿងក្តីផ្តាច់អនីសង្វាសបានដែរឬទេ? បើបាន តើបានក្នុងទំហំណា?

---

[71] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៧៨។

[72] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៨១។

[73] ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៦១។

ករណីដែលទទួលបណ្តឹងលែងលះគ្នា (អាពាហ៍ពិពាហ៍ស្របច្បាប់) ក្នុងករណីចាំបាច់ តុលាការអាចចេញដីការសម្រេចបង្គាប់ឱ្យធ្វើការចាត់ចែងរក្សាការពារដូចជា ការបំបែកលំនៅសង្វាស ការគ្រប់គ្រងថែរក្សាកូន ការគ្រប់គ្រងរក្សាទ្រព្យសម្បត្តិ អាហារកាតព្វកិច្ចរបស់សហព័ទ្ធ បន្ទុកសោហ៊ុយនៃអាពាហ៍ពិពាហ៍ និងសោហ៊ុយចញ្ចឹមបីបាច់កូន ជាអាទិ៍ តាមពាក្យសុំ ឬតាមឆន្ទានុសិទ្ធិរបស់តុលាការ។

ដូចនេះ ការចាត់ចែងរក្សាការពារក្នុងរឿងអនីតិសង្វាស តើគួរតែអាចអនុវត្តបានដោយយោងលើករណីខាងលើឬទេ?

ការទាញហេតុផលផ្ទាល់មាត់ ត្រូវបានធ្វើក្នុងករណីដែលតុលាការផ្អែកលើក្រមនីតិវិធីរដ្ឋប្បវេណី ឬមិនបានធ្វើ ប្រសិនបើតុលាការយកច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឬនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង។[74]

### ១.២.៣. ការវិនិច្ឆ័យសេចក្តី

ការអនុវត្តជាក់ស្តែងនៅសាលាជំនុំជម្រះក្តី តុលាការបានខ្ចីបញ្ញត្តិស្តីពីអាពាហ៍ពិពាហ៍នៅក្នុងក្រមរដ្ឋប្បវេណីទៅអនុវត្តនៅក្នុងរឿងក្តីអនីតិសង្វាស ដោយតុលាការលើកបណ្តឹងពីការផ្តាច់សមគ្គសង្វាសចំពោះអនីតិសង្វាសចោលពីចុងចម្លើយ ដោយយល់ថាពាក្យបណ្តឹងផ្ទុយនឹងច្បាប់ (តុលាការអាចទទួលយកបណ្តឹងទាមទារបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍)។ ការច្រានចោលបណ្តឹងបែបនេះ តុលាការមិនបានបង្ហាញអំពីទឡ្ហីករណ៍គតិយុត្តណាមួយច្បាស់លាស់នោះទេ ដោយគ្រាន់តែសំអាងថា វាជាបណ្តឹងដែលផ្ទុយនឹងច្បាប់តែប៉ុណ្ណោះ។ អាពាហ៍ពិពាហ៍គឺជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងនារីម្នាក់ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញតាមទំនើងចិត្តរបស់ខ្លួនឡើយ។ ចំណែកឯអនីតិសង្វាសវិញ មិនមានចែងនៅក្នុងច្បាប់ណាមួយនោះទេ មានតែក្រមព្រហ្មទណ្ឌត្រង់មាត្រា ២២២ តែប៉ុណ្ណោះ ដែលបានលើកឡើងអំពីសញ្ញាណនេះ តែមិនបានកំណត់ពីលក្ខណៈច្បាស់លាស់នោះទេ។

ដូច្នេះ ការច្រានចោលបណ្តឹងរបស់ដើមចោទ ដែលប្តឹងសុំទាមទារផ្តាច់សមគ្គសង្វាសពីចុងចម្លើយ ហាក់ដូចជាមិនបានផ្តល់ទឡ្ហីករណ៍ច្បាស់លាស់នៅឡើយ។ អាស្រ័យហេតុនេះហើយ ចាំបាច់ទាមទារឱ្យមានការសរសេរកម្មវត្ថុនៃបណ្តឹង និងការប្រើពាក្យនៅក្នុងសេចក្តីសម្រេចរបស់តុលាការឱ្យបានត្រឹមត្រូវ។ ជាក់ស្តែង បើមានចំណងអាពាហ៍ពិពាហ៍ត្រូវប្រើពាក្យ សុំលែងលះគ្នា តែបើគ្មានចំណងអាពាហ៍ពិពាហ៍ទេ(អនីតិសង្វាស) ត្រូវប្រើពាក្យ សុំទាមទារបញ្ជាក់នត្ថិភាព នៃអាពាហ៍ពិពាហ៍ជាដើម ជៀសវាងការប្រើពាក្យ សុំផ្តាច់សមគ្គសង្វាស។[75]

---

[74] ចក សម្បត្តិ, «អនីតិសង្វាស» (ភ្នំពេញ,២០១៤), ទំព័រទី ៦៦-៦៨។

[75] ចក សម្បត្តិ, «អនីតិសង្វាស» (ភ្នំពេញ,២០១៤), ទំព័រទី ៦៨-៧១។

## កថាខណ្ឌទី២ អានុភាពក្រោយការរំលាយអនីតិសង្វាស

### ២.១. អានុភាពរវាងអនីតិសង្វាសជន

បើសហព័ទ្ធឈានដល់ការលែងលះគ្នា ការរំលាយចំណងអាពាហ៍ពិពាហ៍នោះ ត្រូវសម្រេចដោយសាលក្រមរបស់តុលាការ ប៉ុន្តែករណីការរំលាយអនីតិសង្វាសវិញ អាចធ្វើឡើងតាមការព្រមព្រៀមរបស់គូភាគីក៏បាន ឬតាមសេចក្តីសម្រេចរបស់តុលាការ។ បើទោះបីមានពាក្យបណ្តឹង ឬពាក្យសុំឱ្យរំលាយអនីតិសង្វាស ឬសុំផ្តាច់អនីតិសង្វាសក៏ដោយ ពាក្យបណ្តឹងនោះនឹងត្រូវលើកចោលដោយសាលក្រម ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ដោយហេតុថា បណ្តឹងនោះជាបណ្តឹងផ្ទុយច្បាប់ ហើយចំណុចដែលខ្វះខាតរបស់ពាក្យបណ្តឹងនេះមិនអាចកែតម្រូវបានឡើយ។ ក៏ប៉ុន្តែ តុលាការអាចទទួលយកពាក្យបណ្តឹងទាមទារសុំឱ្យបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍ ពីអនីតិសង្វាសជនបាន។

កាលបើភាគីនៃអនីតិសង្វាសមានឆន្ទៈរំលាយអនីតិសង្វាស ភាគីនោះអាចធ្វើឡើងតាមការព្រមព្រៀងគ្នាដោយហេតុថា អនីតិសង្វាសគឺកើតឡើងតាមព្រឹត្តន័យ ឬសេរី ហើយលក្ខណៈជាក់ស្តែងមិនមែនជាចំណងគតិយុត្ត ព្រមទាំងនៅក្នុងក្រមរដ្ឋប្បវេណី ឬច្បាប់វិជ្ជមាននានានៅកម្ពុជាពុំបានបញ្ញត្តិគ្រប់គ្រងទៅលើបញ្ហាអនីតិសង្វាសនោះទេ ហេតុនេះការទាមទារផ្តាច់សមគ្គសង្វាស មិនអាចសម្រេចបានតាមផ្លូវតុលាការនោះទេ ពីព្រោះតុលាការសម្រេចសេចក្តីដោយផ្អែកលើភស្តុតាង និងបញ្ញត្តិច្បាប់ មិនមែនផ្អែកលើការយល់ឃើញ ឬឆន្ទានុសិទ្ធិក្រៅវង្វង់ច្បាប់ ឬហួសវិសាលភាពច្បាប់នោះទេ។

### ២.២. ការសម្រេចអំពីអ្នកមានអំណាចមេបាចំពោះកូន

កូននៅក្នុងទីនេះ សំដៅដល់កូនដែលមានចុះនៅក្នុងសំបុត្រអត្រានុកូលដ្ឋាន (សំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើត) ឬ ដែលមានការទទួលស្គាល់នៅក្នុងសេចក្តីសម្រេចរបស់តុលាការ។

ឪពុកម្តាយ ដែលមានចំណងអាពាហ៍ពិពាហ៍ស្របតាមច្បាប់ ត្រូវប្រើប្រាស់អំណាចមេបា ដោយសហការប៉ុន្តែចំពោះកូនដែលកើតឡើងក្នុងទំនាក់ទំនងអនីតិសង្វាស គឺមានតែអំណាចមេបាទោល ដែលជាម្តាយប៉ុណ្ណោះ។ ហេតុដែលបណ្តាលឱ្យមានតែម្តាយ ពីព្រោះស្ត្រីជាអ្នកសម្រាលកូន គឺជាម្តាយរបស់កូននោះ។[76] ចំណែកឪពុកវិញ គឺគ្មានមូលហេតុបិតុភាពតាមច្បាប់នោះទេ លើកលែងតែឪពុកបានទទួលស្គាល់កូននោះដោយស្ម័គ្រចិត្ត និងបានចុះសំបុត្រកំណើតកូនដោយដាក់ឈ្មោះ ខ្លួនថាជាឪពុករបស់កូននោះ វាជាហេតុនាំឱ្យមានទំនាក់ទំនងជាឪពុក និងកូនកើតឡើង ។[77]

---

[76] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨៧។

[77] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៩៣-៩៩៩។

ជាមួយគ្នានេះដែរ ឪពុកម្តាយនៃចំណងអាពាហ៍ពិពាហ៍ដែលពុំមានអំណាចមេបា ក្រោយការលែងលះ មានសិទ្ធិប្រាស្រ័យជួបទាក់ទងជាមួយនឹងកូនបាន និងត្រូវទទួលបន្ទុកនូវសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន។ [78] ដោយឡែកចំពោះអនីតិសង្វាស ស្ត្រីដែលជាម្តាយមិនអាចទាមទារសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនពីឪពុកបាននោះទេ លើកលែងតែឪពុកនោះបានទទួលស្គាល់កូន។ ប្រសិនបើឪពុកទទួលស្គាល់កូន អាចពិភាក្សា និងកំណត់ជាមួយម្តាយអំពីរបៀបចូលប្រាស្រ័យទាក់ទងគ្នា និងសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន។

**២.៣. សិទ្ធិ និងកាតព្វកិច្ចរបស់ឪពុកម្តាយដែលមិនរស់នៅជាមួយកូន**

តាមទស្សនៈរបស់ប្រទេសជប៉ុន ក្នុងករណីដែលមានការទទួលស្គាល់ទំនាក់ទំនងឪពុកនិងកូនបានកើតឡើងនោះ ឪពុក ឬម្តាយណាដែលមិនមានអំណាចមេបាចំពោះកូនអាចចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបានដូចក្នុងករណីអាពាហ៍ពិពាហ៍ដែរ ព្រមទាំងមានកាតព្វកិច្ចទទួលខុសត្រូវលើបន្ទុកសោហ៊ុយចាំបាច់សម្រាប់គ្រប់គ្រងថែរក្សាកូន។ ការកំណត់អំពីការចូលជួបនិងប្រស្រ័យទាក់ទងជាមួយកូននិងសោហ៊ុយចាំបាច់សម្រាប់ការគ្រប់គ្រងចិញ្ចឹមថែរក្សាកូនធ្វើឡើងដោយឆន្ទៈសេរីរបស់ភាគី លើកលែងតែមានការពិភាក្សាគ្នាមិនបានសម្រេច។

ការលើកឡើងខាងលើបែបនេះ គឺស្របទៅនឹង កថាខ័ណ្ឌទី៣ នៃមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បានចែងថា ឪពុកដែលមិនបានរស់នៅជាមួយកូនដែលបានទទួលស្គាល់កូន អាចពិភាក្សា និងកំណត់ជាមួយម្តាយ អំពីរបៀបជួបប្រាស្រ័យទាក់ទង និងសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងរក្សាកូនបាន។ ប្រសិនបើស្ថិតក្នុងករណីពុំបានសម្រេច ឬប្រសិនបើពុំអាចធ្វើការពិភាក្សាគ្នាបានទេ ត្រូវដាក់ពាក្យបណ្តឹងទៅតុលាការ ហើយវាគឺជាការចាំបាច់បំផុតក្នុងការកំណត់ និងផ្លាស់ប្តូរដែលត្រូវទទួលបន្ទុកលើសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ដោយតុលាការយកប្រយោជន៍របស់កូនជាអាទិភាព និងដោយពិចា-រណាទៅលើស្ថានភាពសេដ្ឋកិច្ចរបស់ ឪពុក ឬម្តាយនោះ។[79]

**២.៤. ការបែងចែកទ្រព្យសម្បត្តិរបស់អនីតិសង្វាស**

នៅពេលការរំលាយអនីតិសង្វាសមានអត្ថិភាពឡើង នឹងបង្កឱ្យមានបញ្ហាស្មុគ្រស្មាញពាក់ព័ន្ធទៅនឹងការបែងចែកទ្រព្យសម្បត្តិរបស់អនីតិសង្វាសជន។ ភាពជាក់ស្តែង អនីតិសង្វាសពុំមានប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធរួម និងប្រព័ន្ធទ្រព្យសម្បត្តិដោយឡែកដូច អាពាហ៍ពិពាហ៍ស្របច្បាប់នោះទេ។ ដោយសារអនីតិសង្វាសមិនមានប្រព័ន្ធទ្រព្យសម្បត្តិរួម ដូច្នេះ ការបែងចែកទ្រព្យសម្បត្តិគឺខុសពីសហព័ទ្ធត្រង់ថា គ្មានបញ្ញត្តិច្បាប់កំណត់ពីការ

[78] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៤០។

[79] ចក សម្បត្តិ, «អនីតិសង្វាស» (ភ្នំពេញ,២០១៤), ទំព័រទី ៧៧។

បែងចែកដូចសហព័ទ្ធ ប្រសិនបើ ការពិភាក្សាអំពីការព្រមព្រៀងបែងចែកទ្រព្យមិនសម្រេច។ ទោះជាបែបនោះក្តី មិនមែនមានន័យថាមិនអាចធ្វើការបែងចែកបាននោះទេ ការបែងចែកទ្រព្យសម្បត្តិនៃអនីតិសង្វាស គឺយើងអាចធ្វើបានតាមរយៈការជម្រះបញ្ជី។

ចំណែកឯការជម្រះបញ្ជី គឺអាស្រ័យទៅតាមរបបគតិយុត្តនៃទ្រព្យសម្បត្តិនីមួយៗ ដូចជា ទ្រព្យសម្បត្តិអនីតិ-សង្វាសជាកម្មសិទ្ធិអវិភាគ អនីតិសង្វាសបានបង្កើតក្រុមហ៊ុនណាមួយ និងសេចក្តីចម្រើនដោយឥតហេតុជាដើម។

ដូចនេះ អនីតិសង្វាសអាចទាមទារបានដោយផ្អែកទៅតាមរបបគតិយុត្ត នៃទ្រព្យសម្បត្តិនីមួយៗ ដែលយើងនឹងធ្វើការបកស្រាយជាបន្ត។

### ២.៤.១. ទ្រព្យជាកម្មសិទ្ធិអវិភាគ

ការណ៍ដែលមិនមានប្រព័ន្ធទ្រព្យសម្បត្តិរួម ទើបបានជាគោលការណ៍អនីតិសង្វាសជនម្នាក់ៗទទួលទ្រព្យតែដើម្បីជាប្រយោជន៍ខ្លួន។ ភស្តុតាងដើម្បីបញ្ជាក់អំពីទ្រព្យសម្បត្តិផ្ទាល់ខ្លួននោះ អាចត្រូវបានបង្ហាញតាមគ្រប់មធ្យោបាយ។ នៅពេលដែលទ្រព្យសម្បត្តិត្រូវបានបញ្ចូលគ្នា និងមិនអាចបែងចែកដាច់ពីគ្នាបានទ្រព្យសម្បត្តិទាំងនោះ នឹងត្រូវចាត់ទុកសម្បត្តិដែលក្រោមរបបគតិយុត្ត នៃកម្មសិទ្ធិអវិភាគ។

អ្វីទៅជាកម្មសិទ្ធិអវិភាគ?

កម្មសិទ្ធិអវិភាគ សំដៅដល់ស្ថានភាពដែលបុគ្គលច្រើននាក់មានកម្មសិទ្ធិស្របទៅតាមភាគចំណែករបស់ខ្លួន ដែលគិតទៅតាមចំនួននៅលើទ្រព្យតែមួយ។ រីឯចំណែកនៃម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ ត្រូវបានសន្មតថាស្មើគ្នា។[80]

ហេតុដូច្នេះ យើងអាចបកស្រាយទៅតាមប្រភេទនៃទ្រព្យសម្បត្តិនីមួយៗ ដែលទ្រព្យសម្បត្តិនោះត្រូវបែងចែកទៅតាមចំណែករបស់អនីតិសង្វាសជននីមួយៗ ប្រសិនបើមានភស្តុតាងអាចបញ្ជាក់ពីចំណែករបស់ខ្លួននោះបាន។ ប៉ុន្តែប្រសិនបើគ្មានភស្តុតាងបញ្ជាក់ពីចំណែករបស់ខ្លួនទេ នាំឱ្យទទួលបានចំណែកពាក់កណ្តាលស្មើគ្នា។ ម្យ៉ាងទៀត ប្រសិនបើស្ថានភាពដែលបុគ្គលច្រើននាក់មានកម្មសិទ្ធិស្របទៅតាមភាគចំណែករបស់ខ្លួនដែលគិតទៅតាមចំនួននៅលើទ្រព្យតែមួយ ហេតុនេះយើងអាចបែងចែកទ្រព្យតែមួយនោះ ទៅតាមចំណែកនៃកម្មសិទ្ធិអវិភាគម្នាក់ៗ ដោយត្រូវបានសន្មតថាទទួលបានចំណែកស្មើគ្នា។

ការបកស្រាយខាងលើនេះ សមស្របជាមួយបទបញ្ញត្តិស្តីពីកម្មសិទ្ធិអវិភាគ នៃក្រមរដ្ឋប្បវេណី។

### ២.៤.២. សេចក្តីចម្រើនឥតហេតុ

សេចក្តីចម្រើនឥតហេតុជាអ្វី?

[80] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ២០២-២០៣។

លក្ខខណ្ឌ និងអានុភាពនៃសេចក្តីចម្រើនដោយឥតហេតុ មានន័យថា ទោះបីជាគ្មានមូលហេតុលើផ្លូវច្បាប់ក៏ដោយ បុគ្គលដែលបានទទួលផលប្រយោជន៍ដោយសារទ្រព្យសម្បត្តិ ឬពលកម្មរបស់អ្នកដទៃ ហើយធ្វើឱ្យកើតមានការបាត់បង់ផលប្រយោជន៍ដល់អ្នកដទៃ និងកើតមានការបាត់បង់ផលប្រយោជន៍ដល់អ្នកដទៃដោយសារការទទួលនោះ ដូច្នេះបុគ្គលនោះត្រូវមានករណីកិច្ច សងប្រយោជន៍នោះត្រឹមកម្រិតដែលផលប្រយោជន៍នោះនៅមាន។[81] ម្យ៉ាងទៀត នៅក្នុងករណីដែលបានទទួលការផ្តល់តាវកាលិកពីអ្នកដទៃ ដោយយោងតាមកិច្ចសន្យានោះ ហើយប្រសិនបើកិច្ចសន្យានោះពុំមានអានុភាព ឬត្រូវបានបាត់បង់អានុភាព បុគ្គលដែលបានទទួលការផ្តល់តាវកាលិកនោះ ត្រូវមានករណីយកិច្ចត្រូវសងផលប្រយោជន៍ដែលខ្លួនបានទទួលដោយសារការផ្តល់តាវកាលិកនោះ ឱ្យអ្នកដទៃដែលបានផ្តល់តាវកាលិកនោះវិញ។[82]

បទបញ្ញត្តិស្តីពីសេចក្តីចម្រើនឥតហេតុនេះ ត្រូវគោរពលក្ខខណ្ឌចំនួនបួន គឺទីមួយ ភាគីម្ខាងទទួលបានសេចក្តីចម្រើន ទីពីរ ភាគីម្ខាងទៀតបាត់បង់ផលប្រយោជន៍ ទីបី សេចក្តីចម្រើននោះមិនមានមូលហេតុតាមផ្លូវច្បាប់ និងទីបួន មានចំណងរវាងសេចក្តីសចម្រើនឥតហេតុនឹងការបាត់បង់ផលប្រយោជន៍។ ដូចនេះ ករណីអនីតិសង្វាស អាចត្រូវបានយកអនុវត្តតាមបទញ្ញត្តិនេះផងដែរ។

### ២.៤.៣. ករណីមានកិច្ចសន្យាក្រុមហ៊ុន

នៅក្នុងករណីមួយចំនួនអនីតិសង្វាសជនទាំងសងខាង អាចដាក់ហ៊ុនចូលគ្នា និងបង្កើតជាក្រុមហ៊ុនមួយ។ កិច្ចសន្យាក្រុមហ៊ុន សំដៅទៅលើកិច្ចសន្យាបង្កើតជាក្រុម ដែលគ្មានការរៀបចំលក្ខណៈជានីតិបុគ្គល ដើម្បីប្រកបកិច្ចការដោយសហការគ្នា ដោយភាគីនីមួយៗធ្វើការវិនិយោគទ្រព្យធនរៀងៗខ្លួន។[83] តែប្រសិនបើមិនមានកិច្ចសន្យាក្រុមហ៊ុនកើតឡើងនោះទេ នោះភាគីណាម្ខាងអាចលើកឡើងថា មិនមានការកកើតឡើងនូវក្រុមហ៊ុនដែលកើតឡើងតាមអង្គហេតុបាន។ ក្នុងទិដ្ឋភាពគតិយុត្ត ក្រុមហ៊ុនប្រភេទនេះត្រូវចាត់ទុកជាមោឃៈ។ ប៉ុន្តែការជម្រះបញ្ជីនៃក្រុមហ៊ុនប្រភេទនេះ ត្រូវឱ្យម្ចាស់ហ៊ុនម្នាក់ៗមានចំណែកភាគទុនស្មើៗគ្នា ហើយត្រូវបំពេញលក្ខខណ្ឌនៃកិច្ចសន្យាក្រុមហ៊ុនដូចជា ទីមួយ ការដាក់ភាគហ៊ុនចូលគ្នា ទីពីរ ការចូលរួមក្នុងការចំណេញ ទីបី ការខាតបង់ និងទីបួន មានឆន្ទៈរួមគ្នាក្នុងការសហការគ្នា។

យោងតាមការបកស្រាយខាងលើ គឺដូចគ្នានឹងលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាក្រុមហ៊ុនដែរ ដោយសំដៅទៅដល់កិច្ចសន្យាបង្កើតជាក្រុម ដែលគ្មានការរៀបចំលក្ខណៈជានីតិបុគ្គល ដើម្បីប្រកបកិច្ចការដោយសហការគ្នា ដោយភាគីនីមួយៗ ធ្វើការវិនិយោគទ្រព្យធនរៀងៗខ្លួន ហើយកិច្ចសន្យាក្នុងបញ្ញត្តិនេះ មិនចាំបាច់

[81] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៣៦ កថាខណ្ឌទី១។

[82] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៣៦ កថាខណ្ឌទី២។

[83] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៦៩៩។

ធ្វើជាកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរនោះទេ។ ហេតុដូច្នេះហើយបញ្ញត្តិនេះ អាចយកទៅអនុវត្តនៅក្នុងករណីអនីតិសង្វាសបាន ដោយទាមទារឱ្យមានការចែកទ្រព្យសម្បត្តិតាមការជម្រះបញ្ជីបែបនេះ។ តែការជម្រះបញ្ជីក្រុមហ៊ុនប្រភេទនេះមិនមានបញ្ញត្តិណាមួយកំណត់ឱ្យបានច្បាស់លាស់នៅក្នុងក្រមរដ្ឋប្បវេណីទេ ប៉ុន្តែ អាចយកជម្រះបញ្ជីបានទៅតាមកម្មសិទ្ធិអវិភាគ ដោយចាត់ទុកថាទ្រព្យសម្បត្តិក្រុមហ៊ុនស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគ។

# ជំពូកទី៣
# ការអនុវត្តសិទ្ធិរបស់អនីតិសង្វាស

# ជំពូកទី៣
# ការអនុវត្តសិទ្ធិរបស់អនីតិសង្វាស

## ផ្នែកទី១ សិទ្ធិដែលអនីតិសង្វាសទទួលបាន

### ១.១. ការចុះសំបុត្រកំណើតកូនរបស់អនីតិសង្វាស

នៅក្នុងទំនាក់ទំនងអនីតិសង្វាស ករណីដែលប្តីប្រពន្ធមានកូន តើអនីសង្វាសអាចធ្វើការចុះសំបុត្រកំណើតកូនបានឬទេ?

ក្នុងទិដ្ឋភាពច្បាប់ ដូចជាក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ និងជាពិសេសច្បាប់ស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០២៣ បានកំណត់អំពីការចុះសំបុត្រកំណើតរបស់កូន តែពុំបានកំណត់ថាកូនដែលកើតពីសហព័ទ្ធ ឬកូនដែលកើតពីអនីតិសង្វសទេ។

នៅពេលដែលមានទារកកើត ឪពុក ឬម្តាយរបស់ទារក ត្រូវទៅរាយការណ៍ចុះសំបុត្រកំណើតនៅសាលាឃុំ ឬសង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ខ្លួន។[84] ប្រសិនបើឪពុក និងម្តាយមានធុរៈទៅមិនបានត្រូវពឹងពាក់សាច់ញាតិ ឬក៏អ្នកជិតខាងឱ្យទៅជំនួសបាន ក៏ប៉ុន្តែ សាច់ញាតិ និងអ្នកជិតខាងនោះ ត្រូវតែជាអ្នកដែលបានឃើញ និងបានដឹងឮផ្ទាល់ពីការកើតរបស់ទារកនេះ។

ហេតុដូចនេះ តាមការអនុវត្តជាក់ស្តែង ដោយឈរលើគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន និងប្រពៃណីទំនៀមទំម្លាប់ល្អរបស់ខ្មែរ កូនដែលកើតពីអនីតិសង្វាស គឺប្តីឬប្រពន្ធអាចចុះសំបុត្រកំណើតកូនបាន។

### ១.២. អំពីការគ្រប់គ្រងទ្រព្យសម្បត្តិអនីតិសង្វាស

យោងតាមការបកស្រាយជាបន្តបន្ទាប់ខាងលើ យើងឃើញថា ក្នុងទំនាក់ទំនងអនីតិសង្វាស ពុំមានប្រព័ន្ធទ្រព្យសម្បត្តិរួម និងប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យាប្តីប្រពន្ធឡើយ នោះមានន័យថា អនីតិសង្វាសជនម្នាក់ៗមានសិទ្ធិពេញលេញក្នុងការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន (ទ្រព្យសម្បត្តិដោយឡែក)។ និយាយដោយខ្លី ទ្រព្យសម្បត្តិរបស់អ្នកណា អ្នកនោះមានកម្មសិទ្ធិលើទ្រព្យសម្បត្តិនោះ។

ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិសង្វាស ខុសពីការគ្រប់គ្រងទ្រព្យរបស់សហព័ទ្ធ ពោលគឺប្រាក់ចំណូលដែលបានមកក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ស្របច្បាប់ អាចចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលច្បាប់ទទួលស្គាល់ដែលកំណត់ពីអំពីទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែក។[85] ចំណែកឯអនីតិសង្វាសវិញ ប្រាក់ចំណូលដែលបានមកក្នុងអំឡុងពេលអនីតិសង្វាសនេះ មិនត្រូវបានចាត់ទុកថាជាទ្រព្យរួមរបស់ភាគីទាំងពីរឡើយ ហើយប្តីប្រពន្ធមិនអាចតាក់តែង និងចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តី

[84] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៨៥។

ប្រពន្ធដែលច្បាប់ទទួលស្គាល់ ដែលមានខ្លឹមសារកំណត់អំពីទ្រព្យសម្បត្តិរួម និងដោយឡែក ឱ្យមានភាពច្បាស់លាស់ស្របទៅតាមឆន្ទៈរបស់ប្ដីប្រពន្ធឡើយ។

ប៉ុន្តែ អនីតិសង្វាសជន ក៏អាចបង្កើតកិច្ចសន្យាឯកជន ស្របតាមបញ្ញត្តិច្បាប់បាន ដោយកំណត់ពីការគ្រប់គ្រងទ្រព្យសម្បត្តិតាមឆន្ទៈរបស់គូភាគី។

ចំណែកឯ បទបញ្ញត្តិស្ដីពីការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក[86] មិនអាចយកមកអនុវត្តក្នុងករណីអនីតិសង្វាសបានឡើយ។

**១.៣. អំពីកម្មសិទ្ធិអវិភាគ**

ក្នុងទំនាក់ទំនងអនីតិសង្វាសពុំមានប្រព័ន្ធទ្រព្យសម្បត្តិដូចសហព័ទ្ធឡើយ ដូចនេះនៅពេលដែលទ្រព្យសម្បត្តិត្រូវបានបញ្ចូលគ្នា និងមិនអាចបែងចែកដាច់ពីគ្នាបាន ទ្រព្យសម្បត្តិទាំងនោះនឹងត្រូវស្ថិតក្រោមរបបគតិយុត្តនៃកម្មសិទ្ធិអវិភាគ។[87] នៅកម្ពុជា ប្រព័ន្ធចុះបញ្ជីអចលនទ្រព្យ អនីតិសង្វាសអាចធ្វើការចុះបញ្ជីបាន។

របបកម្មសិទ្ធិអវិភាគនេះ ត្រូវយកមកអនុវត្តចំពោះការគ្រប់គ្រង និងការបែងចែកទ្រព្យសម្បត្តិរបស់អនីតិសង្វាស ក្នុងករណីដែលពុំមានភាពច្បាស់លាស់ ឬនត្ថិភាពនៃភស្តុតាងដើម្បីបញ្ជាក់ពីទ្រព្យសម្បត្តិផ្ទាល់ខ្លួន។

**១.៤. អំពីសន្តតិកម្ម**

សន្តតិកម្ម គឺជាការផ្ទេរនូវសិទ្ធ និងករណីកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់ តាមឆន្ទៈ ឬតាមច្បាប់[88] ដែលមានភាគីម្ខាងជាសន្តតិជន ទទួលនូវមត៌កពីមតកជនដែលជាអ្នកបន្សល់ទុកនូវមត៌ក ដោយរាប់បញ្ចូលទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម។

**១.៤.១. សិទ្ធិទទួលបានទ្រព្យសម្បត្តិដោយសន្តតិកម្មនៃអនីតិសង្វាស**

សហព័ទ្ធរបស់មតកជន គឺជាសន្តតិជនជានិច្ច[89] ប៉ុន្តែភាគីម្ខាងនៃអនីតិសង្វាស មិនមែនជាសន្តតិជនជានិច្ចរបស់ភាគីម្ខាងទៀតនៃអនីតិសង្វាសនោះបានទេ។ ប៉ុន្តែភាគីនៃអនីតិសង្វាស អាចដាក់ពាក្យសុំទៅតុលាការ ដើម្បីទទួលបានមត៌កមួយផ្នែកដោយប្រើ ឋានៈជាជនមាននិស្ស័យពិសេសបាន។

[85] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៦៩ ៩៧២ និង៩៧៣។
[86] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៧។
[87] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ២០២-២១៤។
[88] សទ្ទានុក្រមផ្នែករដ្ឋប្បវេណី, លេខរៀង ១៤៣។
[89] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦១ កថាខណ្ឌ១។

### ១.៤.២. ការទទួលបានទ្រព្យសម្បត្តិនៃសន្តតិកម្ម

#### ក. ការទទួលបានទ្រព្យសម្បត្តិតាមរយៈមតកសាសន៍[90]

អនីតិសង្វាស អាចទទួលបាននូវទ្រព្យសម្បត្តិដែលជាសន្តិកម្មរបស់អនីតិសង្វាសបានទទួលមរណៈភាពម្ខាងទៀតតាមរយៈមតកសាសន៍។ ក្នុងករណីនេះ ប្រសិនបើអនីតិសង្វាសជនដែលទទួលមរណភាពបានបន្សល់ទុកនៅបណ្តាំ អនីតិសង្វាសជនដែលនៅរស់ នឹងទទួលបាននូវទ្រព្យសម្បត្តិដែលកំណត់ក្នុងមត៌កសាសន៍នោះ។

#### ខ. ការទទួលបានទ្រព្យសម្បត្តិតាមការកំណត់នៃច្បាប់[91]

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជាក៏បានផ្តល់សិទ្ធិឱ្យបុគ្គលដែលមិនមែនជាញាតិអាចទទួលបានទ្រព្យសម្បត្តិខ្លះផងដែរ។ ប៉ុន្តែ ជននោះត្រូវគោរពលក្ខខណ្ឌមួយចំនួនដូចជា៖

- ជននោះត្រូវតែមានជីវភាពជាមួយគ្នានឹងមតកជន ជនដែលបានខិតខំមើលថែទាំព្យាបាលមតកជន និងជនដែលមាននិស្ស័យពិសេសផ្សេងទៀត
- ករណីនត្ថិភាពនៃសន្តតិជន

ជនដែលមាននិស្ស័យពិសេសនោះ ត្រូវដាក់ពាក្យសុំក្នុងអំឡុងពេល ៣ ខែ ក្រោយអំឡុងពេលនៃការជូនដំណឹងជាសារធារណៈស្វែងរកសន្តតិជនបានកន្លងហួស និងត្រូវបញ្ជាក់អំពីហេតុនៃនិស្ស័យពិសេសនោះឱ្យច្បាស់ផងដែរ។

ប្រសិនបើមានការទទួលស្គាល់អនីតិសង្វាស ក្នុងឋានៈជាជនដែលមាននិស្ស័យពិសេស ការកំណត់ពីការផ្តល់ឱ្យនូវទ្រព្យសម្បត្តិដែលជាមត៌កនោះ ក្រមរដ្ឋប្បវេណីមិនបានកំណត់ថាទទួលបានប៉ុន្មានភាគ ឱ្យបានច្បាស់ដូចសហព័ទ្ធឡើយ គ្រាន់តែបានកំណត់ថា ចំនួននៃតម្លៃទ្រព្យដែលត្រូវចែកទៅឱ្យនោះ មិនត្រូវលើសពីពាក់កណ្តាលនៃមត៌កដែលនៅសេសសល់នោះទេ។[92]

## ផ្នែកទី២ សិទ្ធិដែលអនីតិសង្វាសមិនទទួលបាន

### ២.១. អំពីភេទ

ការទទួលស្គាល់នូវអនីតិសង្វាសរវាងបុគ្គលដែលមានភេទដូចគ្នា គឺជាការអនុវត្តយ៉ាងទន់ភ្លន់នូវច្បាប់តែរក្សាបាននូវស្ថិរភាពគតិយុត្តមួយដល់សង្គម ជាពិសេសស្ថាប័នអនុវត្តច្បាប់តែម្តង។ ភេទដូចគ្នា ត្រូវបានទទួលស្គាល់ជាអនីតិសង្វាសឬអត់ ត្រូវពិចារណាលើស្ថានភាពផ្សេងៗទៀត ដូចជា កត្តាសង្គមជាក់ស្តែងប៉ុណ្ណោះ។

ការទទួលស្គាល់ភេទផ្ទុយគ្នាបែបនេះ វាផ្ទុយនឹងទំនៀមទម្លាប់ដ៏ល្អរបស់សង្គមខ្មែរ។ ជាក់ស្តែង នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជា ត្រង់មាត្រា ៩៤៨ ប្តីប្រពន្ធ ត្រូវតែមានភេទផ្ទុយគ្នា ទើបអាចរៀបការបាន។ ដូចគ្នានេះដែរ

[90] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦៨-១១៩៨។

[91] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥៦-១១៦៧។

[92] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩៩។

នៅកម្ពុជា ដោយសារច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ បានកំណត់យ៉ាងច្បាស់ និងទទួលស្គាល់តែបុរសនារីដែលមានភេទផ្ទុយគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ជាសហព័ទ្ធស្របច្បាប់ប៉ុណ្ណោះ។ មួយវិញទៀត នៅពេលដែលមានបណ្ដឹងសុំរំលាយអនីតិសង្វាស ក្នុងការអនុវត្តជាក់ស្ដែងនៅតុលាការកម្ពុជា ភាគច្រើននៃបណ្ដឹង ទាំងនោះត្រូវបានធ្វើឡើងដោយភាគីដែលមានភេទផ្ទុយគ្នាប៉ុណ្ណោះ។ ហេតុនេះ ពុំចាំបាច់ពិចារណាដល់ភេទដូចគ្នាជាអនីតិសង្វាសឡើយ។ ចំណែកឯ នៅប្រទេសបារាំង ដោយមានការទទួលស្គាល់អាពាហ៍ពិពាហ៍ភេទដូចគ្នា។ អនីតិសង្វាស អាចត្រូវបានបង្កើតឡើងដោយគូភាគីដែលមានភេទដូចគ្នាផងដែរ ដូចមានកំណត់ក្នុងនិយមន័យនៃពាក្យ អនីតិសង្វាស ត្រង់មាត្រា ១៤៣ នៃក្រមរដ្ឋប្បវេណីបារាំង។ មួយវិញទៀត ប្រទេសជប៉ុនមិនមានការទទួលស្គាល់ភេទដូចគ្នាជាអនីតិសង្វាសនោះទេ ដោយមូលហេតុវាផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ ទំនៀមទម្លាប់ និងប្រពៃណីល្អរបស់សង្គមជប៉ុន។

ដូចនេះ ភេទដូចគ្នា នឹងត្រូវពិចារណាថាតើជាអនីតិសង្វាស ឬស្ថិតក្នុងស្ថានភាពផ្សេងទៀត?

### ២.២. អំពីទំនាក់ទំនងញាតិ

ញាតិ គឺសំដៅដល់ញាតិលោហិតក្នុង៦ថ្នាក់ សហព័ទ្ធ និងញាតិពន្ធក្នុង៣ថ្នាក់ ហើយបុគ្គលក្រៅពីនេះមិនមែនជាញាតិតាមផ្លូវច្បាប់ឡើយ។[93] នៅពេលបង្កើតអាពាហ៍ពិពាហ៍ស្របច្បាប់ ទំនាក់ទំនងញាតិក៏ត្រូវបានបង្កើតឡើងផងដែរ ពោលគឺមានទាំងញាតិរវាងសហព័ទ្ធ ទំនាក់ទំនងញាតិលោហិត និងទំនាក់ទំនងញាតិពន្ធ។ អាពាហ៍ពិពាហ៍ស្របច្បាប់ក្នុងទីនេះ សំដៅដល់អាពាហ៍ពិពាហ៍ដែលបានគោរពតាមលក្ខខណ្ឌឱឡារិកនៃអាពាហ៍ពិពាហ៍ ដែលមានចែងក្នុងមាត្រា ៣ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារឆ្នាំ១៩៨៩។

បើពិនិត្យទៅលើទំនាក់ទំនងអនីតិសង្វាស (ទំនាក់ទំនងតាមព្រឹត្តន័យ ឬសេរី) ពុំបានបង្កើត ទំនាក់ទំនងញាតិឡើយ ដោយមូលហេតុអវត្តមាននៃវិធានគតិយុត្តរបស់វា។ ជាសច្ចធារណ៍គតិយុត្ត អាពាហ៍ពិពាហ៍ស្របច្បាប់ បង្កើតទំនាក់ទំនងញាតិស្របច្បាប់ ហើយទំនាក់ទំនងញាតិស្របច្បាប់ បង្កើតសិទ្ធិនិងកាតព្វកិច្ចស្របច្បាប់រវាងញាតិ។ ផ្ទុយពីនេះ ទំនាក់ទំនងក្រៅគតិយុត្ត មិនបានធ្វើឱ្យមានអត្ថិភាពទំនាក់ទំនងញាតិឡើយ។

### ២.៣. អំពីទ្រព្យអកម្មរបស់អនីតិសង្វាស (បំណុល)

ក្នុងទំនាក់ទំនងអនីតិសង្វាស ពុំមានសកម្មភាពនៃការទទួលខុសត្រូវដោយសាមគ្គីភាពដូចសហព័ទ្ធទេ។ ប្រសិបើភាគីណាមួយនៃអនីតិសង្វាសបានជំពាក់បំណុល អ្នកដែលបានជំពាក់នោះត្រូវទទួលខុសត្រូវដោយខ្លួនឯង មិនពាក់ព័ន្ធជាមួយអនីតិសង្វាសជនម្ខាងទៀតឡើយ។ ប៉ុន្តែ ត្រូវចាត់ទុកថា ជាការទទួលខុសត្រូវរួមគ្នា ប្រសិនបើមានការព្រមព្រៀងរវាងអនីតិសង្វាសជនទាំងពីរ ដោយផ្ទាល់មាត់ក្តី ឬដោយលាយលក្ខណ៍អក្សរក្តី។

[93] ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៣៨។

## ២.៤. បណ្ដឹងផ្ដាច់អនីតិសង្វាស

ការអនុវត្តរបស់អនីតិសង្វាសមិនទាន់មានលក្ខណៈឯកភាព និងគោលការណ៍ច្បាប់ច្បាស់លាស់ក្នុងការបកស្រាយនៅឡើយនោះទេ ដោយហេតុថាការអនុវត្តជាក់ស្ដែងមានសាលក្រម ដែលត្រូវបានចេញឱ្យរំលាយអនីតិសង្វាស និងសាលក្រមលើកចោលបណ្ដឹងទាមទារឱ្យរំលាយអនីតិសង្វាស មានន័យថាតុលាការខ្លះទទួលស្គាល់ តុលាការខ្លះមិនទទួលស្គាល់។

នៅក្នុងនីតិវិធីនៃការរំលាយចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ គេអាចធ្វើបានតាមរយៈការដាក់ពាក្យសុំប្រសិនបើប្ដីប្រពន្ធនោះព្រមព្រៀងគ្នាលែងលះ ដោយប្រើនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង។ ផ្ទុយទៅវិញ ប្រសិនបើប្ដីប្រពន្ធនោះមិនព្រមព្រៀងគ្នាលែងលះនោះទ ភាគីដែលមានបំណងត្រូវដាក់ពាក្យបណ្ដឹងទៅតុលាការដោយប្រើប្រាស់នីតិវិធីបណ្ដឹងឋានៈបុគ្គល និងមានមូលហេតុស្របច្បាប់។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ដោយឆ្លងកាត់តាមការសិក្សាស្រាវជ្រាវ ក្រោមប្រធានបទ " **អនីតិសង្វាសនៅកម្ពុជា** " រួចមក ក្រុមរបស់យើងខ្ញុំយល់ឃើញថា របបអនីតិសង្វាសនៅកម្ពុជាមានលក្ខណៈស្មុគស្មាញ ព្រមទាំងមានការលំបាកក្នុងការអនុវត្តទៅតាមវិធានច្បាប់នៅទាំងក្នុងអំឡុងពេល និងក្រោយការរំលាយចំណងអនីតិសង្វាស។ តួយ៉ាង ប្តីប្រពន្ធដែលបានបង្កើតចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ពេលដែលត្រូវបញ្ចប់អាពាហ៍ពិពាហ៍ក៏ត្រូវតម្រូវឱ្យធ្វើស្របទៅតាមបញ្ញត្តិច្បាប់ដែរ។ ដោយឡែក ចំណងអនីតិសង្វាស ជាចំណងអាពាហ៍ពិពាហ៍ក្រៅគតិយុត្តិ ដូចនេះនៅពេលបញ្ចប់ក៏មិនតម្រូវឱ្យមាននីតិវិធីតឹងរឹងដូចអាពាហ៍ពិពាហ៍ស្របច្បាប់ដែរ។ ក៏ប៉ុន្តែ ដោយសារតែចំណងអនីតិសង្វាសនៅកម្ពុជា ពុំមានលិខិតបទដ្ឋានណាមួយបានកំណត់ឱ្យមានការអនុវត្តនោះទេ ការណ៍នេះនាំឱ្យមានការត្រិះរិះពិចារណា និងការបកស្រាយផ្សេងៗគ្នា។

ជាការពិណាស់ អនីតិសង្វាស គឺជាសមគ្គសង្វាសតាមព្រឹត្តន័យមួយដែលមានភាពខុសគ្នាពីអាពាហ៍-ពិពាហ៍ស្របច្បាប់ ហេតុនេះវាបង្កើតឱ្យមានអានុភាពគតិយុត្តដោយឡែក ខុសពីអាពាហ៍ពិពាហ៍ស្របច្បាប់។ ម្យ៉ាងទៀត បើទោះបីជាច្បាប់មិនបានកំណត់ពីការការពារផលប្រយោជន៍ ក្នុងការគ្រប់គ្រងប្រើប្រាស់ទ្រព្យសម្បត្តិរបស់អនីតិសង្វាសទាំងនៅអំឡុងពេលមានទំនាក់ទំនង និងក្រោយការរំលាយទំនាក់ទំនងក៏ដោយ ក៏មានលក្ខណៈពិសេសមួយចំនួនដែលបានធានានូវស្ថិរភាពនៃទ្រព្យសម្បត្តិដែលរកបានរៀងៗខ្លួនផងដែរ។ លើសពីនេះទៅទៀត ថ្វីត្បិតតែគ្មានប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់ និងប្រព័ន្ធទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យាដូចសហាព័ទ្ធក៏ដោយ ក៏អនីតិសង្វាសជន អាចធ្វើកិច្ចសន្យាកំណត់អំពីទ្រព្យសម្បត្តិដែលមានលក្ខណៈជាកិច្ចសន្យាឯកជនបានដែរ។ ក្រៅពីនេះ ក៏មានបទបញ្ញត្តិមួយចំនួនអាចយកមកបកស្រាយអំពីទំនាក់ទំនងទ្រព្យសម្បត្តិ នៃអនីតិសង្វាសបានដែរ ប្រសិនបើ សកម្មភាពអនីតិសង្វាសកើតឡើងស្របតាមការកំណត់ ឬអនុលោមតាមលក្ខខណ្ឌនៃបញ្ញត្តិ ដែលយើងបានបកស្រាយរួចមកហើយជាអាទិ៍ កម្មសិទ្ធិអវិភាគ កិច្ចសន្យាក្រុមហ៊ុនជាដើម។ ចំណែកឯបញ្ហាពាក់ព័ន្ធចំពោះបណ្តឹងវិញ ភាគច្រើនបណ្តឹងនៅប្រទេសកម្ពុជា គឺដើមចោទប្តឹងទាមទារឈប់រស់នៅជាអនីតិសង្វាស សុំសិទ្ធិអំណាចមេបាលើកូន និងសុំទាមទារលើការគ្រប់គ្រងកាន់កាប់ទ្រព្យសម្បត្តិ។ ការណ៍នេះប្រសិនបើភាគីនៃអនីតិសង្វាសមានឆន្ទៈរំលាយអនីតិសង្វាស ភាគីនោះអាចធ្វើឡើងតាមការព្រមព្រៀងគ្នាបាន ដោយហេតុថា អនីតិសង្វាសគឺកើតឡើងតាមព្រឹត្តន័យ ឬដោយសេរី ហើយលក្ខណៈជាក់ស្តែងមិនមែនជាចំណងគតិយុត្តដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ឬច្បាប់វិជ្ជមាននានានៅកម្ពុជា។ ទន្ទឹមនឹងនេះដែរ អនីតិសង្វាស អាចធ្វើការទាមទារផ្តាច់សមគ្គសង្វាសបាន ស្របទៅតាមការសម្រេចរបស់តុលាការផងដែរ ក្នុងករណីដែលអនីតិសង្វាសជនមានបញ្ហាក្នុងការរស់នៅជាមួយគ្នា ក៏ដូចជាមានភាពចម្រូងចម្រាស់គ្នា ហើយពួកគាត់អាចសុំសិទ្ធិទាមទារកាន់កាប់នូវទ្រព្យសម្បត្តិ ឬអំណាចមេបាលើកូនបាន។ ការស្នើសុំបែបនេះ នោះ

តុលាការសម្រេចសេចក្តីដោយផ្អែកលើភស្តុតាង និងផ្អែកលើការយល់ឃើញ ឬឆន្ទានុសិទ្ធិក្រៅវង្វង់ច្បាប់។ ចំណែកឯ ការរួមរស់ជាមួយគ្នា ឬការយកគ្នាជាប្តីប្រពន្ធរវាងមនុស្សដែលមានភេទដូចគ្នា កំពុងត្រូវបានពិចារណាថាតើជាអនីតិសង្វាស ឬស្ថិតក្នុងស្ថានភាពផ្សេងទៀត។

សរុបសេចក្តីមក នត្ថិភាពនៃបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងទំនាក់ទំនងអនីតិសង្វាស បានបង្កើតឱ្យមានភាពស្រពិចស្រពិលក្នុងការអនុវត្ត ជាពិសេសផ្តល់ផលលំបាកក្នុងការការពារ និងស្វែងរកផលប្រយោជន៍ដល់គូភាគី។ ការណ៍នេះធ្វើឱ្យមានការបកស្រាយ ព្រមទាំងអនុវត្តផ្សេងៗគ្នាពីសំណាក់អ្នកច្បាប់ ក៏ដូចជាអ្នកសិក្សានានានៅក្នុងសង្គមកម្ពុជា។ ក្នុងបរិបទនៃប្រទេសកម្ពុជា ប្រជាជនកម្ពុជាផ្តល់តម្លៃខ្ពស់ទៅលើការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីទំនៀមទំម្លាប់ ព្រោះថា ជីវិតគូត្រូវតែពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយ ក្នុងការជ្រើសរើសគូស្រករ ឬសម្រេចចិត្តរួមរស់ជាមួយគ្នា។

# អនុសាសន៍

# អនុសាសន៍

ដោយសារតែប្រទេសកម្ពុជា ទាក់ទងនឹងបញ្ហាអនីតិសង្វាសពុំមានច្បាប់ណាមួយ កំណត់ជាក់លាក់នៅឡើយទេ។ ដូច្នេះ ការយកបទបញ្ញត្តិស្តីពីអាពាហ៍ពិពាហ៍នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ មកអនុវត្តក្នុងរឿងក្តីអនីតិសង្វាស គឺវាកំពុងតែធ្វើឱ្យមានភាពច្របូកច្របល់ក្នុងប្រព័ន្ធច្បាប់កម្ពុជា។ ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងការសិក្សាវែកញែកតាមប្រភពឯកសារមួយចំនួនទៀត យើងឃើញថា មានការបកស្រាយផ្សេងៗគ្នាអំពីចំណងអនីតិសង្វាស នោះក៏ដោយសារតែចំណងអនីតិសង្វាសពុំមានបញ្ញត្តិក្នុងច្បាប់ណាមួយជាក់លាក់នៅឡើយ។

ហេតុនេះហើយ ដើម្បីកុំឱ្យមានភាពមិនចុះសម្រុងគ្នា ក្នុងការបកស្រាយលើករណីអនីតិសង្វាសនេះ យើងខ្ញុំសូមផ្តល់នូវអនុសាសន៍ខ្លះៗដូចរៀបរាប់ខាងក្រោម៖

- ផ្សព្វផ្សាយអំពីផលប្រយោជន៍នៃអាពាហ៍ពិពាហ៍ស្របច្បាប់និងគុណវិបត្តនៃអនីតិសង្វាស
  - គួរបង្កើនការផ្សព្វផ្សាយ និងអប់រំឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋកម្ពុជា អំពីផលប្រយោជន៍នៃអាពាហ៍ពិពាហ៍ស្របច្បាប់ និងគុណវិបត្តិនៃអនីតិសង្វាស។
  - ក្រសួងមហាផ្ទៃ ឬមន្ត្រីអត្រានុកូលដ្ឋាន និងស្ថាប័នដែលពាក់ព័ន្ធ គួរតែរៀបចំឱ្យមានជាសិក្ខាសាលា ឬវេទិកាសន្ទនាផ្សេងៗដែលទាក់ទងនឹងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ព្រោះការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីទំនៀមទម្លាប់មិនមែនជាអាពាហ៍ពិពាហ៍ស្របច្បាប់ទេ។
- បន្តអនុវត្តនីតិវិធីនៃការចុះបញ្ជីអាពាហ៍ពិពាហ៍ឱ្យបានឆាប់រហ័ស
  - ដោយសារនីតិវិធីនៃការចុះបញ្ជីអាពាហ៍ពិពាហ៍ ត្រូវឆ្លងកាត់តាមដំណាក់កាលដូចជា ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងការបិទផ្សាយជាសារធារណៈជាដើម។
  - គួរបង្ករលក្ខណៈងាយស្រួលដោយការចុះសំបុត្រអាពាហ៍ពិពាហ៍ឱ្យបានឆាប់រហ័សដល់ ប្តីប្រពន្ធដែលមិនទាន់បានចុះបញ្ជី និងជាពិសេសប្តីប្រពន្ធទើបរៀបការថ្មីថ្មោង។
  - ហេតុនេះហើយ មន្ត្រីអត្រានុកូលដ្ឋានគួរទៅចុះបញ្ជីអាពាហ៍ពិពាហ៍នៅកន្លែងដែលប្រជាពលរដ្ឋកំពុងរៀបការ ឬប្រារព្ធពិធីអាពាហ៍ពិពាហ៍តាមប្រពៃណីទំនៀមទម្លាប់ ដើម្បីពន្លឿននីតិវិធីនៃការចុះបញ្ជីអាពាហ៍ពិពាហ៍។
- កំណត់ឱ្យបានច្បាស់លាស់អំពីសញ្ញាណនៃអនីតិសង្វាស
  - ដោយសារតែនៅសង្គមកម្ពុជាបច្ចុប្បន្ន ពុំទាន់ឃើញមានច្បាប់ ឬលិខិតបទដ្ឋានណាមួយបញ្ញត្តិច្បាស់លាស់ដែលកំណត់អំពីសញ្ញាណរបស់អនីតិសង្វាសនៅឡើយទេ ករណីនេះធ្វើឱ្យមានវិវាទផ្លូវច្បាប់ និងភាពមិនឯកភាពគ្នាក្នុងការបកស្រាយអំពីចំណងអនីតិសង្វាសនៅក្នុងតុលាការ។

- ដូច្នេះ ដើម្បីកុំឱ្យមានបញ្ហាចម្រូងចម្រាស់គ្នា នៅពេលមានទំនាស់អនីតិសង្វាសកើតឡើងក្នុងតុលាការ គួរមានការកំណត់អំពីសញ្ញាណរបស់អនីតិសង្វាស ដូចជា និយមន័យ នីតិវិធីនៃការបង្កើត ការរំលាយ និងអានុភាពឱ្យបានច្បាស់លាស់ដូចអាពាហ៍ពិពាហ៍។
- គួរកំណត់អំពីប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិសង្វាសឱ្យបានច្បាស់លាស់
- រាជរដ្ឋាភិបាលកម្ពុជា គួររៀបចំឱ្យមាននូវលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិសង្វាសជន ដោយពុំមានការប៉ះពាល់ដល់ខ្លឹមសារនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជាទេ ប៉ុន្តែវាជាការផ្តល់សិទ្ធ សេរីភាពដល់អនីតិសង្វាសជន។

➢ ការជំរុញ និងការលើកទឹកចិត្ត

- ធ្វើការជំរុញដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព
- ត្រូវមានការចូលរួមសហការពីភាគីពាក់ព័ន្ធទាំងអស់ ទាំងស្ថាប័នរដ្ឋ និងឯកជនក្នុងការអប់រំផ្សព្វផ្សាយដល់សាធារណៈជនតាមដែលអាចធ្វើទៅបាន
- លើកទឹកចិត្ត និងបំផុសបំផុលដល់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសយុវជនដែលជាទំពាំងស្នងឫស្សីឱ្យពួកគេជ្រួតជ្រាបកាន់តែច្រើនឡើងៗលើវិស័យច្បាប់ និងផ្សព្វផ្សាយបន្ត។

# ឯកសារយោង

## ឯកសារយោង

### ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦
- ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
- ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆកា ឆ្នាំ២០០៩
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៩
- ច្បាប់ស្តីពីឯកពន្ធភាព, លេខ នសរ/កម/១០០៦/០២៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦
- នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ កយ.ប្រក/កម/១៣, ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣
- ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០
- ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០
- អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០
- អនុក្រឹត្យស្តីពីការកែសម្រួល មាត្រា ៨ និងមាត្រា ៥៩ នៃអនុក្រឹត្យលេខ ១០៣, លេខ ៦០ អនក្រ.បក, ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០០
- អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា ៥៩ថ្មី នៃអនុក្រឹត្យលេខ ៦០, លេខ ១៧ អនក្រ.បក, ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤
- អនុក្រឹត្យស្តីពីការកែសម្រួលចំណុច ក និង ចំណុច ខ នៃមាត្រា ៥៩ថ្មីស្ទួន នៃអនុក្រឹត្យលេខ ១៧, លេខ ១០៦ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៥
- អនុក្រឹត្យស្តីពីការកែសម្រួលចំណុច ក និង ចំណុច ខ នៃមាត្រា ៥៩ថ្មីស្ទួន នៃអនុក្រឹត្យលេខ ១០៦, លេខ ៨៩ អនក្រ.បក, ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៦
- សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃស្តីពីការចុះសៀវភៅអត្រានុកូលដ្ឋានឱ្យមាននិរន្តរភាព ក្រោយការបញ្ចប់យុទ្ធនាការចុះបញ្ជីអត្រានុកូលដ្ឋានចល័ត, លេខ ០០៨ សណន, ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៧

## សៀវភៅ និងអត្ថបទច្បាប់នានា

- ចក សម្បត្តិ «អនីតិសង្វាស» ភ្នំពេញ, បោះពុម្ព៖ ឆ្នាំ២០១៤
- ខៀវ សុខា «អនីតិសង្វាស និងទិដ្ឋភាពផ្លូវច្បាប់» ការចែករំលែកចំណេះដឹងផ្នែកច្បាប់
- អៀង សំអាង, *នីតិរដ្ឋប្បវេណី៖ នីតិឯកជន*, «អំពី អនីតិសង្វាស» ឆ្នាំ២០២០
- សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, «សទ្ទានុក្រមបារាំង-ខ្មែរនៃពាក្យច្បាប់», (ភ្នំពេញ៖ហ្វូណាន ឆ្នាំ២០០២)។
- Masayuki Tanamura, Professor of Law, Waseda University, *ការបកស្រាយអំពីប្រព័ន្ធទ្រព្យសម្បត្តិរួមប្តីប្រពន្ធ*
- សម្តេចព្រះសង្ឃរាជ ជួន ណាត, វចនានុក្រមខ្មែរភាគទី២, *ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិតកម្ពុជា, លេខ ១៦៥,* បោះពុម្ពគ្រាទី៥៖ ឆ្នាំ១៩៦៨

## ប្រភពអ៊ីនធើណែត

- អាចរកបាននៅ យល់ដឹងផ្នែកច្បាប់៖ អនីតិសង្វាស (freshnewsasia.com), (ចូលទស្សនាថ្ងៃទី ០៧/មិថុនា/២០២៤) លោកមេធាវី លឹម សុវណ្ណារ៉ុង និងលោក គន្ធ មូលសក្តា ជំនួយការមេធាវី, (ភ្នំពេញ, ២០២២/១១/២៧), *យល់ដឹងផ្នែកច្បាប់៖ អនីតិសង្វាស។*
- អាចរកបាននៅ https://youtu.be/QclHE_XqE2Q?si=YeL4d47k9w70MKzS, (ចូលទស្សនាថ្ងៃទី ១០/កក្កដា/២០២៤, (២០១៩/០៦/១៩), *ប្តីប្រពន្ធអនីតិសង្វាស ពេលលែងលះអាចប្តឹងទៅតុលាការបានឬទេ។*
- អាចរកបាននៅ https://m.postkhmer.com/law/2022-04-25-1100-235348.html, (ចូលទស្សនាថ្ងៃទី ២០/មិថុនា/២០២៤, លោកមេធាវី តាំង ហេងហុក, (ភ្នំពេញ, ២០២២/០៤/២៥), *តើប្តីប្រពន្ធមិនបានរៀបការ អាចប្តឹងគ្នាទារកូននៅតុលាការបានដែរឬទេ?*
- អាចរកបាននៅ ឈ្វេងយល់ពីការរំលោភអនីតិសង្វាស (lykosal.com), (ចូលទស្សនាថ្ងៃទី ១៥/កក្កដា/២០២៤, លោកមេធាវី តាំង ហេងហុក, (ភ្នំពេញ, ២០២៣/០៦/០៣), *ឈ្វេងយល់ពីការរំលោភអនីតិសង្វាស។*

# ឧបសម្ព័ន្ធ

# ច្បាប់

# ស្តីពី

# នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង

Khmer Law's Association

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រម

នស/រកម/០៧១០/០១៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលដៅនៃច្បាប់នេះ**

ច្បាប់នេះមានគោលដៅបញ្ញត្តនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។

**មាត្រា ២.- គោលបំណងនៃច្បាប់នេះ**

ច្បាប់នេះមានគោលបំណងធានាការអនុវត្តឲ្យបានត្រឹមត្រូវនូវនីតិវិធីក្នុងការដោះស្រាយរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។

**មាត្រា ៣.- វិសាលភាពនៃច្បាប់នេះ**

១- ក្នុងចំណោមចំណុចដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់តុលាការ ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ចំពោះចំណុចដែលកំណត់ក្នុងផ្នែកនីមួយៗ នៃតារាងឧបសម្ព័ន្ធ តុលាការត្រូវសម្រេចសេចក្តីតាមបញ្ញត្តិនៃច្បាប់នេះ លើកលែងតែករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង ។

២- ការសម្រេចសេចក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើងដោយដីកាសម្រេច ។

៣- ក្រៅពីករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់នេះ បញ្ញត្តិស្តីពីដីកាសម្រេច ដូចមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

## ជំពូកទី ២
## តុលាការ
### ផ្នែកទី ១
### សមត្ថកិច្ចសាលាជម្រះក្តី

**មាត្រា ៤.- តុលាការដែលមានសមត្ថកិច្ច**

១- រឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) ខាងលើនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ ។

ROYAUME DU CAMBODGE MINISTRE DU PALAIS ROYAL

Ksl

# ច្បាប់
# ស្តីពី
# នីតិវិធីបណ្តឹងទាក់ទង
# នឹងឋានៈបុគ្គល

Khmer Law's Association

# ព្រះរាជក្រម

នស/រកម/០៦១០/០០៩

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្ដីទាំងស្រុង ដូចតទៅនេះ ៖

ROYAUME DU CAMBODGE

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-** គោលដៅនៃច្បាប់នេះ

ច្បាប់នេះ មានគោលដៅបញ្ញត្តនូវករណីពិសេសនៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

**មាត្រា ២.-** គោលបំណងនៃច្បាប់នេះ

ច្បាប់នេះ មានគោលបំណងធានាការអនុវត្តឱ្យបានត្រឹមត្រូវនូវនីតិវិធីក្នុងការដោះស្រាយបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

**មាត្រា ៣.-** វិសាលភាពនៃច្បាប់នេះ

ច្បាប់នេះ មានវិសាលភាពអនុវត្តលើបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលរួមមានបណ្តឹងដូចខាងក្រោមនេះ៖

ក- បណ្តឹងទាមទារឱ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍ តាមបញ្ញត្តិនៃមាត្រា ៩៥៨ (មោឃភាពនៃអាពាហ៍ពិពាហ៍) នៃក្រមរដ្ឋប្បវេណី ។

ខ- បណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ តាមបញ្ញត្តិចាប់ពីមាត្រា ៩៥៩ (ការលុបចោលអាពាហ៍ពិពាហ៍) ដល់មាត្រា ៩៦៣ (ការលុបចោលអាពាហ៍ពិពាហ៍ ដោយការឆបោក ឬការគំរាម) នៃក្រមរដ្ឋប្បវេណី ។

គ- បណ្តឹងទាមទារលែងលះគ្នា តាមបញ្ញត្តិនៃមាត្រា ៩៧៨ (មូលហេតុនៃការលែងលះគ្នា) នៃក្រមរដ្ឋប្បវេណី ។

ឃ- បណ្តឹងបដិសេធបិតុភាព តាមបញ្ញត្តិនៃមាត្រា ៩៩០ (បណ្តឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក) និងមាត្រា៩៩១ (បណ្តឹងបដិសេធបិតុភាពពីកូន) នៃក្រមរដ្ឋប្បវេណី ។

ង-បណ្តឹងទាមទារឱ្យទទួលស្គាល់ តាមបញ្ញត្តិនៃមាត្រា ១០០១ (បណ្តឹងទាមទារឱ្យទទួលស្គាល់) នៃក្រមរដ្ឋប្បវេណី ។

ច- បណ្តឹងដែលមានគោលបំណងបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព តាមបញ្ញត្តិនៃមាត្រា ១០០២ (បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព) នៃក្រមរដ្ឋប្បវេណី ។

ឆ- បណ្តឹងដែលមានគោលបំណងបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព តាមបញ្ញត្តិនៃមាត្រា ១០០៤ (បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពពីកូន) និង មាត្រា ១០០៥ (បណ្តឹងទាមទារឱ្យបញ្ជាក់

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាល**

**លេខ :** ១០៣ អនក្រ បក

# អនុក្រឹត្យ
# ស្តីពី
# អគ្គានុកូលដ្ឋាន
# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១/៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៥៦ ក្រ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៨៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១/៩៦ /០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌

តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០០

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

អត្រានុកូលដ្ឋាន គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និងស្ថានភាពជាក់ស្តែង ដែលជននោះមាននៅក្នុងត្រកូល-គ្រួសារខ្លួន និងសង្គមជាតិ និងដែលបង្កើតឱ្យជននោះមានសិទ្ធិ និងករណីយកិច្ច ។

សំបុត្រអត្រានុកូលដ្ឋាន គឺជាសំបុត្រសម្រាប់កត់ត្រាភាពជាស៊ីវិលនៃពលរដ្ឋខ្មែរ និងជនបរទេសដែលរស់នៅស្រប ច្បាប់ ក្នុងដែនសមត្ថកិច្ចកំណត់ នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

សំបុត្រអត្រានុកូលដ្ឋានមាន សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព ។

**មាត្រា ៣.-**

ការសុំចុះអត្រានុកូលដ្ឋានក្នុងសៀវភៅអនុត្រានុកូលដ្ឋាន ជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។

**មាត្រា ៤.-**

រាល់ការសុំចុះសៀវភៅអនុត្រានុកូលដ្ឋាន កំណើត និងមរណភាព អ្នករាយការណ៍ និង/ឬ សាក្សី និង ឬសាមីខ្លួន ត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះការសុំចុះសៀវភៅអត្រានុកូលដ្ឋាន អាពាហ៍ពិពាហ៍ សាមីខ្លួន និងសាក្សី ត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រា-នុកូលដ្ឋាន ។

**មាត្រា ៥.-**

ទម្រង់បែបបទ និងសំបុត្រអត្រានុកូលដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយឯកភាពគ្នាទូទាំងប្រ-ទេស ។

គំរូសំបុត្រអត្រានុកូលដ្ឋាន ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៦.-**

ការចុះសៀវភៅអត្រានុកូលដ្ឋាន សម្រាប់ព្រះរាជវង្សានុវង្ស ត្រូវអនុវត្តដោយឡែក ដោយប្រគល់ភារកិច្ចនេះជូន រដ្ឋមន្ត្រីព្រះបរមរាជវាំង ។

**មាត្រា ៧.-**

រាល់សំបុត្រអត្រានុកូលដ្ឋានថតចម្លង មិនមានតម្លៃជាផ្លូវការឡើយ ។

មន្ត្រីអត្រានុកូលដ្ឋាន មិនត្រូវបញ្ជាក់លើសំបុត្រអត្រានុកូលដ្ឋានថតចម្លងទេ ។

## ជំពូកទី ៧
## អំពីសំបុត្របញ្ជាក់កំណើត

### មាត្រា ៤៣.-

ពលរដ្ឋខ្មែរដែលបានកើតមុនពេលមានអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រកំនើត ប្រើប្រាស់ អាចសុំចុះសៀវភៅបញ្ជាក់សំបុត្រកំណើតបាន តាមគំរូណែនាំថ្មី នៅសាលាឃុំ ឬសង្កាត់ ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២រូប ជានីតិជន និងជាមនុស្សគួរឱ្យជឿទុកចិត្តបាន ដែលបានស្គាល់ច្បាស់ពីប្រវត្តិអ្នកត្រូវសុំធ្វើសំបុត្របញ្ជាក់កំណើត និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬសង្កាត់ជាមួយ ពីពេលដែលសាមីខ្លួនកើតនាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះមន្ត្រីរាជការដែលបានទទួលបៀវត្ស ឬទទួលសោធននិវត្តន៍ ត្រូវយកឯកសារបៀវត្ស ឬសោធននិវត្តន៍ ឬសេចក្តីបញ្ជាក់ពីស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើត ហើយថ្ងៃ ខែ ឆ្នាំកំណើត ដែលចុះនៅក្នុងសៀវភៅបញ្ជាក់កំណើតមិនត្រូវឱ្យខុសពីថ្ងៃ ខែ ឆ្នាំកំណើត ដែលមាននៅក្នុងឯកសារបៀវត្ស ឬសោធននិវត្តន៍ជាផ្លូវការឡើយ ។

### មាត្រា ៤៤.-

ពេលមានអ្នកមកសុំចុះសៀវភៅកំនើត មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់កំណើត រួចត្រូវប្រគល់អោយសាមីខ្លួន ឬក្រុមគ្រួសារនូវសំបុត្របញ្ជាក់កំណើតច្បាប់ដើម ០១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ។

## ជំពូកទី ៨
## អំពីសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

### មាត្រា ៤៥.-

ពលរដ្ឋខ្មែរដែលបានគ្នាជាប្តី ឬប្រពន្ធ ពិតប្រាកដ នៅមុនពេលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានថ្មីនេះចូលជាធរមាន ហើយគ្មានសំបុត្រអាពាហ៍ពិពាហ៍ប្រើប្រាស់ សាមីខ្លួនប្តី ប្រពន្ធអាចមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បានតាមគំរូណែនាំថ្មីនៅសាលាឃុំ ឬសង្កាត់ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២រូប ជានីតិជន និងជាមនុស្សគួរឱ្យជឿទុកចិត្តបាន ដែលបានដឹងឮផ្ទាល់ពីសាមីខ្លួនប្តី ប្រពន្ធនោះ និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬសង្កាត់ជាមួយគ្នានាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

### មាត្រា ៤៦.-

ពេលមានសាមីខ្លួនប្តី និងប្រពន្ធមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់ឱ្យសាមីខ្លួនប្តី ប្រពន្ធនូវសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ច្បាប់ដើម ០១សន្លឹក និង ចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ។

សំបុត្រអត្រានុកូលដ្ឋានក្លែងបន្លំដែលបានចេញរួចហើយ ត្រូវប្រមូលយកមកវិញ និងប្តឹងទៅតុលាការ ដើម្បីបដិសេធ និងសុំផ្តន្ទាទោសតាមច្បាប់ ។

## ជំពូកទី១២

## អំពីថវិកាអត្រានុកូលដ្ឋាន

**មាត្រា ៥៦.-**

ការបោះពុម្ពសៀវភៅ សំបុត្រអត្រានុកូលដ្ឋាន និងការបណ្តុះបណ្តាល អំពីការងារអត្រានុកូលដ្ឋានដល់មន្ត្រីអត្រានុកូលដ្ឋានទូទាំងប្រទេសត្រូវស្ថិតនៅក្នុងបន្ទុកថវិការដ្ឋ ។

**មាត្រា ៥៧.-**

ក្រសួងមហាផ្ទៃត្រូវលើកគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់ការសុំបោះពុម្ពសៀវភៅ សំបុត្រអត្រានុកូលដ្ឋាន និងការបណ្តុះបណ្តាលការងារអត្រានុកូលដ្ឋាន ។

**មាត្រា ៥៨.-**

ការសុំចុះសំបុត្រអត្រានុកូលដ្ឋាន កំណើត និងមរណភាព អ្នកមកសុំមិនតម្រូវឱ្យបង់ថ្លៃអ្វីឡើយ ។

ការសុំច្បាប់រៀបអាពាហ៍ពិពាហ៍ និងការចុះសំបុត្រអត្រានុកូលដ្ឋាន អាពាហ៍ពិាហ៍ ការសុំបញ្ជាក់កំណើត បញ្ជាក់អាពាហ៍ពិពាហ៍ និងបញ្ជាក់មរណភាព អ្នកសុំត្រូវបង់ថ្លៃក្រដាសតាមការកំណត់ ។

រាល់ការសុំចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋានអ្នកមកសុំត្រូវបង់ថ្លៃក្រដាស និងថ្លៃបិទតែមប្រឹ ដើម្បីជាប្រយោជន៍សម្រាប់ ឃុំ ឬសង្កាត់ និងចំណូលថវិការដ្ឋ ។

ថ្លៃក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រិត្រូវកំណត់ដោយអនុក្រឹត្យ តាមសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ១៣

## អន្តរប្បញ្ញត្តិ

**មាត្រា ៥៩.-**

ការសុំបញ្ជាក់អត្រានុកូលដ្ឋានមានចុះសៀវភៅបញ្ជាក់កំណើត សៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅបញ្ជាក់មរណភាព ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរ ហើយអនុវត្តតែក្នុងរយៈពេល ៣ឆ្នាំ ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ។ ផុតរយៈពេលនេះ ពលរដ្ឋខ្មែរដែលគ្មានសំបុត្រអត្រានុកូលដ្ឋាន កំណើត និងមរណភាព ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត ក្រុងសាមី រួចយកសាលក្រមតុលាការនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋាន ។ ឯការបញ្ជាក់អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍អនុញ្ញាតឱ្យប្តឹងសុំចុះតាមការស្ម័គ្រចិត្តនៃសហព័ទ្ធ ។

**មាត្រា ៦០.-**

ហាមយកសំបុត្រអត្រានុកូលដ្ឋានរបស់ជនណាម្នាក់ ទៅប្រើប្រាស់ធ្វើជាសំបុត្រអត្រានុកូលដ្ឋានផ្ទាល់ខ្លួនរបស់ជន

**មាត្រា ៦៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ហត្ថលេខា ហត្ថលេខា ហត្ថលេខា

**ស ខេង យូ ហុកគ្រី អ៊ុក វិធុន**

**ចម្លងជូន**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋាន រដ្ឋសភា

-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៦៧

-កាលប្បវត្តិ-ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ : ៦០ អនក្រ.បក**

# អនុក្រឹត្យ

# ស្តីពី

# ការកែសំរួលមាត្រា ៨ និងមាត្រា ៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១/៩៧/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៥៦ក្រ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៨៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន
-យោងតាមសំណើរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

## សំរេច

**មាត្រា២** ១.~ ត្រូវបានកែសម្រួលមាត្រា ៨ និងមាត្រា ៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្ដីពីអត្រានុកូលដ្ឋានដូចខាងក្រោម :

**មាត្រា ៨ ថ្មី.~**

ក្រុមប្រឹក្សាឃុំ សង្កាត់ទទួលខុសត្រូវការងារអត្រានុកូលដ្ឋានក្នុងដែនដី ឃុំ ឬសង្កាត់ ដែលខ្លួនគ្រប់គ្រង ។

មេឃុំ ចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋាន ។

**មាត្រា ៥៩ ថ្មី.~**

ការសុំបញ្ជាក់អត្រានុកូលដ្ឋានមានចុះ សៀវភៅបញ្ជាក់កំណើត សៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅបញ្ជាក់មរណភាព ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរ ហើយអនុវត្តតែក្នុងរយៈពេល ៣ឆ្នាំ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ ។

ផុតរយៈពេលនេះ ពលរដ្ឋខ្មែរដែលគ្មានសំបុត្រអត្រានុកូលដ្ឋានកំណើត និងមរណភាពត្រូវទៅសុំសាលក្រមពីតុលាការ ខេត្ត ក្រុងសាមី រួចយកសាលក្រមនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬសង្កាត់ ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋាន ។ ឯការបញ្ជាក់អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍អនុញ្ញាតអោយប្ដឹងសុំចុះតាមការស្ម័គ្រចិត្តនៃសហព័ទ្ធ ។

សំរាប់ ឆ្នាំ ២០០២ សៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទត្រូវបានអនុញ្ញាតអោយបើកប្រើប្រាស់ចាប់ពីថ្ងៃទី ០១ ខែ សីហា ហើយត្រូវបញ្ឈប់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ ។

ចាប់ពីឆ្នាំ ២០០៣ តទៅត្រូវអនុវត្តបទបញ្ញត្តិដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៤ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ។

រាជធានីភ្នំពេញ.ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

បានយកសេចក្ដីជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា ហត្ថលេខា

**ស ខេង យូ ហុកគ្រី**

**<u>ចម្លងជូន</u>**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ...១៧៥....អនក្រ - បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសំរួលអនុក្រឹត្យស្តីពីអគ្រានុកូលដ្ឋាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១/៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអគ្រានុកូលដ្ឋាន ។
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការកែសំរួលមាត្រា ៨ និង មាត្រា៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអគ្រានុកូលដ្ឋាន ។
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## សំរេច

**មាត្រាតែមួយ .-**

កែសំរួលមាត្រា ២៥ មាត្រា ៤០ មាត្រា ៤៣ មាត្រា ៤៥ មាត្រា ៤៧ មាត្រា ៥១ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអគ្រានុកូលដ្ឋាន



Downloaded from http://www.khmerlaws.com

និងមាត្រា ៥៩ ថ្មី នៃអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្ដីពីការកែសំរួលមាត្រា៥៨ និង មាត្រា៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្ដីពីអត្រានុកូលដ្ឋាន ដូចខាងក្រោម ៖

**មាត្រា២៥ថ្មី ._**

បើមានទារកកើតហើយ ទុកអោយហួសរយៈពេល ៣០ ថ្ងៃ ពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ឪពុក ឬ ម្ដាយ ឬ អាណាព្យាបាល ត្រូវប្ដឹងសុំសំបុត្រកំណើតនេះពី មេឃុំ ចៅសង្កាត់ សាមី ដោយបង់ប្រាក់ថ្លៃសំបុត្រកំណើតដល់អាជ្ញាធរ ឃុំ សង្កាត់សាមី ចំនួន ១.០០០ (មួយពាន់) រៀលសំរាប់ប្រជាពលរដ្ឋមានទីលំនៅនៅក្នុងខេត្ត រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ ឧត្ដរមានជ័យ និង ៤.០០០ (បួនពាន់) រៀល សំរាប់ប្រជាពលរដ្ឋ ដែលមានទីលំនៅក្រៅពីខេត្តខាងលើ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្ដីណែនាំបន្ថែមអំពីបែបបទ និង នីតិវិធីនៃការសុំ និង ការចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ក្នុងករណីខាងលើនេះ ។

**មាត្រា៤០ថ្មី ._**

បើមានអ្នកស្លាប់ទុកអោយហួសរយៈពេល ១៥ ថ្ងៃ ពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ក្រុមគ្រួសារ នៃអ្នកស្លាប់ត្រូវប្ដឹងសុំសំបុត្រមរណភាពពី មេឃុំ ចៅសង្កាត់សាមី ដោយបង់ថ្លៃសំបុត្រមរណភាពនេះដល់អាជ្ញាធរឃុំ សង្កាត់សាមីចំនួន១.០០០ (មួយពាន់) រៀល សំរាប់ប្រជាពលរដ្ឋមានទីលំនៅ នៅក្នុងខេត្ត រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ ឧត្ដរមានជ័យ និង ៤.០០០ (បួនពាន់) រៀល សំរាប់ប្រជាពលរដ្ឋ ដែលមានទីលំនៅក្រៅពីខេត្តខាងលើ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្ដីណែនាំបន្ថែម អំពីបែបបទ នីតិវិធី នៃការសុំ និង ការចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ក្នុងករណីខាងលើនេះ ។

**មាត្រា៤៣ថ្មី ._**

ពលរដ្ឋខ្មែរដែលកើតមុនពេលមានអនុក្រឹត្យ ស្ដីពីអត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រកំណើតប្រើប្រាស់ អាចសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតបានតាមគំរូណែនាំថ្មី នៅ សាលាឃុំ សង្កាត់ ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សី ចំនួន ០២ រូប ជានីតិជន ហើយត្រូវមានទីលំនៅពិតប្រាកដ នាំមកបញ្ជាក់នៅចំពោះមុខ មន្ត្រីអត្រា-នុកូលដ្ឋាន ។

ចំពោះមន្ត្រីរាជការដែលបានទទួលបៀវត្ស ឬ ទទួលសោធននិវត្តន៍ ត្រូវយកឯកសារបៀវត្ស ឬ សោធននិវត្តន៍ ឬ សេចក្ដីបញ្ជាក់ពីក្រសួងស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើត ហើយថ្ងៃ ខែ ឆ្នាំកំណើត ដែលចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត មិនត្រូវអោយខុសពីថ្ងៃ ខែ ឆ្នាំកំណើត ដែលមាននៅក្នុងឯកសារបៀវត្ស ឬ សោធននិវត្តន៍ជាផ្លូវការឡើយ ។



Downloaded from http://www.khmerlaws.com

**មាត្រា៤៥ថ្មី ..**

ពលរដ្ឋខ្មែរដែលបានរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្ដីប្រពន្ធ នៅមុនពេលដែលមានអនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋានថ្មីនេះចូលជាធរមាន ហើយមិនទាន់បានចុះសៀវភៅអាពាហ៍-ពិពាហ៍ សាមីខ្លួនទាំងពីររូបអាចសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បានតាមគំរូណែនាំថ្មី នៅសាលាឃុំ ឬ សង្កាត់ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២ រូប ជានីតិជន និងតាមច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ។

**មាត្រា៤៧ថ្មី ..**

ពលរដ្ឋខ្មែរដែលស្លាប់មុនពេលមានអនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រមរណភាព សាច់ញាតិសន្ដាន ដែលនៅរស់អាចមកសុំចុះ សៀវភៅបញ្ជាក់មរណភាពបានតាមគំរូណែនាំថ្មី នៅសាលា ឃុំ ឬ សង្កាត់ ដែលញាតិសន្ដានរស់នៅជាប់លាប់បច្ចុប្បន្ន ដោយនាំសាក្សី ចំនួន ០២ រូប ជានីតិជន ហើយមានទីលំនៅពិតប្រាកដ មកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

**មាត្រា៥១ថ្មី ..**

ការសុំចម្លង ឬ សំរង់សំបុត្រអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅសាលាឃុំ ឬ សាលាសង្កាត់ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំឬសង្កាត់ ហើយត្រូវបោះត្រាផង ។

**មាត្រា៥៩ថ្មីស្ទួន ..**

**ក.** ការសុំបញ្ជាក់អត្រានុកូលដ្ឋានមាន ចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ ។

ផុតរយៈពេលនេះ ពលរដ្ឋខ្មែរដែលគ្មានសំបុត្រអត្រានុកូលដ្ឋានកំណើត និង មរណភាព ត្រូវទៅសុំសំបុត្រអត្រានុកូលដ្ឋាន តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា២៥ថ្មី និង មាត្រា៤០ថ្មី នៃអនុក្រឹត្យនេះ ។ ចំពោះអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ អនុញ្ញាតអោយប្ដីងសុំចុះតាមការស្ម័គ្រចិត្តនៃសហព័ទ្ធ ។

សំរាប់ឆ្នាំ ២០០២ សៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទត្រូវបានអនុញ្ញាតអោយបើកប្រើប្រាស់ចាប់ពីថ្ងៃទី ០១ ខែ សីហា ហើយត្រូវបញ្ឈប់បញ្ជីត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ ។

ចាប់ពីឆ្នាំ ២០០៣ តទៅ ត្រូវអនុវត្តបទបញ្ញត្តិដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ មាត្រា ១៤ នៃអនុក្រឹត្យលេខ ១០៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ។



Downloaded from http://www.khmerlaws.com

**ខ.**ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ ប្រជាពលរដ្ឋ ដែលបានមកចុះសៀវភៅអត្រានុកូលដ្ឋានរួមមាន បញ្ជាក់កំណើត និង បញ្ជាក់មរណភាព នឹងត្រូវបានផ្តល់ជូនសំបុត្រអត្រានុកូលដ្ឋានខាងលើនេះនូវច្បាប់ដើម ០១សន្លឹកដោយឥតគិតថ្លៃ ។

ចំពោះទារកដែលបានកើតក្នុងចន្លោះពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ ដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០៥ ហើយដែលមិនទាន់បានចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅពេលដែលឪពុកឬម្តាយ ឬ អាណាព្យាបាល មកសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត អោយទាន់ពេលក្នុងថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ នោះនឹងត្រូវបាន ផ្តល់ជូនសំបុត្រអត្រានុកូលដ្ឋានកំណើតច្បាប់ដើម ០១ សន្លឹកដោយឥតគិតថ្លៃ ។

**គ.**ដើម្បីបង្កលក្ខណៈសម្បត្តិងាយស្រួល ជូនប្រជាពលរដ្ឋ ក្នុងការចុះសៀវភៅអត្រានុកូលដ្ឋាន ឃុំ សង្កាត់ អាចចាត់អោយមានការចុះសៀវភៅអត្រានុកូលដ្ឋានចល័តក្នុងឃុំ សង្កាត់របស់ខ្លួនតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី**

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង យូ ហុកគ្រី

**ចម្លងជូន :**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ កាលប្បវត្តិ ។



Downloaded from http://www.khmerlaws.com

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១០៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសំរួលចំណុច "ក" និង "ខ" មាត្រា ៥៩ថ្មីស្ទួន នៃអនុក្រឹត្យ លេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០៤ ស្តីពីការកែសំរួលអនុក្រឹត្យ ស្តីពីអគ្រានុកូលដ្ឋាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអគ្រានុកូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការកែសំរួលមាត្រា ៨ និង មាត្រា៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអគ្រានុកូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលអនុក្រឹត្យស្តីពីអគ្រានុកូលដ្ឋាន
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រាតែមួយ .-**

កែសំរួលចំណុច "ក" និង "ខ" មាត្រា ៥៩ថ្មីស្ទួន នៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០៤ ស្តីពីការកែសំរួលអនុក្រឹត្យស្តីពីអគ្រានុកូលដ្ឋាន មានដូចខាងក្រោម :

**មាត្រា៥៩ថ្មីស្ទួន ..**

**ក.** ការសុំបញ្ជាក់អត្រានុកូលដ្ឋានមាន ចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៦ ។

ផុតរយៈពេលនេះ ពលរដ្ឋខ្មែរដែលគ្មានសំបុត្រអត្រានុកូលដ្ឋានកំណើត និង មរណភាព ត្រូវទៅសុំសំបុត្រអត្រានុកូលដ្ឋាន តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា២៥ថ្មី និង មាត្រា៤០ថ្មី នៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការកែសំរួល អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ។ ចំពោះអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ អនុញ្ញាតអោយប្តីង សុំចុះតាមការស្ម័គ្រចិត្តនៃសហព័ទ្ធ ។

**ខ.**ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៦ ប្រជាពលរដ្ឋខ្មែរដែលបានមកចុះសៀវភៅអត្រានុកូលដ្ឋាន រួមមាន បញ្ជាក់កំណើត និង បញ្ជាក់មរណភាព នឹងត្រូវផ្តល់ជូនសំបុត្រអត្រានុកូលដ្ឋានខាងលើនេះនូវច្បាប់ដើម ០១សន្លឹកដោយឥតគិតថ្លៃ ។

ចំពោះទារកដែលបានកើតក្នុងចន្លោះពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ ដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០៦ ហើយដែលមិនទាន់បានចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅពេលដែល ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល មកសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត អោយទាន់ពេល មិនហួសពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៦ នឹងត្រូវបានផ្តល់ជូនសំបុត្រអត្រានុកូលដ្ឋានកំណើត ច្បាប់ដើម ០១ សន្លឹកដោយឥតគិតថ្លៃ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន :**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ កាលប្បវត្តិ

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង** **នរោត្តម សិរីវុឌ្ឍ**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

ក្រសួងមហាផ្ទៃ

លេខ : ០០៤ សណន

លិខិតចូល

ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៧

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៧

# សេចក្តីណែនាំ

## ស្តីពី

## ការចុះសៀវភៅអត្រានុកូលដ្ឋាន ឱ្យមាននិរន្តរភាពក្រោយបញ្ចប់យុទ្ធនាការ ចុះសៀវភៅអត្រានុកូលដ្ឋានចល័ត

ការចុះសៀវភៅអត្រានុកូលដ្ឋាន គឺជាការផ្តល់នូវឯកសារគតិយុត្តិដ៏សំខាន់ចាំបាច់ ជូនប្រជាពលរដ្ឋទាក់ទងនឹងកំណើត អាពាហ៍ពិពាហ៍ និង មរណភាព។ ឯកសារគតិយុត្តិទាំងនេះ គឺជាឯកសារ និងជាភស្តុតាងដ៏មានតម្លៃបំផុតក្នុងជីវិតរបស់មនុស្សម្នាក់ៗសម្រាប់បញ្ជាក់អំពីអត្តសញ្ញាណ និង ស្ថានភាពស៊ីវិលរបស់ខ្លួនក្នុងគោលដៅលើកស្ទួយនូវសិទ្ធិ ករណីយកិច្ចរបស់ប្រជាពលរដ្ឋម្នាក់ ៗ នៅក្នុងត្រកូលគ្រួសារខ្លួន និង សង្គមជាតិ ។ ក្នុងសង្គមប្រជាធិបតេយ្យ និងនីតិរដ្ឋ ប្រជាពលរដ្ឋគ្រប់ៗរូបតែងតែប្រើប្រាស់ឯកសារអត្រានុកូលដ្ឋានសំរាប់ការពារសិទ្ធិ សេរីភាព ផលប្រយោជន៍ និង កាតព្វកិច្ចនានា ក្នុងសង្គម ។

អនុលោមតាមអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពី អត្រានុកូលដ្ឋាន អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន អនុក្រឹត្យលេខ ៨៩ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលចំណុច "ក" និង "ខ" មាត្រា ៥៩ថ្មីស្ទួន នៃអនុក្រឹត្យលេខ ១០៦ អនក្រ. បក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៥ ស្តីពី ការកែសម្រួលចំណុច "ក" និង "ខ" មាត្រា ៥៩ ថ្មី ស្ទួន ។

ក្រោយពីយុទ្ធនាការ នៃការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត ត្រូវបានបញ្ចប់នៅថ្ងៃទី [illegible] ឆ្នាំ ២០០៦ និង ដើម្បីឱ្យដំណើរការ នៃការចុះសៀវភៅអត្រានុកូលដ្ឋានអនុវត្តទៅបានល្អប្រសើរ និង [illegible] ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំ ដូចខាងក្រោម ÷

**I- អំពីភារកិច្ច :**

**១- ថ្នាក់ក្រសួង :**

នាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជាសេនាធិការឱ្យក្រសួង លើការងារស្ថិតិ និង អត្រានុកូលដ្ឋាន និង មានភារកិច្ច ដូចខាងក្រោម ÷

kinira 11.04.07

Downloaded from http://www.khmerlaws.com

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខ្ញុំបាទ នាងខ្ញុំឈ្មោះ------------------------សញ្ជាតិ---------- កើតថ្ងៃទី------ ខែ-------ឆ្នាំ------- មុខរបរបច្ចុប្បន្ន-----------------------------------------ស្ថានភាពផ្ទាល់ខ្លួន---------------------ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ--------- ផ្លូវលេខ---------- ក្រុម---------- ភូមិ------------ ឃុំ សង្កាត់ ---------------- ក្រុង ស្រុក ខណ្ឌ----------------- រាជធានី ខេត្ត ------------------ ។ ឪពុកឈ្មោះ--------------------------អាយុ-------ឆ្នាំ (រស់ ស្លាប់) ម្តាយឈ្មោះ----------------------អាយុ-------ឆ្នាំ (រស់ ស្លាប់) ។

**គោរពជូន**

**មន្ត្រីអ ត្រានុកូលដ្ឋានឃុំ សង្កាត់.......................................**

<u>**កម្មវត្ថុ**</u> ៖ សំណើសុំរៀបអាពាហ៍ពិពាហ៍ ។

ដោយខ្ញុំបាទ នាងខ្ញុំ បានស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ----------------------ភេទ------ សញ្ជាតិ-----------កើតថ្ងៃទី------ ខែ-------ឆ្នាំ--------------------------------មុខរបរ------------------------- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ-------- ផ្លូវលេខ--------- ក្រុម--------- ភូមិ--------------ឃុំ សង្កាត់------------------ ក្រុង ស្រុក ខណ្ឌ------------------- រាជធានី ខេត្ត ------------------ប្រទេស ------------------ ។

ខ្ញុំសូមសន្យាថា នឹងអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា នៃ ព្រះរាជាណាចក្រកម្ពុជា ។

អាស្រ័យហេតុនេះ សូមមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់------------------------------ មេត្តាអនុញ្ញាត ឱ្យយើងខ្ញុំទាំងពីរបានរៀបអាពាហ៍ពិពាហ៍តាមសំណូមពរដោយអនុគ្រោះ ។

ធ្វើនៅ-------------ថ្ងៃទី------- ខែ----------- ឆ្នាំ-------

**ស្នាមមេដៃស្តាំសាមីខ្លួន**

<u>សូមជូនភ្ជាប់ជាមួយនូវ</u> ៖

– ------------------------------
– ------------------------------
– ------------------------------

ឈ្មោះ-----------

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំបញ្ជាក់
## ភាពនៅលីវ ភាពពោះម៉ាយ ភាពមេម៉ាយ

ខ្ញុំបាទ នាងខ្ញុំឈ្មោះ-------------------- ភេទ------- សញ្ជាតិ------- កើតនៅថ្ងៃ----------ទី------ ខែ-------ឆ្នាំ-------- នៅភូមិ------------------- ឃុំ សង្កាត់---------------------ក្រុង ស្រុក ខណ្ឌ-------------- រាជធានី ខេត្ត--------------------- មុខរបរបច្ចុប្បន្ន----------------------ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ---------- ផ្លូវលេខ-------- ក្រុម------ ភូមិ----------- ឃុំ សង្កាត់------------ ក្រុង ស្រុក ខណ្ឌ------------------ រាជធានី ខេត្ត --------------- ។

**គោរពជូន**
**មេឃុំ ចៅសង្កាត់**-------------------------

<u>**កម្មវត្ថុ**</u> ៖ សំណើសុំលិខិតបញ្ជាក់ភាព------------------------------ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូមជម្រាបលោក លោកស្រីមេឃុំ ចៅសង្កាត់ មេត្តាជ្រាបថា បច្ចុប្បន្ន ខ្ញុំបាទ នាងខ្ញុំ មានស្ថានភាពផ្ទាល់ខ្លួន----------------------- ហើយមានបំណងរៀបអាពាហ៍ពិពាហ៍ ជាមួយឈ្មោះ-------------- ភេទ--------- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ------ ផ្លូវលេខ---------ក្រុម---------- ភូមិ----------------------- ឃុំ សង្កាត់--------------------- ក្រុង ស្រុក ខណ្ឌ------------------------ រាជធានី ខេត្ត ---------------------ប្រទេស------------- ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីមេឃុំ ចៅសង្កាត់ មេត្តាចេញលិខិតបញ្ជាក់ឱ្យខ្ញុំបាទ នាងខ្ញុំ ដើម្បីអាចរៀបអាពាហ៍ពិពាហ៍បាន ដោយអនុគ្រោះ។

ដើម្បីជាសក្ខីភាពនៃការអះអាងខាងលើ ខ្ញុំបាទ នាងខ្ញុំ សូមផ្តិតស្នាមមេដៃស្តាំ ទុកជាភស្តុតាង។

ធ្វើនៅ -----------ថ្ងៃទី-------- ខែ-------- ឆ្នាំ---------

**ស្នាមមេដៃសាមីខ្លួន**

<u>សូមជូនភ្ជាប់ជាមួយនូវ</u> ៖

– --------------------------
– --------------------------
– --------------------------

ឈ្មោះ ------------

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

4x6

រាជធានី ខេត្ត ----------------
ក្រុង ស្រុក ខណ្ឌ ----------------
ឃុំ សង្កាត់ ----------------
លេខ ----------------

ថ្ងៃទី------ ខែ---------- ឆ្នាំ-------

## លិខិតបញ្ជាក់

### ភាពនៅលីវ ភាពពោះម៉ាយ ភាពមេម៉ាយ

យោងពាក្យសុំបញ្ជាក់ភាព------------- ចុះថ្ងៃទី------ ខែ---------- ឆ្នាំ-------- របស់------------------------។

**យើងមេឃុំ ចៅសង្កាត់**-----------------------

សូមបញ្ជាក់ថា ឈ្មោះ----------------------- ភេទ------- កើតនៅថ្ងៃ------ ទី------- ខែ----------ឆ្នាំ--------- នៅភូមិ----------- ឃុំ សង្កាត់-------------- ក្រុង ស្រុក ខណ្ឌ----------------រាជធានី ខេត្ត------------------ ប្រទេស-------------មុខរបរបច្ចុប្បន្ន---------------------------------ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ-------- ផ្លូវលេខ-------- ក្រុម------- ភូមិ-------------ឃុំ សង្កាត់----------------ក្រុង ស្រុក ខណ្ឌ------------------- រាជធានី ខេត្ត----------------ប្រទេស-------------មានស្ថានភាពផ្ទាល់ខ្លួនបច្ចុប្បន្ន ពិតជា------------------ ប្រាកដមែន។

លិខិតបញ្ជាក់នេះ ចេញឱ្យសាមីខ្លួន ដើម្បីយកទៅប្រើប្រាស់ក្នុងការសុំរៀបអាពាហ៍ពិពាហ៍។

(លិខិតបញ្ជាក់នេះ មានសុពលភាពរយៈពេល៣ខែ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ)

**មេឃុំ ចៅសង្កាត់**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត** --------------------
**ក្រុង ស្រុក ខណ្ឌ** --------------------
**ឃុំ សង្កាត់** --------------------
**លេខ** --------------------

# ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍

| អំពីសាមីខ្លួន | ខាងប្រុស | ខាងស្រី |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| ទីកន្លែងកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |
| រយៈពេលប្តឹងជំទាស់ | | |
| នាមត្រកូល និងនាមខ្លួនឪពុក | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |
| នាមត្រកូល និងនាមខ្លួនម្តាយ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍នេះ ត្រូវបិទផ្សាយជាសាធារណៈ នៅថ្ងៃទី............. ខែ........................ ឆ្នាំ................. ។

ធ្វើនៅ........................ ថ្ងៃទី........... ខែ................. ឆ្នាំ............

**មន្ត្រីអត្រានុកូលដ្ឋាន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ~~ខេត្ត~~** ---- *ភ្នំពេញ* -------
**~~ក្រុង~~ ~~ស្រុក~~ ខណ្ឌ** ---- *ជ្រោយចង្វារ* -----
**~~ឃុំ~~ សង្កាត់** ---- *បាក់ខែង* ------
**លេខ** ---- *០៩ ប.ខ* -----

# បណ្ណប្រកាសអាពាហ៍ពិពាហ៍

| អំពីសាមីខ្លួន | ខាងប្រុស | ខាងស្រី |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | *សាយ សំអាន* | *អ៊ូ នួនស្រី* |
| ជាអក្សរឡាតាំង | SAY SAM ANN | OU NUON SREY |
| សញ្ជាតិ | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត | *ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣* | *ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៩* |
| ទីកន្លែងកំណើត | *ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា* | *ភូមិក្ដីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល ប្រទេសកម្ពុជា* |
| មុខរបរបច្ចុប្បន្ន | *សាស្ត្រាចារ្យ* | *គ្រូពេទ្យ* |
| ទីលំនៅបច្ចុប្បន្ន | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | *ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* |
| រយៈពេលប្ដឹងជំទាស់ | *១០ថ្ងៃ គិតពីថ្ងៃបិទផ្សាយ* | |
| នាមត្រកូល និងនាមខ្លួនឪពុក | *សាយ សំអឿន* | *អ៊ូ សែម* |
| ថ្ងៃ ខែ ឆ្នាំកំណើត | *ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ១៩៤៦* | *ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥* |
| មុខរបរបច្ចុប្បន្ន | *កសិករ* | *ជាងសំណង់* |
| ទីលំនៅបច្ចុប្បន្ន | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* |
| នាមត្រកូល និងនាមខ្លួនម្ដាយ | *សែម បុប្ផា* | *នួន ផល្លា* |
| ថ្ងៃ ខែ ឆ្នាំកំណើត | *ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៤៨* | *ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០* |
| មុខរបរបច្ចុប្បន្ន | *ជាងកាត់ដេរ* | *លក់ដូរ* |
| ទីលំនៅបច្ចុប្បន្ន | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* |

បណ្ណប្រកាសអាពាហ៍ពិពាហ៍នេះ ត្រូវបិទផ្សាយជាសាធារណៈ នៅថ្ងៃទី *០៣* ខែ *កុម្ភៈ* ឆ្នាំ *២០១៥* ។

ធ្វើនៅ.... *បាក់ខែង* ....ថ្ងៃទី *០២* ខែ *កុម្ភៈ* ឆ្នាំ *២០១៥*

**មន្ត្រីអត្រានុកូលដ្ឋាន**
***ចៅសង្កាត់***
*ផៃ សុនី*

**រាជធានី ~~ខេត្ត~~** (១)..... *ភ្នំពេញ* .......... **លេខ** (៤)................. *០៩* ............................
**~~ក្រុង~~ ~~ស្រុក~~ ខណ្ឌ** (២).... *ជ្រោយចង្វារ* ........ **សៀវភៅអាពាហ៍ពិពាហ៍លេខ** (៥)...*០១/២០១៥*..
**~~ឃុំ~~ សង្កាត់** (៣)...... *បាក់ខែង* ........ **ឆ្នាំ** (៦).......... *២០១៥*..................................

## បញ្ជីអាពាហ៍ពិពាហ៍

| **អំពីប្តី ប្រពន្ធ** | | **ប្តី** | | **ប្រពន្ធ** | |
|---|---|---|---|---|---|
| នាមត្រកូល (៧) | | *សាយ* | | *អ៊ូ* | |
| នាមខ្លួន (៨) | | *សំអាន* | | *នួនស្រី* | |
| ជាអក្សរឡាតាំង (៩) | នាមត្រកូល | SAY | | OU | |
| | នាមខ្លួន | SAM ANN | | NUON SREY | |
| សញ្ជាតិ (១០) | | *ខ្មែរ* | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | *ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣* | | *ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៩* | |
| ទីកន្លែងកំណើត (១២) ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | | *ភូមិពញ្ញាឮ ឃុំពញ្ញាឮ ស្រុកពញ្ញាឮ ខេត្តកណ្តាល ប្រទេសកម្ពុជា* | | *ភូមិក្តីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល ប្រទេសកម្ពុជា* | |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | | *សាស្ត្រាចារ្យ* | | *គ្រូពេទ្យ* | |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | |
| លេខអត្តសញ្ញាណប័ណ្ណ (១៥) | | | | | |
| ចុះបញ្ជីអាពាហ៍ពិពាហ៍លើកទី (១៦) | | *មួយ* | | *មួយ* | |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៧) | | *ថ្ងៃ សុក្រ ទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៥* | | | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៨) | | *សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ* | | | |
| លេខ និងថ្ងៃ ខែឆ្នាំប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ (១៩) | | *០៩ ប.ខ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥* | | | |
| **អំពីឪពុក ម្តាយ** | | **ខាងប្តី** | | **ខាងប្រពន្ធ** | |
| នាមត្រកូល និង នាមខ្លួនឪពុក (២០) | | *សាយ សំអឿន* | (២១) សញ្ជាតិ *ខ្មែរ* | *អ៊ូ សែម* | (២១) សញ្ជាតិ *ខ្មែរ* |
| ជាអក្សរឡាតាំង (២២) | | SAY SAM OEUN | (២៣) រស់ ឬ ស្លាប់ | OU SEM | (២៣) រស់ ឬ ស្លាប់ |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៤) | | *ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៤៦* | | *ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥* | |
| មុខរបរបច្ចុប្បន្ន (២៥) | | *កសិករ* | | *ជាងសំណង់* | |
| ទីលំនៅបច្ចុប្បន្ន (២៦) | | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | |
| នាមត្រកូល និង នាមខ្លួនម្តាយ (២៧) | | *សែម បុប្ផា* | (២៨) សញ្ជាតិ *ខ្មែរ* | *នួន ផល្លា* | (២៨) សញ្ជាតិ *ខ្មែរ* |
| ជាអក្សរឡាតាំង (២៩) | | SEM BOPHA | (៣០) រស់ ឬ ស្លាប់ | NUON PHALLA | (៣០) រស់ ឬ ស្លាប់ |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣១) | | *ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៤៨* | | *ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០* | |
| មុខរបរបច្ចុប្បន្ន (៣២) | | *ជាងកាត់ដេរ* | | *លក់ដូរ* | |
| ទីលំនៅបច្ចុប្បន្ន (៣៣) | | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | |
| **អំពីសាក្សី** | | **សាក្សី** | | **សាក្សី** | |
| នាមត្រកូល និង នាមខ្លួន (៣៤) | | *សោម ទុយ* | (៣៥) ភេទ *ប្រុស* | *សេង ភក្តី* | (៣៥) ភេទ *ស្រី* |
| សញ្ជាតិ (៣៦) | | *ខ្មែរ* | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣៧) | | *ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ១៩៧២* | | *ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៧០* | |
| មុខរបរបច្ចុប្បន្ន (៣៨) | | *កសិករ* | | *គ្រូបង្រៀន* | |
| ទីលំនៅបច្ចុប្បន្ន (៣៩) | | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | |
| លេខអត្តសញ្ញាណប័ណ្ណ (៤០) | | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានអោយប្រជាពលរដ្ឋដែលមកសុំ ជននោះ និង មន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

(៤២) ធ្វើនៅ..... *បាក់ខែង*........... ថ្ងៃទី *២១* ខែ *កុម្ភៈ* ឆ្នាំ *២០១៥*

(៤១) **ស្នាមមេដៃស្តាំ**

ប្តី ប្រពន្ធ សាក្សី សាក្សី

*សាយ សំអាន* *អ៊ូ នួន ស្រី* *សោម ទុយ* *សេង ភក្តី*

(៤៣) **មន្ត្រីអត្រានុកូលដ្ឋាន**
***ចៅសង្កាត់***
(៤៤) *ហត្ថលេខា និងត្រា*
*ផៃ សុទី*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ~~ខេត្ត~~**(១) ----- *ភ្នំពេញ* -----
**~~ក្រុង~~ ~~ស្រុក~~ ខណ្ឌ** (២) ----- *ជ្រោយចង្វារ* -----
**~~ឃុំ~~ សង្កាត់** (៣) ----- *បាក់ខែង* ------

**លេខ** (៤)------- *០៩*--------------------------
**សៀវភៅអាពាហ៍ពិពាហ៍លេខ** (៥)-*០១/២០១៥*
**ឆ្នាំ** (៦)-------- *២០១៥* ------------------------

# សំបុត្រអាពាហ៍ពិពាហ៍

| **អំពីប្ដី បពន្ធ** | | **ប្ដី** | **បពន្ធ** |
|---|---|---|---|
| នាមត្រកូល (៧) | | *សាយ* | *អ៊ូ* |
| នាមខ្លួន (៨) | | *សំអាន* | *នួនស្រី* |
| ជាអក្សរឡាតាំង (៩) | នាមត្រកូល | SAY | OU |
| | នាមខ្លួន | SAM ANN | NUON SREY |
| សញ្ជាតិ (១០) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | *ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣* | *ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៩* |
| ទីកន្លែងកំណើត (១២) ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | | *ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា* | *ភូមិក្តីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល ប្រទេសកម្ពុជា* |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | | *សាស្ត្រាចារ្យ* | *គ្រូពេទ្យ* |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌ ជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៥) | | *ថ្ងៃ សុក្រ ទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៥* | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៦) | | *សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ* | |
| **អំពីឪពុក ម្ដាយ** | | **ខាងប្ដី** | **ខាង បពន្ធ** |
| នាមត្រកូល និង នាមខ្លួនឪពុក (១៧) | | *សាយ សំអឿន* | *អ៊ូ សែម* |
| ជាអក្សរឡាតាំង (១៨) | | SAY SAM OEUN | OU SEM |
| សញ្ជាតិ (១៩) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២០) | | *ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៤៦* | *ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥* |
| នាមត្រកូល និង នាមខ្លួនម្ដាយ (២១) | | *សែម បុប្ផា* | *នួន ផល្លា* |
| ជាអក្សរឡាតាំង (២២) | | SEM BOPHA | NUON PHALLA |
| សញ្ជាតិ (២៣) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៤) | | *ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៤៨* | *ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០* |

(២៥) ធ្វើនៅ.... *បាក់ខែង* .... ថ្ងៃទី *២១* ខែ *កុម្ភៈ* ឆ្នាំ *២០១៥*

(២៦) **មន្ត្រីអត្រានុកូលដ្ឋាន**
***ចៅសង្កាត់***
(២៧) *ហត្ថលេខា និងត្រា*
*ផៃ សុទី*

# សៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ (នៅសាលាឃុំ សង្កាត់)

| លេខរៀង | ថ្ងៃខែឆ្នាំចេញសេចក្ដីចម្លង | ចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | សៀវភៅ | | សំបុត្រ | | ប្ដី ប្រពន្ធ | | | | | អ្នកសុំចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | | | | មន្ត្រីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | លេខ | ឃុំ សង្កាត់ | លេខ | ចុះថ្ងៃខែឆ្នាំ | នាមត្រកូល និងនាមខ្លួន | សញ្ជាតិ | ថ្ងៃ ខែ ឆ្នាំ កំណើត | ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | ថ្ងៃខែឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | នាមត្រកូល និងនាមខ្លួន | ទីលំនៅបច្ចុប្បន្ន | ត្រូវជាអ្វីនឹងអ្នកចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | ស្នាមមេដៃស្ដាំ | នាមត្រកូល និងនាមខ្លួន | មុខងារ | ចំនួនសន្លឹកចម្លង | សេចក្ដីផ្សេងៗ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) | (១២) | (១៣) | (១៤) | (១៥) | (១៦) | (១៧) | (១៨) | (១៩) | (២០) |
| ០១ | ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៥ | ចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ០១/ ២០១៥ | បាក់ខែង | ០៩ | ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៥ | សាយ សំអាន<br>អ៊ូ នួនស្រី | ខ្មែរ<br>ខ្មែរ | ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣<br>ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៩ | សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ | ថ្ងៃសុក្រ ទី២១ ខែ កុម្ភៈ ឆ្នាំ២០១៥ | សាយ សំអាន | ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | សាមីខ្លួន | | ផៃ សូនី | ចៅសង្កាត់ | ០៥ សន្លឹក | |
| | | | | | | | ប្ដី........ | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្រពន្ធ... | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្ដី........ | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្រពន្ធ... | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |

# សៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ (នៅសាលាក្រុង ស្រុក ខណ្ឌ)

| លេខរៀង | ថ្ងៃខែឆ្នាំចេញសេចក្ដីចម្លង | ចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | សៀវភៅ | | សំបុត្រ | | ប្ដី ប្រពន្ធ | | | | | អ្នកសុំចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | | | | មន្ត្រីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | លេខ | ឃុំ សង្កាត់ | លេខ | ចុះថ្ងៃខែឆ្នាំ | នាមត្រកូល និងនាមខ្លួន | សញ្ជាតិ | ថ្ងៃ ខែ ឆ្នាំ កំណើត | ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | ថ្ងៃខែឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | នាមត្រកូល និងនាមខ្លួន | ទីលំនៅបច្ចុប្បន្ន | ត្រូវជាអ្វីនឹងអ្នកចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | ស្នាមមេដៃស្ដាំ | នាមត្រកូល និងនាមខ្លួន | មុខងារ | ចំនួនសន្លឹកចម្លង | សេចក្ដីផ្សេងៗ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) | (១២) | (១៣) | (១៤) | (១៥) | (១៦) | (១៧) | (១៨) | (១៩) | (២០) |
| *០១* | *ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤* | *ចម្លងសំបុត្រ បញ្ជាក់អាពាហ៍ ពិពាហ៍* | *០១/ ២០០៥* | *ព្រែក គយ* | *១២* | *ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៥* | *ទេព សឿង*<br><br>*ភួង វណ្ណា* | *ខ្មែរ*<br><br>*ខ្មែរ* | *ថ្ងៃអង្គារ ទី២៧ ខែមេសា ឆ្នាំ១៩៤៨*<br>*ថ្ងៃពុធ ទី១៨ ខែកក្កដា ឆ្នាំ១៩៥៣* | *ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល* | *ថ្ងៃសុក្រ ទី១៥ ខែសីហា ឆ្នាំ២០០៥* | *ទេព សឿង* | *ភូមិសំប៉ានលើ ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា* | *សាមីខ្លួន* | | *គុង្គ គីមយ៉ន* | *ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ* | *០៦ សន្លឹក* | |
| | | | | | | | ប្ដី........ | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្រពន្ធ... | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្ដី........ | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្រពន្ធ... | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ~~ខេត្ត~~** (១) ----- *ភ្នំពេញ*-----
**~~ក្រុង~~ ~~ស្រុក~~ ខណ្ឌ** (២) ---- *ជ្រោយចង្វារ*--
**~~ឃុំ~~ សង្កាត់** (៣) ----- *បាក់ខែង* ----

# សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍

| ចម្លងសំបុត្រអាពាហ៍ពិពាហ៍ចេញពី | | (៤) សៀវភៅអាពាហ៍ពិពាហ៍<br>លេខ ៖--- *០១/២០១៥*------ | (៥) សំបុត្រអាពាហ៍ពិពាហ៍<br>លេខ *០៩* ចុះថ្ងៃទី *២១* ខែ *កុម្ភៈ* ឆ្នាំ *២០១៥* |
|---|---|---|---|
| អំពីប្តី ប្រពន្ធ | | ប្តី | ប្រពន្ធ |
| នាមត្រកូល (៦) | | *សាយ* | *អ៊ូ* |
| នាមខ្លួន (៧) | | *សំអាន* | *នួនស្រី* |
| ជាអក្សរឡាតាំង (៨) | នាមត្រកូល | *SAY* | *OU* |
| | នាមខ្លួន | *SAM ANN* | *NUON SREY* |
| សញ្ជាតិ (៩) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១០) | | *ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣* | *ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៩* |
| ទីកន្លែងកំណើត (១១)<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | | *ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល ប្រទេសកម្ពុជា* | *ភូមិក្តីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល ប្រទេសកម្ពុជា* |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១២) | | *សាស្ត្រាចារ្យ* | *គ្រូពេទ្យ* |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌ ជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | | *ថ្ងៃ សុក្រ ទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៥* | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៥) | | *សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ* | |
| អំពីឳពុក ម្តាយ | | ខាងប្តី | ខាងប្រពន្ធ |
| នាមត្រកូល និង នាមខ្លួនឳពុក (១៦) | | *សាយ សំអឿន* | *អ៊ូ សែម* |
| ជាអក្សរឡាតាំង (១៧) | | SAY SAM OEUN | OU SEM |
| សញ្ជាតិ (១៨) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៩) | | *ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៤៦* | *ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥* |
| នាមត្រកូល និង នាមខ្លួនម្តាយ (២០) | | *សែម បុប្ផា* | *នួន ផល្លា* |
| ជាអក្សរឡាតាំង (២១) | | *SEM BOPHA* | *NUON PHALLA* |
| សញ្ជាតិ (២២) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៣) | | *ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៤៨* | *ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០* |

(២៤) ធ្វើនៅ.... *បាក់ខែង* .... ថ្ងៃទី *២១* ខែ *កុម្ភៈ* ឆ្នាំ *២០១៥*

(២៥) **មន្ត្រីអត្រានុកូលដ្ឋាន**-----
***ចៅសង្កាត់***
(២៦) *ហត្ថលេខា និងត្រា*
*ផៃ សុនី*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

~~រាជធានី~~ **ខេត្ត** (១) ----- *កណ្តាល* -----
~~ក្រុង~~ **ស្រុក** ~~ខណ្ឌ~~ (២) ----- *ស្អាង* --------
**ឃុំ** ~~សង្កាត់~~ (៣) -----*ព្រែកគយ*--------

# សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

| ចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ចេញពី | | (៤) សៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ លេខ ៖ *០១/២០០៥* | (៥) សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ លេខ១២ ចុះថ្ងៃទី *១៥* ខែ *សីហា* ឆ្នាំ *២០០៥* |
|---|---|---|---|
| អំពីប្តី ប្រពន្ធ | | ប្តី | ប្រពន្ធ |
| នាមត្រកូល (៦) | | *ទេព* | *ភួង* |
| នាមខ្លួន (៧) | | *សឿង* | *វណ្ណា* |
| ជាអក្សរឡាតាំង (៨) | នាមត្រកូល | *TEP* | *PHUONG* |
| | នាមខ្លួន | *SOEUNG* | *VANNA* |
| សញ្ជាតិ (៩) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | *ថ្ងៃអង្គារ ទី២៧ ខែមេសា ឆ្នាំ១៩៤៨* | *ថ្ងៃពុធ ទី១៨ ខែកក្កដា ឆ្នាំ១៩៥៣* |
| ទីកន្លែងកំណើត (១១) ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | | *ភូមិកណ្តាល ឃុំព្រែកព្នៅ ស្រុកពញាឮ ខេត្តកណ្តាល ប្រទេសកម្ពុជា* | *ភូមិសំប៉ានលើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា* |
| មុខរបរពេលចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ (១២) | | *គ្រូបង្រៀន* | *ជាងកាត់ដេរ* |
| ទីលំនៅពេលចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ (១៣) | | *ភូមិទួលសូភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា* | *ភូមិទួលសូភី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា* |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ (១៤) | | *ថ្ងៃ សុក្រ ទី ១៥ ខែ សីហា ឆ្នាំ ២០០៥* | |
| ទីកន្លែងចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ (១៥) | | *ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល* | |
| អំពីឪពុក ម្តាយ | | ខាងប្តី | ខាងប្រពន្ធ |
| នាមត្រកូល និង នាមខ្លួនឪពុក (១៦) | | *ទេព សួង* | *កៅ សៀម* |
| ជាអក្សរឡាតាំង (១៧) | | *TEP SUONG* | *KAO SEAM* |
| សញ្ជាតិ (១៨) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៩) | | *ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩២៣* | *ថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩២២* |
| នាមត្រកូល និង នាមខ្លួនម្តាយ (២០) | | *ប្រាក់ សម្បត្តិ* | *សុខ សន* |
| ជាអក្សរឡាតាំង (២១) | | *PRAK SAMBATH* | *SOK SAN* |
| សញ្ជាតិ (២២) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៣) | | *ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩២៥* | *ថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩២៦* |

លេខ (ក)..... *០៥ ស.ប.អ* ............
យើង (ខ).... *អភិបាលស្រុកស្អាង* .........................
បានឃើញ និងបញ្ជាក់ថា ហត្ថលេខាខាងស្តាំនេះ ជាហត្ថលេខា
របស់លោក (គ)......*គុង្គ គីមយ៉ន*....... ជាមន្ត្រីរក្សាសៀវភៅ
អត្រានុកូលដ្ឋាន (ឃ)...... *ស្រុកស្អាង*.........ពិតប្រាកដមែន។
(ង) ធ្វើនៅ...ស្អាង.... ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤
(ច) *ហត្ថលេខា និងត្រា*
*ខឹម ច័ន្ទគិរី*

(២៤) ធ្វើនៅ....ស្អាង ..... ថ្ងៃទី *២៤* ខែ *មករា* ឆ្នាំ *២០១៤*
(២៥) **មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន**----
*ហត្ថលេខា*
*គុង្គ គីមយ៉ន*